ISSN 1560-7615 / ISBN 978-99950-52-06-5

# ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

ឯកសារបោះពុម្ពផ្សាយរបស់
វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

ឆ្នាំទី១០ លេខ ១ | មករា-មីនា ឆ្នាំ២០០៦ | តម្លៃ ១.៥០០រ

## កម្មវិធីសកម្មភាពអាទិភាពក្នុងបឋមសិក្សានៅកម្ពុជា

ប៉ក់ គឹមជឿន អ្នកស្រាវជ្រាវនៅ CDRI ពិភាក្សាពីប្រព័ន្ធគ្រប់គ្រងចំណាយសាធារណៈ (PEM) នៅកម្ពុជាដោយផ្អែកលើលទ្ធផលរកឃើញក្នុងអង្កេតតាមដានចំណាយសាធារណៈ (PETS) នៅបឋមសិក្សា ដែលជាការសិក្សារួមគ្នារវាង វបសអ ធនាគារពិភពលោក និង ADB ។



*សិស្សកំពុងសិក្សាក្នុងថ្នាក់រៀននៅតាមសាលាជនបទ*

ជាទូទៅប្រព័ន្ធថវិកាកម្ពុជា ប្រើប្រាស់វិធីសាស្ត្រមជ្ឈការបែបបុរាណតាមប្រព័ន្ធបារាំង ។ កម្ពុជាបានចាប់ផ្តើមធ្វើកំណែទំរង់ហិរញ្ញវត្ថុដើមឆ្នាំ១៩៩៣ តាមការប្រកាសឱ្យប្រើច្បាប់ប្រព័ន្ធហិរញ្ញវត្ថុ (ថវិកា) ។ ជារៀងរាល់ឆ្នាំ ការព្យាករណ៍ចំណូលថវិកាជាតិសរុប តែងធ្វើឡើងនៅខែឧសភា/មិថុនា ដោយផ្អែកលើការព្យាករណ៍ពីកំណើន ផសស ដើម្បីឈានទៅព្យាករណ៍ធនធានដែលមានសំរាប់ឆ្នាំក្រោយ ។ នៅចុងខែកក្កដា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកំណត់ចេញនូវក៏រិតថវិកាអតិបរមា បែងចែកទៅឱ្យវិស័យ និងសកម្មភាពវិនិយោគនានា ដែលនឹងត្រូវអនុម័តដោយគណៈរដ្ឋមន្ត្រី (CoM) ។

គំរោងថវិកា មានបែងចែកតាមជំពូក និងខ្ទង់ផ្សេងៗ[1] ។ ថវិកាសំរាប់ចំណាយចរន្ត និងចំណាយជាមូលធនត្រូវបានរៀបចំដាច់ដោយឡែកពីគ្នា ។ ថវិកាចរន្តជាទូទៅមានជំពូក១០ (បៀវត្សរ៍ និងប្រាក់បំណាច់), ជំពូក១១ ចំនាយដំណើរការរដ្ឋបាល (សំភារៈ និងការជួសជុលតិចតួច) និងជំពូក ៣១ (អន្តរាគមន៍ក្នុងវិស័យសង្គមកិច្ចនិងវប្បធម៌) ។នៅខែកញ្ញា/តុលា ក្រសួង-មន្ទីរជំនាញនិមួយៗចរចាថវិការបស់ខ្លួនជាមួយនាយកដ្ឋានថវិកា ។ ពង្រាងចុងក្រោយនៃគំរោងថវិកា ដែលមានតួលេខសរុប និងលំអិត នឹងត្រូវអនុម័តដោយគណៈរដ្ឋមន្ត្រី នឹងត្រូវឆ្លងរដ្ឋសភាយ៉ាងយូរបំផុតនៅសប្តាហ៍ចុងក្រោយនៃខែធ្នូ ។

នៅពេលថវិកាអនុម័តហើយ គេត្រូវអនុវត្តវាយ៉ាងតឹងរ៉ឹងដោយមានការគ្រប់គ្រងក៏រិតខ្ពស់ពីអាជ្ញាធរថ្នាក់កណ្តាល ។ ក្នុងនេះត្រូវមានការអនុមតិពីក្រសួងហិរញ្ញវត្ថុ សំរាប់ការផ្ទេរថវិកានៅក្នុងជំពូកចំណាយ (ឧ. ជំពូក១១) និងពីក្រុមប្រឹក្សារដ្ឋមន្ត្រីសំរាប់ការផ្ទេរឆ្លងជំពូក ។ ដំណើរការសុំការអនុមតិមានលក្ខណៈការិយាល័យធិបតេយ្យ និងបែបបទច្រើន អស់ពេលយូរ រឿងខ្លះអស់យ៉ាងតិច ២ខែ ។ ក្រសួងហិរញ្ញវត្ថុ និងមន្ទីរក្រោមឱវាទតាមខេត្ត រតនាគារជាតិ និងរតនាគារខេត្តតាមដាន និងអនុម័តចំណាយលទ្ធកម្ម និងការទូទាត់ក្នុងការអនុវត្តន៍ថវិការបស់ក្រសួង-មន្ទីរជំនាញ ។

### ការផ្តួចផ្តើមធ្វើកំណែទំរង់

មានការទទួលស្គាល់ជាទូទៅថា ប្រព័ន្ធសព្វថ្ងៃគ្មានប្រសិទ្ធភាព ពីព្រោះនាំឱ្យបាត់បង់ថវិកា និងបង្កការពិបាកផ្សេងៗ ដូចជា ការយឺតយូរនិងកង្វះតំលាភាពក្នុងការចំនាយថវិកា ។ ទោះធៀបនឹងស្តង់ដាប្រទេសកំពុងអភិវឌ្ឍន៍ក្តី ក៏ប្រព័ន្ធនេះនៅទន់ខ្សោយគ្រប់ចំនុច (ដូចជា ការកសាងគំរោងថវិកា ចំណាយ និងរបាយការណ៍) ហើយបង្កការបារម្ភពីសមត្ថភាពដោះស្រាយ សូម្បីការងារសាមញ្ញៗ ។ នៅចំពោះមុខអប្រសិទ្ធភាព

## មាតិកា

កម្មវិធីសកម្មភាពអាទិភាពក្នុងបឋមសិក្សានៅកម្ពុជា ........ 1
កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន-ចិន ........ 5
រចនាសម្ព័ន្ធសមាគមកសិករនៅកម្ពុជា ........ 10
តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស ........ 13
- ស្ថានភាពក្នុងប្រទេស ........ 15
- សន្ទស្សន៍សេដ្ឋកិច្ច ........ 17
ពតិមានថ្មីៗពី វបសអ ........ 20

ទាំងនេះ ក្រសួងហិរញ្ញវត្ថុ អប់រំ និងសុខាភិបាល បានព្រមព្រៀងលើគំនិតផ្តួចផ្តើមមួយចំនួន រួមទាំង PAP ផង ដើម្បីបញ្ជូនថវិកាទៅឱ្យវិស័យជាអាទិភាពទាំង២ ដោយជៀសវាងពីបែបបទរឹងកំព្រឹស ការយឺតយ៉ាវ និងភាពមិនច្បាស់លាស់ កើតចេញពីដំណើរការអនុវត្តន៍ថវិកាតាមរបៀបមជ្ឈការបែបបុរាណ ។

ចំនុចគន្លឹះមួយទៀតក្នុងការកែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺការចាប់អនុវត្តន៍កម្មវិធីកំណែទំរង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ[២] (PFM) នៅចុងឆ្នាំ២០០៤ ដោយមានគោលដៅរយៈពេលវែងអនុវត្តឱ្យបានតាមស្តង់ដាអន្តរជាតិដ៏ប្រសើរទទួលយកបានជាទូទៅ ។ កំណែទំរង់ឈរលើគោលនយោបាយជាអាទិភាពតាមលំដាប់ ៤ គឺៈ ១) គំរោងថវិកាគួរឱ្យជឿជាក់ ២) គណនេយ្យភាពហិរញ្ញវត្ថុដ៏ជាក់ស្តែង ៣) របៀបវារៈគោលនយោបាយរដ្ឋាភិបាលមានកំនត់អាទិភាពនិងអាចធ្វើបាននិង៤) អ្នកគ្រប់គ្រងក្នុងជួររដ្ឋមានគណនេយ្យភាពពេញលេញលើលទ្ធផលកម្មវិធី ។[៣]

## អង្កេតតាមដានចំណាយសាធារណៈ(PETS) នៅបឋមសិក្សាកម្ពុជា

PAP មានលើកជាពិសេសនៅក្នុងកម្មវិធីកំណែទំរង់ PFM ថា ជាចំណុចគន្លឹះនៃវិសហមជ្ឈការហិរញ្ញវត្ថុក្នុងរយៈពេលមធ្យម ហើយគេត្រូវវាយតំលៃវាសិន មុននឹងអាចអនុវត្តជាទូទៅបាន ។ដូច្នេះក៏មានការព្រមព្រៀងរវាងអ្នកផ្តល់ជំនួយសំខាន់ៗ (រួមទាំងWB) នឹងរដ្ឋាភិបាល ដើម្បីប្រើប្រាស់ PETS ជាឧបករណ៍វាយតំលៃលំអិតទៅលើ PAP ដោយចាប់ផ្តើមធ្វើក្នុងវិស័យអប់រំ ក្រោយពេលអនុវត្ត PAP បាន ៤ឆ្នាំ ។

PETS គឺជាបច្ចេកទេសអង្កេតសំរាប់តាមដានមើលថវិកាសាធារណៈដែលឆ្លងកាត់លំដាប់ថ្នាក់រដ្ឋផ្សេងៗ (ឧទាហរណ៍ ថ្នាក់ខេត្ត ថ្នាក់ស្រុក) ដើម្បីកំណត់ថា មានថវិកាប៉ុន្មាន (ក្នុងចំនួនបានលៃចែកឱ្យ) ដែលបានទៅដល់កន្លែងប្រើប្រាស់ និងតើវាទៅដល់ទាន់ពេលរឺទេ ។ អង្កេតមានប្រយោជន៍ក្នុងការកំណត់ពីកន្លែង និងបរិមាណនៃការត្រងយកថវិកាសាធារណៈជាលក្ខណៈនយោបាយ និងការិយាធិបតេយ្យ ការធ្លាយជ្រុះថវិកា និងបញ្ហាចោទក្នុងការប្រើប្រាស់ធនធានមនុស្ស និងសំភារៈ ។ PETS ដាក់ប្រើសាកល្បងជា ដំបូងដោយ WB នៅឆ្នាំ១៩៩៦ នៅ Uganda, បន្ទាប់មកនៅ ១២ប្រទេសទៀត ដូចជា កម្ពុជា, Albania, Chad, Ghana, Honduras, Macedonia, Papua New Guinea, Peru, Rwanda, Senegal, Sierra Leone និង Tanzania ។ បច្ចុប្បន្នមិនទាន់មានការវាយតំលៃគ្រប់ជ្រុងជ្រោយលើផលប៉ះពាល់របស់ PETS ទេ ពីព្រោះអង្កេតមួយចំនួននៅថ្មីពេកមិនទាន់អាចវាយតំលៃបានទេ ។[៤]

នៅកម្ពុជានាពាក់កណ្តាលឆ្នាំ២០០៤ វបសអ បានធ្វើអង្កេត PETS លើកទី១ លើ PAP ថ្នាក់បឋមសិក្សា និងថវិកាជំពូក១១ ។ ការសិក្សាបានធ្វើនៅ ២១ស្រុក (ក្នុង ៧ខេត្តៈ បន្ទាយមានជ័យ កំពង់ចាម កំពង់ឆ្នាំង កំពត ក្រចេះ ព្រៃវែង ក្រុងព្រះសីហនុ) លើ ២០០សាលាបឋមសិក្សា ។ នៅសាលានីមួយៗ បានសំភាសនាយក សាលាម្នាក់ គ្រូបង្រៀន ៦នាក់ គណៈកម្មការទ្រទ្រង់សាលា ៣នាក់ ឪពុកម្តាយសិស្ស ៦នាក់ និងបានពិនិត្យបញ្ជីរបស់សាលា រួមទាំងបញ្ជី PAP ផង ។ បានជ្រើសសិស្សប្រហែល ៤០នាក់ មកធ្វើតេស្តខាងអក្សរសាស្ត្រ និងលេខនិព្វន្តនិងបំពេញបញ្ជីសំនួរស្តីពីទ្រព្យសម្បត្តិគ្រួសារ និងការសិក្សារបស់ពួកគេ ។ បានពិនិត្យរបាយការណ៍ពីPAP និងជំពូក១១និងបានធ្វើសំភាសន៍តាមបែបគុណភាពនៅមន្ទីរអប់រំខេត្ត (PEO) និងការិយាល័យអប់រំស្រុក (DEO) ។

លទ្ធផលរកឃើញក្នុង PETS អាចពិភាក្សាដូចតទៅ ក្នុងចំណោមសកម្មភាពPAP ទាំង១២ PETS[5] ពិនិត្យតែ PAP ២.១ (ថវិកាប្រតិបត្តិការបឋមសិក្សា) តំណាងឱ្យ១/៤ នៃ PAPទាំងមូល ។ សំណួរស្រាវជ្រាវដែលលើកមកពិនិត្យពេលនេះគឺៈ តើPAP2.1 បានទៅដល់សាលារៀនរឺទេ? បើបានដល់ តើវាទៅដល់ទាន់ពេល និងអាចទាយដឹងមុនរឺទេ? តើបាត់បង់អស់ប៉ុណ្ណា? តើមានប្រព័ន្ធត្រួតពិនិត្យអ្វីខ្លះ និងមានការចូលរួមរបស់សហគមន៍ក្នុងដំណើរការនេះរឺទេ? តើPAP ជួយដល់អ្នកក្រ និងមានប្រសិទ្ធភាពរឺទេក្នុងការកែលំអថ្នាក់បឋមសិក្សា? នៅចុងបញ្ចប់ មានលើកអនុសាសន៍ស្តីពីគោលនយោបាយសំខាន់ៗដែលផ្អែកលើលទ្ធផល PETS ។

## PAP នៅក្នុងការអប់រំ

តាំងពីការសាកល្បងនៅឆ្នាំ២០០០ PAP បានរីកធំយ៉ាងរហ័ស ។ នៅឆ្នាំ២០០១ កម្មវិធីបានពង្រីកដល់ទូទាំង ២៤ខេត្តក្រុង[៦] ។ នៅឆ្នាំ២០០២ វាបន្តរីកធំ ដោយមានបញ្ចូលការងារច្រើនទៀតសំរាប់សកម្មភាពទាំង ១២ របស់ PAP ។ ដល់ត្រឹមខែមិថុនា ២០០៤ មានការលៃចែក ៧៧ពាន់លានរៀល សំរាប់ចំណាយឆ្នាំ២០០៣ លើទាំង ១២ សកម្មភាព PAP នៅទូទាំងប្រទេស ។ ក្នុងនេះ ៣៤% ត្រូវបានលៃចែកឱ្យ PAP ២ សំរាប់កែលំអគុណភាព និងប្រសិទ្ធភាពនៅបឋមសិក្សា ។

PETS មិនបានគ្របដណ្តប់លើ PAP ទាំងមូលទេ ប៉ុន្តែត្រឹម PAP 2.1 ដែលជាផ្នែកមួយនៃ PAP 2 សំរាប់ជួយទ្រទ្រង់បឋមសិក្សាក្នុងទូទាំងប្រទេស ។ PAP 2.1 គឺជាថវិកា PAP ធំជាងគេដែលផ្តល់ទៅឱ្យសាលាបឋមសិក្សា ។នៅតាមខេត្តគំរូតាងPAP2.1 តំណាងឱ្យជាមធ្យមជិត៥០% នៃថវិកា PAP ទាំងអស់សំរាប់ការអប់រំ ។ វាជាអំណោយថវិកាផ្អែកលើរូបមន្តដែលកំណត់ឱ្យសាលាបឋមសិក្សានីមួយៗទទួលបានថវិកាជាចំនួនថេរមួយ (៥០០.០០០រៀល) បូកនឹងចំនួនកូនសិស្សសរុបគុណនឹងវិភាជន៍ក្នុងសិស្សម្នាក់ៗ (៦.០០០រៀល) ។

## *PAP 2.1* ការគ្រប់គ្រង និងអនុវត្តន៍ថវិកា

តាមធម្មតានៅខែកក្កដា រៀងរាល់ឆ្នាំ សាលារៀនថ្នាក់ស្រុក និងថ្នាក់ខេត្តរៀបចំសំណើថវិកា PAP និងដាក់សុំទៅក្រសួងហិរញ្ញវត្ថុ ។ មន្ទីរជំនាញផ្សេងៗនៅក្រសួងអប់រំ ធ្វើការព្រមព្រៀងគ្នាលើពង្រាងថវិកា PAP សំរាប់មុខនីមួយៗនៃសកម្មភាព PAP ទាំង ១២ និងបញ្ជូនវាទៅក្រសួងហិរញ្ញវត្ថុ ។ ក្រសួងហិរញ្ញវត្ថុប្រើប្រាស់សវនកម្ម ដើម្បីអនុម័តគំរោងថវិកា និងចំណាយ ដោយគ្មានការធ្វើសវនកម្មជាមុន រឺការអនុមតិលើសំណើចំណាយដូចនៅក្នុងវិធីបុរាណទេ ។ថវិកាPAP2.1 ត្រូវផ្ទេរទៅឱ្យសាលាតាមការបើកផ្តល់ជាច្រើនដង (បើកផ្តល់ ៦ដងជាមធ្យមក្នុងគំរោងថវិកាឆ្នាំ២០០២) ឆ្លងតាមប្រព័ន្ធរតនាគារដែលមានស្រាប់ទៅកាន់PEO ។ ដោយគ្មានប្រើប្រាស់ប្រព័ន្ធធនាគារ PEO ទទួលប្រាក់ពីរតនាគារខេត្ត ហើយយកទៅឱ្យ DEO និងជាចុងក្រោយឱ្យបន្តទៅសាលារៀន ។ ដើម្បីសំរួលការគ្រប់គ្រង មជ្ឈមណ្ឌលគ្រប់គ្រងថវិកា (BMC) ត្រូវបានបង្កើតឡើង ។ នៅឆ្នាំ២០០៣ មានៈ ២៥មណ្ឌល នៅក្រសួងអប់រំ ដើម្បីជួយធ្វើការនៅតាមនាយកដ្ឋានជំនាញនីមួយៗ, ១មណ្ឌល/ខេត្ត និង ១៤៤មណ្ឌលនៅតាម DEO ទាំង ១៨៥ ។

PEO ទទួលភារកិច្ចបើកផ្តល់ថវិកាឱ្យ PAP ផ្សេងៗទៅតាមតំរូវការ និងពេលវេលាជាក់ស្តែង ដោយត្រូវអនុវត្តតាមថវិកាអនុមតិពីខាងដើម ។

សំរាប់ PAP 2.1 ដោយផ្អែកលើរូបមន្តលៃចែក PEO ត្រូវសំរេចថា សាលារៀនណាគួរទទួលបានការបែកចែកប្រាក់ប៉ុណ្ណា និងបញ្ជាឱ្យ DEO បែងចែកទៅតាមនោះ ។ ដោយមានសេចក្តីណែនាំអាចបត់បែនបានគួរសមក្នុងការចាយវាយ សាលាបឋមសិក្សាគ្រប់គ្រងលើថវិកា PAP 2.1 ដែលទទួលបាន ។ PEO, DEO និងសាលារៀនទាំងអស់ ត្រូវកត់ត្រាចំនួលចំណាយសាច់ប្រាក់ ។នៅតាមសាលារៀន របាយការណ៍ចំណាយ PAP ត្រូវមានការបញ្ជាក់យល់ព្រមពីគណៈកម្មាធិការទ្រទ្រង់សាលារៀន (SSC) ។ តាមធម្មតា SSC និងសមាគមមាតាបិតាសិស្ស គឺជាអង្គភាពតែមួយ ។

### *តើថវិកាប្រតិបត្តិការសាលាបឋមសិក្សា (PAP 2.1) បានទៅដល់សាលារៀនដែរឬទេ?*

ការសិក្សាបង្ហាញថា គំលាតនៃការផ្តល់ថវិកា PAP 2.1 គឺ ២,៦% ២៥,១% និង ៤,២% សំរាប់ឆ្នាំសារពើពន្ធ ២000, ២00១ និង ២00២ ។ គំលាតនេះប្រែប្រួលខុសគ្នាតិចតួចពីខេត្តមួយទៅខេត្តមួយ និងខុសគ្នាតិចតួចមែនទែនរវាងសាលារៀនក្នុងខេត្តតែមួយ ។ គំលាតកើតចេញពីកត្តាពីរជាសំខាន់គឺ គំលាតអនុវត្តថវិកា និងការបាត់បង់ថវិកា ។ នៅថ្នាក់ខេត្ត និងថ្នាក់ក្រោមនេះទៀត គំលាតអនុវត្តថវិកាសំដៅដល់ការខុសគ្នារវាងPAP 2.1 ដែលបានកំណត់ បែងចែកទៅឱ្យPEO និងចំនួនដែល PEO ទទួលបានជាក់ស្តែង ។ ការបាត់បង់ថវិកាសំដៅដល់ ថវិកាដែលបាត់នៅពេលផ្ទេរពីរតនាគារខេត្តទៅដល់សាលារៀន ។ការសិក្សាបានរកឃើញការបាត់បង់ ២ប្រភេទគឺ ១) ការធ្លាយជ្រុះគិតតាមបង្កាន់ដៃទទួលប្រាក់ និង ២) ប្រាក់កំរៃរត់ការ (រឺប្រាក់កំរៃក្រៅផ្លូវការ) ដែលត្រូវបង់នៅពេលដកប្រាក់ពីរតនាគារខេត្ត PEO និង DEO (គ្មានចុះលើបង្កាន់ដៃទេ) ។ ការសិក្សាបង្ហាញថា ប្រាក់កំរៃរត់ការដែលបានបង់ ដើម្បីដកថវិកាពីរតនាគារខេត្តឱ្យសាលារៀន មានដល់ទៅ ២% នៃសាច់ប្រាក់ត្រូវបើកផ្តល់ ។

### *តើហេតុអ្វីមានការបាត់បង់ថវិកាតិចយ៉ាងដូច្នេះ?*

PAP គឺជាការផ្តួចផ្តើមធ្វើកំណែទំរង់ ដោយផ្អែកលើសវនកម្ម និងមិនសូវមានមជ្ឈការច្រើនទេ គឺខុសគ្នាពីវិធីបុរាណ ។ ដោយសារ PAP 2.1 ផ្អែកលើរូបមន្ត ហើយនាយកសាលាទាំងអស់ដឹងពីរូបមន្តនេះ ដូច្នេះវាជួយកាត់បន្ថយការកាត់យកភាគរយ ហើយបទពិសោធន៍នៅប្រទេសដទៃក៏មានលក្ខណៈដូចគ្នា ។ ម្យ៉ាងទៀត នៅពេល PAP 2.1 ផ្ទេរឆ្លងកាត់លំដាប់ថ្នាក់នានា, រតនាគារខេត្ត PEO និង DEO ពុំសូវមានអំណាចកាត់យកភាគរយទេ ព្រោះគ្រាន់តែត្រូវបញ្ជូនប្រាក់ប៉ុណ្ណោះ ។ ការធ្លាយជ្រុះថវិកាកាន់តែថយចុះព្រោះគ្មានតំរូវការធ្វើបែបបទ រឺបំពេញសំណុំឯកសារ

*តារាង ១. គំលាតមធ្យមនៃការផ្តល់ថវិកា PAP 2.1 បានរាយការណ៍នៅតាមខេត្ត (%)*

| ខេត្ត | 2000 | 2001 | 2002 |
|---|---|---|---|
| បន្ទាយមានជ័យ | គ្មានលេខ | -24.4 | -2.6 |
| កំពង់ចាម | គ្មានលេខ | -23.0 | -16.3 |
| កំពង់ឆ្នាំង | -2.6 | -21.9 | 0.5 |
| កំពត | -3.1 | -20.6 | -2.9 |
| ក្រចេះ | 2.4 | -19.7 | -2.0 |
| ព្រៃវែង | -6.1 | -22.8 | -4.7 |
| ក្រុងព្រះសីហនុ | គ្មានលេខ | -42.9 | 1.8 |
| សរុប | -3.1 | -23.5 | -6.3 |

អ្វីពិបាកៗ ដើម្បីផ្តល់ប្រាក់ពីថ្នាក់មួយទៅថ្នាក់មួយទៀតទេ ដូច្នេះក៏មានឱកាសតិចតួចសំរាប់ខ្ទប់ច្រកថវិកាយកកំរៃដែរ ។

លទ្ធភាពកាត់យកភាគរយកាន់តែថយចុះដោយសារថ្នាក់នីមួយៗយល់ថាអាចមានបញ្ហាសន្តិសុខ បើសិនរក្សាទុកសាច់ប្រាក់ច្រើនៗ ។ ម្យ៉ាងទៀត មន្ត្រីអនុវត្ត PAP ដឹងថា មានអធិការកិច្ច និងសវនកម្មច្រើនណាស់លើថវិកានេះ ។ ពិតហើយ ថវិកា PAP យ៉ាងច្រើន (ឧ. PAP 11) បានទុកចំនាយទទួលលើអធិការកិច្ច ។ ចំនុចទាំងអស់នេះធ្វើអោយ PAP ក្លាយជារឿងពិបាកទារយកកំរៃ បើធៀបនឹងខ្ទង់ថវិកាឯទៀត ដូចជា ជំពូក១១ ជាដើម ។

### *តើ PAP ទៅដល់សាលារៀនទាន់ពេល និងអាចទាយដឹងមុនទេ?*

ពេលវេលា ការទាយដឹងមុន និងទំហំនៃការបើកផ្តល់ថវិកាធៀបនឹងតំរូវការរបស់សាលាក្នុងឆ្នាំនីមួយៗ ក៏សំខាន់ដែរសំរាប់ដំនើរការសាលារៀន ។ ការសិក្សា PETS បង្ហាញថា តាំងពីចាប់អនុវត្តន៍នៅឆ្នាំ២000 មក ថវិកា PAP រួមទាំង PAP 2.1 ផង មានបើកផ្តល់យឺត ថ្វីបើមានកែលំអខ្លះហើយពេលថ្មីៗនេះក្តី (តារាង២) ។ ការយឺតយ៉ាវប៉ះពាល់មិនល្អដល់ការអនុវត្តន៍គំរោងនៅតាមសាលារៀន ពិសេសនៅពេលបវេសនកាល ។ កង្វះថវិកាបង្ខំឱ្យសាលារៀនត្រូវទិញជើសំភារៈក្នុងក៏រិតថ្លៃខ្ពស់ នាយកសាលាខ្លះថា វាខ្ពស់ជាងថ្លៃធម្មតា (៥%) បើធៀបនឹងការទិញឱ្យប្រាក់ដល់ដៃ ។

*តារាង ២. ពេលវេលានិងការបើកផ្តល់ PAP 2.1 ឱ្យទៅសាលារៀន (% ប្រាក់បានទទួលបូកត្រួតគ្នាគិតតាមត្រីមាស)*

| ឆ្នាំ | 1 | 2 | 3 | 4 | 1 | 2 | 3 | 4 |
|---|---|---|---|---|---|---|---|---|
| 2000 | - | - | - | 24.9 | 38.8 | 99.5 | 100 | |
| 2001 | - | - | 43.6 | 49.2 | 63.0 | 100 | | |
| 2002 | - | - | 0.1 | 47.6 | 53.2 | 73.8 | 98.7 | 100 |
| 2003 | - | - | - | 21.4 | 89.4 | 100 | | |

ការបើកផ្តល់ប្រាក់តិចៗច្រើនដងពេក ក៏នាំឱ្យកើនចំនាយប្រតិបត្តិការដែរ ។ ការផ្ទេរប្រាក់នីមួយៗ តែងមានចំនាយដឹកជញ្ជូនវិភាជន៍សំរាប់បុគ្គលិកអ្នកទៅយកប្រាក់ និងកំរៃរត់ការ ។

### *តើការពិនិត្យតាមដានចំណាយ PAP 2.1 នៅសាលារៀនមានប្រសិទ្ធភាពដែរឬទេ?*

យន្តការត្រួតពិនិត្យចំនាយPAP2.1 នៅសាលារៀននៅទន់ខ្សោយ ។ទីមួយ អធិការកិច្ចហិរញ្ញវត្ថុនៅតាមសាលារៀនមិនសូវធ្វើញឹកញាប់ទេ (ពី 0-២ដង/ឆ្នាំ) ឯគុណភាពវាក៏នៅមិនច្បាស់លាស់ ។ អធិការកិច្ចតាមសាលាភាគច្រើនមានរយៈពេលកន្លះថ្ងៃ និងគ្មានរបាយការណ៍ពីលទ្ធផលអធិការកិច្ចទេ ។សាលារៀន និងមន្ត្រីថ្នាក់ស្រុកទទួលស្គាល់ថា ពេលខ្លះសាលាត្រូវចំណាយថវិកា PAP លើសកម្មភាពខុសពីសេចក្តីណែនាំលើខ្ទង់ចំណាយ PAP ដូច្នេះក៏រាយការណ៍មិនត្រូវ តាមការពិត ដើម្បីឱ្យរបាយការណ៍ចំណាយអាចទទួលយកបាន ។រឿងនេះបង្ហាញពីភាពរឹងកំព្រឹសនៃចំណាយ PAP, របាយការណ៍មិនបានផ្តល់ព័ត៌មានត្រឹមត្រូវ ហើយធ្ងន់ធ្ងរបំផុត គឺអាចប្រើប្រាស់ ដើម្បីលាក់ចំណាយថវិកាខុសឆ្គងបាន បើសិនគេចង់ធ្វើដូច្នេះ ។

### *តើសហគមន៍ចូលរួមយ៉ាងសកម្មដែរឬទេ ក្នុងការពិនិត្យតាមដាន PAP និងកិច្ចការសាលារៀន?*

ការចូលរួមរបស់សហគមន៍ ញ៉ាំងឱ្យមានគណនេយ្យភាពនៃថ្នាក់គ្រប់គ្រង

*តារាង ៣. ការយល់ដឹងនៃគ្រូបង្រៀន, សមាជិក SSC និងឪពុកម្តាយសិស្សពី PAP (%)*

| អ្នកឆ្លើយសំភាសន៍ | ដឹងថា PAP ជាអ្វី | ដឹងពីវិភាជន៍ ៦.០០០រសំរាប់សិស្សម្នាក់ (ក្នុងចំនោមអ្នកស្គាល់ PAP) | ដឹងថាសាលាត្រូវទទួល៥០០.០០០រ (ក្នុងចំណោមអ្នកស្គាល់ PAP) | ដឹងថាមានសេចក្តីណែនាំពីខ្ទង់ចំណាយ (ក្នុងចំនោមអ្នកស្គាល់ PAP) | ដឹងចំនុចលំអិតក្នុងសេចក្តីណែនាំពីចំនាយ (ក្នុងចំនោមអ្នកដឹងពីសេចក្តីណែនាំ) |
|---|---|---|---|---|---|
| គ្រូបង្រៀន | 97 | 56 | 25 | 90 | 21 |
| សមាជិកគណៈកម្មការទ្រទ្រង់សាលា | 83 | 27 | 14 | 72 | 7 |
| ឪពុកម្តាយសិស្ស | 9 | 0 | 0 | គ្មានលេខ | គ្មានលេខ |

សាលាចំពោះសហគមន៍ ។ ការសិក្សាបង្ហាញថា ការចូលរួមនេះមានកំរិតទាបនៅឡើយដូចមានបញ្ជាក់ក្នុងតារាង៣ ។ ក្រៅពីនាយកសាលា គ្រូបង្រៀន គឺជាអ្នកដឹងច្បាស់ជាងគេពី PAP ហើយក៏ជាអ្នកតែងលើកសួរពីបញ្ហាទាក់ទងនឹងចំនាយ PAP ដែរ ។ ប៉ុន្តែពួកគេគ្មានពេលគ្រប់គ្រាន់ (គ្រូ ៧០% មានការងារផ្សេងមួយទៀតក្រៅពីបង្រៀន) និងគ្មានគ្រឿងលើកទឹកចិត្តឱ្យចូលរួមទេ ។ សមាជិកគណៈកម្មការទ្រទ្រង់សាលា (SSC) មិនសូវបានចូលពាក់ព័ន្ធក្នុងបញ្ហាចំណាយ PAP និងមិនសូវមានច្រើនគ្នាទេ ដែលបានដឹងពីថវិកាត្រូវបាន និងរបៀបចាយវាយវា ។ ម្យ៉ាងទៀត SSP ជាទូទៅ មិនបានចាត់ទុកការជួយពិនិត្យតាមដានចំណាយ PAP ជាការងារចំបងរបស់ខ្លួនទេ គឺពួកគេច្រើនតែផ្តោតលើការសាងសង់សាលារៀន និងការកែលំអផ្សេងៗទៅវិញ ។

ឪពុកម្តាយសិស្សយល់ដឹងតិចជាងគេពី PAP គឺតែ ៩% ប៉ុណ្ណោះ ដែលប្រាប់ថា ធ្លាប់ឮពី PAP តែគ្មានម្នាក់ណាដឹងលំអិតពីវាទេ ។ ជាទូទៅ ពួកគេក៏មិនសូវចូលរួមក្នុងការងារសាលាដែរ គឺមានតែ ៣០% ប៉ុណ្ណោះ ដែលបានចូលរួមពិធីសម្ពោធសាលារៀន ហើយ ១២% មិនទាំងដឹងថា មានពិធីនេះផង ។ ប៉ុន្តែឪពុកម្តាយ ៩៧% រាយការណ៍ថា លែងបង់ថ្លៃសាលារៀនឱ្យកូនគាត់ទៀតហើយ ចាប់តាំងមានPAP មក ។ខុសគ្នាពីទីក្រុងដែលមានរឿងរ៉ាវគ្រូបង្រៀនទារប្រាក់ពីសិស្ស ក្នុងតំបន់អង្កេតមានឪពុកម្តាយតែ ៥% ប៉ុណ្ណោះដែលបានលើកពីទង្វើបែបនេះ ។

## តើ PAP 2.1 មានសមភាពដែរឬទេ, តើវាមានឥទ្ធិពលយ៉ាងណាដល់ការចុះឈ្មោះចូលរៀន?

តាមការវិភាគពីធនធានសាលារៀន ដែលវាស់វែងតាមខាងផ្នែកតំរូវការ និងការប្រៀបធៀបវាទៅនឹងចំនួន និងពេលវេលាទទួលបាន PAP 2.1 ការសិក្សាបង្ហាញថា ការបែងចែកថវិកា PAP 2.1 ឱ្យទៅសាលារៀន វាអំណោយផលដល់អ្នកក្រ ហើយពេលវេលាផ្តល់មិនទាក់ទងនឹងធនធានទេ ។ រឿងនេះមកពីរូបមន្ត PAP 2.1 អំណោយផលដល់សាលាតូចៗ ហើយសាលាតូចៗច្រើនតែក្រីក្រ ។ អង្កេតបង្ហាញទៀតថា មានការកែលំអគួរកត់សំគាល់ក្នុងការចុះឈ្មោះចូលរៀនក្នុងរយៈ ៥ឆ្នាំកន្លងទៅ ជាពិសេសតួលេខសុទ្ធនៃអត្រាចុះឈ្មោះចូលរៀននៅបឋមសិក្សា ហើយ PAP 2.1 ហាក់ដូចជាបានជួយជំរុញរឿងនេះ ។ លទ្ធផលដំបូងៗបង្ហាញថា ចាប់ពីឆ្នាំ ២០០០/០១ ដល់ ឆ្នាំ២០០១/០២, PAP 2 បង្កើនការចុះឈ្មោះចូលរៀនថ្នាក់ទី១ បានជាមធ្យម ២៥នាក់/សាលារៀន រឺកំណើន ១៥% ធៀបនឹងលទ្ធផលមុនពេលធ្វើកំណែទំរង់ ។ ឥទ្ធិពលនេះ មានខ្លាំងជាងនៅតាមសាលារៀនជនបទ គឺហាក់ដូចបង្ហាញថា PAP 2.1 មានឥទ្ធិពលជួយចែកចាយធនធានយ៉ាងសំខាន់ ។ ប៉ុន្តែ របាយការណ៍ក៏បំផុសគំនិតយ៉ាងខ្លាំងថាបញ្ហាគុណភាពការអប់រំ ត្រូវតែដោះស្រាយគឺត្រឡប់មកដល់បញ្ហាចំនួនគ្រូ គុណភាព និងគ្រឿងលើកទឹកចិត្តវិញដដែល ។

## អនុសាសន៍គន្លឹះ

អនុសាសន៍មួយចំនួនទាក់ទិននឹង PAP ដោយផ្អែកលើលទ្ធផលរកឃើញក្នុង PETS មានដូចតទៅ:

- គួរកែលំអថែមទៀតនូវគំរូថវិកាសំរាប់កម្មវិធី ជាពិសេសទាក់ទិននឹងវិសហមជ្ឈការសិទ្ធិអំណាចទៅឱ្យក្រសួងជំនាញដោយដាក់សាកល្បងរបៀបរបបអនុវត្តថ្មីៗនៅឆ្នាំ២០០៦ ក្នុងក្រសួងជ្រើសរើសខ្លះៗ ។
- ត្រូវមានការកែលំអនៅក្នុងយន្តការត្រួតពិនិត្យ និងតាមដាន PAP 2.1 ដើម្បីទប់ស្កាត់ការបាត់បង់ថវិកាដោយ ១) កែលំអរបាយការណ៍ថវិកា និងបង្កើនការតំរូវផ្សេងៗខាងរបាយការណ៍ និងគ្រឿងលើកទឹកចិត្តឱ្យគោរពតាមការណែនាំកែលំអសវនកម្មផ្ទៃក្នុង និងបង្កើនការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ។
- គួរអនុវត្តសាកល្បងក្នុងសាលារៀនជ្រើសរើសមួយចំនួននូវយុទ្ធសាស្ត្រ "អំណាចទទួលបានព័ត៌មាន" ដើម្បីទាញការចូលរួមពីឪពុកម្តាយសិស្សតាមរយៈគណៈកម្មការទ្រទ្រង់សាលារៀន និងអង្គភាពផ្សេងទៀត ។
- កំណត់ជាផ្លូវការនូវរបៀបរបបបើកផ្តល់ធនធាន PAP អំពី PEO តាមលំដាប់អាទិភាពដល់កម្មវិធីនានា ដែលដល់ពេលទិញចាំបាច់ និងផ្តល់លទ្ធភាពសាលាមានសិទ្ធិអំណាចច្រើនលើការចាយថវិកា PAP ពេលយន្តការត្រួតពិនិត្យបានកែលំអហើយ ។
- ដោយពិនិត្យឃើញថា វាមានប្រយោជន៍ជាក់ស្តែងក្នុងវិស័យអប់រំគួរបញ្ចូលទិដ្ឋភាពខ្លះៗនៃ PETS ជាឧបករណ៍សំរាប់ការគ្រប់គ្រង ។

## កំណត់សំគាល់

១. ទំរង់នេះបញ្ជាក់ពីការបែងចែកថវិកាទាំងមូលទៅតាមប្រភេទចំនាយ និងខ្ទង់ចំនាយលំអិត ។ ឧទាហរណ៍ ទំរង់នេះមិនគ្រាន់តែមាន ចុះថាមានថវិកាប៉ុន្មានសំរាប់ប្រតិបត្តិការ/ការថែទាំនោះទេ ប៉ុន្តែមានប្រាប់ពីចំណាយប៉ុន្មានសំរាប់សាំង ទឹក ភ្លើងជាដើម ។

២. សូមអានឯកសារក្រសួងហិរញ្ញវត្ថុ ឆ្នាំ២០០៤ សំរាប់ព័ត៌មានលំអិតអំពីកម្មវិធីកំណែទំរង់ PFM (សូមអាន Reinikka ២០០៣) សំរាប់ព័ត៌មានបន្ថែមពី PETS និងវិធីសាស្ត្ររបស់វា ។

៣. សកម្មភាពទាំង ១២ មាន ១) ប្រសិទ្ធភាពសេវាកម្មបង្រៀនក្នុងវិស័យ

*តទៅទំព័រទី១៣*

# កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាស៊ាន_ចិន: ខ្លឹមសារ និង ផលប៉ះពាល់ចំពោះកម្ពុជា

*លោក ហ៊ីង វុត្ថា អ្នកស្រាវជ្រាវនៅ វបសអ បានពិនិត្យពីចំណុចសំខាន់ៗនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយរវាងអាស៊ាន-ចិន ដោយសង្កត់ធ្ងន់លើកម្មវិធីប្រមូលផលឆាប់ និងស្រាវជ្រាវពីឱកាសសេដ្ឋកិច្ច បញ្ហាប្រឈម និងផលប៉ះពាល់នៃកិច្ចព្រមព្រៀងទៅលើភាពក្រីក្រក្នុងបរិបទប្រទេសកម្ពុជា ។**

តំបន់ពាណិជ្ជកម្មសេរីរវាងអាស៊ាន-ចិន ត្រូវបានអនុម័តនៅក្នុងកិច្ចប្រជុំកំពូលអាស៊ានបូកបី នៅខែវិច្ឆិកា ឆ្នាំ២០០០ ។ ក្រុមជំនាញអាស៊ាន-ចិន សំរាប់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ត្រូវបានបង្កើតឡើង ដើម្បីសិក្សាពីផលប៉ះពាល់នៃការចូលជាសមាជិក អង្គការពាណិជ្ជកម្មពិភពលោក (WTO) របស់ចិន និងលទ្ធភាពបង្កើតតំបន់ពាណិជ្ជកម្មសេរីរវាងតំបន់ទាំងពីរ ។ នៅក្នុងកិច្ចប្រជុំកំពូល អាស៊ានលើកទី៨ នាខែវិច្ឆិកា ២០០២ នៅក្រុងភ្នំពេញបណ្តាប្រទេសអាស៊ាន និងចិន បានចុះហត្ថលេខាលើកិច្ចព្រមព្រៀងក្របខ័ណ្ឌស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ ដើម្បីពង្រឹង និងជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ សំដៅបង្កើតតំបន់ពាណិជ្ជកម្មសេរីមួយក្នុងរយៈពេល ១០ឆ្នាំ ។ កិច្ចព្រមព្រៀងក្របខ័ណ្ឌ មានចែងពីកិច្ចសហប្រតិបត្តិការលើទំនិញ សេវាកម្ម និងវិនិយោគ និងការដកចេញរបាំង ពាណិជ្ជកម្មរវាងអាស៊ាន និងចិន ។ វិធានការសេរីភាវូបនីយកម្មទាំងនេះ នឹងជួយកាត់បន្ថយថ្លៃដើម បង្កើនសកម្មភាពពាណិជ្ជកម្ម និងឯកទេសនីយកម្មក្នុងតំបន់ បង្កើនប្រសិទ្ធភាពសេដ្ឋកិច្ចនិងទាក់ទាញវិនិយោគកាន់តែច្រើនមកក្នុងទីផ្សារតំបន់ ។តាមការចូលជាសមាជិកអាស៊ាននៅខែមេសា ១៩៩៩ កម្ពុជាត្រូវផ្សារភ្ជាប់នឹងកិច្ចព្រមព្រៀងនេះជាស្វ័យប្រវត្តិ ហើយគេរំពឹងថា វានឹងផ្តល់អត្ថប្រយោជន៍ឱកាសសេដ្ឋកិច្ចនិងបញ្ហាប្រឈមមួយចំនួនដល់កម្ពុជា ។នៅមិនទាន់ច្បាស់ទេថា ដល់កាត់កងគ្នាអស់ទៅ តើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនេះ មានលក្ខណៈវិជ្ជមាន រឺអវិជ្ជមាន ពីព្រោះសព្វថ្ងៃមានព័ត៌មាន និងការស្រាវជ្រាវតិចណាស់ពីផលប៉ះពាល់នៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិននេះចំពោះកម្ពុជា ។

អត្ថបទនេះមានគោលដៅបំពេញកង្វះខាតព័ត៌មាននេះដោយ (១) ពិនិត្យពីចំនុចសំខាន់ៗនៃកិច្ចព្រមព្រៀងក្របខ័ណ្ឌរវាងអាស៊ាន-ចិន និង (២) ស្រាវជ្រាវពីផលប៉ះពាល់ចំពោះឱកាសខាងសេដ្ឋកិច្ច បញ្ហាប្រឈម និងភាពក្រីក្រនៅកម្ពុជា ។អត្ថបទនេះផ្អែកជាសំខាន់លើការស្រាវជ្រាវថ្មីៗរបស់ វបសអ ស្តីពី "កម្មវិធីប្រមូលផលឆាប់: ផលប៉ះពាល់ចំពោះកសិកម្មកម្ពុជា" ដែលផ្តល់មូលនិធិដោយការិយាល័យតំបន់អាស៊ីអគ្នេយ៍នៃអង្គការអុកស្វាមអាមេរិក ។

## ខ្លឹមសារកិច្ចព្រមព្រៀងក្របខ័ណ្ឌ

កិច្ចព្រមព្រៀងក្របខ័ណ្ឌ ស្តីពីកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចគ្រប់ជ្រុងជ្រោយ បានចែងពីពាណិជ្ជកម្មលើទំនិញ សេវាកម្ម និងវិនិយោគដោយមានគោលដៅជាក់លាក់បួនៈ (១) ពង្រឹង និងជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច ពាណិជ្ជកម្ម និងវិនិយោគ (២) ធ្វើសេរីភាវូបនីយកម្មជាបណ្តើរៗ និងជំរុញពាណិជ្ជកម្មលើទំនិញ និងសេវាកម្ម ព្រមទាំងបង្កើតរបប វិនិយោគមួយដែលមានលក្ខណៈជួយសំរួល និងមានតំលាភាព (៣) ស្វែងរកតំបន់ថ្មីៗនិងបង្កើតវិធានការសមស្រប ជំរុញកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឱ្យកាន់តែជិតស្និទ្ធ និង (៤) ជួយសំរួលឱ្យសមាជិកអាស៊ានថ្មីៗធ្វើសមាហរណកម្មសេដ្ឋកិច្ចមានប្រសិទ្ធភាព និងកាត់បន្ថយគំលាត កំរិតអភិវឌ្ឍន៍ក្នុងចំណោមប្រទេសជាសមាជិក ។ កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញដែលធ្វើឡើងនៅខែធ្នូ ២០០៤ បានកំណត់ពីការកាត់បន្ថយពន្ធគយ និងលុបចោលផលិតផលពីរប្រភេទដែលគេហៅថា ផ្លូវធម្មតា និងផ្លូវស្មុគស្មាញ ។ផលិតផលក្នុងផ្លូវធម្មតា គួរមានការព្រមព្រៀងទៅវិញទៅមក ដើម្បីកាត់បន្ថយ រឺលុបបំបាត់ពន្ធគយក្នុងអំឡុងពេលពីថ្ងៃ ០១ មករា ២០០៥ ដល់ ២០១០ សំរាប់ប្រទេសអាស៊ាន៦[១] និងចិន និងរហូតដល់ឆ្នាំ២០១៥[២] សំរាប់ប្រទេស CLMV[៣] ។ ផលិតផលក្នុងផ្លូវស្មុគស្មាញ[៤] គឺជាផលិតផលដែលភាគីណាមួយ បានស្នើសុំដាក់អត្រាពន្ធគយអតិបរមាចុងក្រោយ និងកាលបរិច្ឆេទបញ្ចប់ខុសគ្នាពីកាលវិភាគធម្មតា ប៉ុន្តែត្រូវមានការយល់ព្រមទៅវិញទៅមកពីប្រទេសអាស៊ាននីមួយៗ និងចិនផងដែរ ។ អាស៊ាន និងចិន បានយល់ព្រមចរចាធ្វើសេរីភាវូបនីយកម្មជាបណ្តើរៗលើពាណិជ្ជកម្មខាងសេវាកម្ម ដើម្បីពង្រីកវិសាលភាពរបស់វា ។ ការចរចាចាប់ផ្តើមនៅឆ្នាំ២០០៣ និងសំដៅបញ្ចប់យ៉ាងលឿនតាមអាចធ្វើបាន ។ កិច្ចព្រមព្រៀងមានគោលដៅលុបបំបាត់ជាបណ្តើរៗ ការរើសអើងគ្រប់បែបយ៉ាងខាងពាណិជ្ជកម្មសេវាកម្ម រវាង/ក្នុងចំណោមសមាជិកអាស៊ាន និងចិន ព្រមទាំងពង្រីកកំរិតនិងវិសាលភាព សេរីភាវូបនីយកម្មនៃពាណិជ្ជកម្មក្នុងវិស័យសេវាកម្ម ។ វាក៏ជួយជំរុញកិច្ចសហប្រតិបត្តិការក្នុងវិស័យសេវាកម្មថែមទៀត ដើម្បីកែលំអប្រសិទ្ធភាព និងបរិយាកាសប្រកួតប្រជែង និងធ្វើចំរុះកម្មការផ្គត់ផ្គង់/ការចែកចាយសេវាកម្ម ។

ចំពោះវិនិយោគ ភាគីទាំងពីរបានព្រមព្រៀងៈ (១) ចរចាគ្នាដើម្បីធ្វើសេរីភាវូបនីយកម្មជាបណ្តើរនូវរបបវិនិយោគ (២) ពង្រឹងកិច្ចសហប្រតិបត្តិខាងវិនិយោគ ជួយសំរួលវិនិយោគ និងកែលំអច្បាប់វិនិយោគឱ្យមានតំលាភាព និង (៣) ផ្តល់នូវកិច្ចការពារដល់ការវិនិយោគទុន ។

## *កម្មវិធីប្រមូលផលឆាប់*

ដើម្បីពន្លឿនការកាត់បន្ថយ និងការលុបបំបាត់ពន្ធគយលើទំនិញ កិច្ចព្រមព្រៀងក្របខ័ណ្ឌបានចែងពីកម្មវិធីប្រមូលផលឆាប់(EarlyHarvestProgramme: EHP) ដែលគ្របដណ្តប់លើផលិតផល ៨ជំពូក ក្នុងប្រព័ន្ធស៊ីសង្វាក់គ្នា គឺមាន (១) សត្វរស់ (២) សាច់សត្វ និងគ្រឿងក្នុងមានសាច់ហូបបាន (៣)

* អត្ថបទនេះ ផ្អែកលើរបាយការណ៍ធ្វើដោយក្រុមជំនាញការអាស៊ាន-ចិនខាងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ច កាលពីខែតុលា ២០០១ មាន ចំណងជើងថា "ការបង្កើតទំនាក់ទំនងសេដ្ឋកិច្ចអាស៊ាន-ចិនកាន់តែជិតស្និទនៅសតវត្សរ៍ទី២១" ។

ត្រី (៤) ផលិតផលទឹកដោះគោ (៥) ផលិតផលផ្សេងទៀតបានពីសត្វ (៦) ដើមឈើរស់ (៧) បន្លែហូបបាន និង (៨) ផ្លែឈើ និងគ្រាប់ឈើហូបបាន ។ ចំពោះការកាត់បន្ថយ និងលុបបំបាត់ពន្ធគយគ្រប់ផលិតផលក្នុងកម្មវិធីប្រមូលផលឆាប់ ត្រូវបានបែងចែកជា ៣ប្រភេទ ទៅតាមអត្រាពន្ធគយអនុគ្រោះបំផុត (MFN) កំនត់ឡើងដោយប្រទេសនិមួយៗ ។

- ប្រភេទទី១: សំរាប់អាស៊ាន៦ និងចិន វាសំដៅដល់គ្រប់ផលិតផលដែលមានអត្រាពន្ធគយ MFN ខ្ពស់ជាង ១៥% ។ សំរាប់ប្រទេសអាស៊ានថ្មី វាសំដៅដល់គ្រប់ផលិតផលដែលមានអត្រាពន្ធគយ MFN ស្មើ រឺខ្ពស់ជាង ៣0% ។
- ប្រភេទទី២: សំរាប់អាស៊ាន៦ និងចិន និងសំដៅដល់គ្រប់ផលិតផលដែលមានអត្រាពន្ធគយ MFN ពី ៥% ដល់ ១៥% ។ សំរាប់ប្រទេសអាស៊ានថ្មី វាសំដៅដល់គ្រប់ផលិតផលដែលមានអត្រាពន្ធគយ MFN ពី ១៥% ដល់ ៣0% ។
- ប្រភេទទី៣: សំរាប់អាស៊ាន៦ និងចិន វាសំដៅដល់គ្រប់ផលិតផលដែលអត្រាមានពន្ធគយ MFN ទាបជាង ៥% ។ សំរាប់ប្រទេសអាស៊ានថ្មី វាសំដៅដល់គ្រប់ផលិតផលដែលមានអត្រាពន្ធគយ MFN ទាបជាង ១៥% ។

ការអនុវត្តន៏កម្មវិធីប្រមូលផលឆាប់ ចាប់ផ្តើមនៅខែមករា ២០០៤ ដោយមានតារាងពេលកាត់បន្ថយពន្ធគយជាបន្តបន្ទាប់ដូចមានបញ្ជាក់ក្នុង *តារាង (១) និង តារាង (២)* ។

*តារាង (១) សំរាប់ចិន និងអាស៊ាន៦*

| ប្រភេទផលិតផល | មិនហួសថ្ងៃ១ មករា ២០០៤ | មិនហួសថ្ងៃ១ មករា ២០០៥ | មិនហួសថ្ងៃ១ មករា ២០០៦ |
|---|---|---|---|
| ប្រភេទ ១ | 10% | 5% | 0% |
| ប្រភេទ ២ | 5% | 0% | 0% |
| ប្រភេទ ៣ | 0% | 0% | 0% |

## ទំនាក់ទំនងសេដ្ឋកិច្ចកម្ពុជា_ចិន

ទំនាក់ទំនងសេដ្ឋកិច្ចកម្ពុជា-ចិន បានរីកចំរើនគួរសំគាល់តាំងពីទសវត្សរ៏ ១៩៩0 ។ មុនពេលមានកិច្ចព្រមព្រៀងក្របខណ្ឌរវាងអាស៊ាន និងចិន នៅខែវិច្ឆិកា ២០០២ កម្ពុជាបានចុះកិច្ចព្រមព្រៀង ការពារ និងជំរុញវិនិយោគជាមួយចិននៅខែកក្កដា ១៩៩៦ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មទ្វេភាគី នៅខែកក្កដា ១៩៩៧ ។ កិច្ចព្រមព្រៀងទាំងនេះ បានជួយពង្រីកពាណិជ្ជកម្ម និងវិនិយោគរវាងប្រទេសទាំងពីរ ។

## *ពាណិជ្ជកម្មកម្ពុជា_ចិន*

ពាណិជ្ជកម្មសរុបរបស់កម្ពុជាជាមួយចិន កើនឡើងសន្សឹមៗក្នុងអត្រាប្រចាំឆ្នាំ ៥0% ក្នុងឆ្នាំ១៩៩៥-២០០៤ ។ ចិនជាដៃគូពាណិជ្ជកម្មរបស់កម្ពុជាដ៏ធំក្នុងលំដាប់ទី៧ នៅឆ្នាំ១៩៩៥ និងក្នុងលំដាប់ទី៤ នៅឆ្នាំ២០០៣ ។ ពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជាជាមួយចិន បានកើនឡើងតាមអត្រាប្រចាំឆ្នាំ ២៣% ពី ឆ្នាំ១៩៩៥-២០០១ និង ៧៧% ពីឆ្នាំ២០០១-២០០៤ ។ ការនាំចេញ របស់កម្ពុជាទៅចិន កើនពី ៣,៨លានដុល្លារនៅឆ្នាំ១៩៩៥ ដល់ ៣0លានដុល្លារនៅឆ្នាំ២០០៤ រីឯការនាំចូលពីចិនវិញកើនពី ៣៩ លានដុល្លារនៅឆ្នាំ១៩៩៥ ដល់ ៤៥២លានដុល្លារនៅឆ្នាំ២០០៤ ។ ក្នុងឆ្នាំ១៩៩៥-២០០៤ ការនាំចេញរបស់កម្ពុជាទៅចិនបានកើន ៤១% គឺយឺតជាងការនាំចូលពីចិនដែលកើនដល់ ៩៧% ។

កម្ពុជានាំចេញផលិតផលធនធានធម្មជាតិ និងកសិកម្ម និងនាំចូលផលិតផលឧស្សាហកម្មច្រើនមុខពីចិន ដូចជា វាយនភណ្ឌ និងសំលៀកបំពាក់ ដែកនិងដែកថែប កុលាលភាជន៏ (គ្រឿងសេរ៉ាមិច) សំភារៈអគ្គិសនី និងអេឡិចត្រូនិក ម្ហូបអាហារ និងគ្រឿងយាន ។ ទំនិញនាំចេញធំបំផុតរបស់កម្ពុជាទៅចិន គឺឈើ និងសំភារៈធ្វើពីឈើ ដែលតំណាងឱ្យពាក់កណ្តាលនៃការនាំចេញសរុប និងមានតំលៃ ១៥លានដុល្លារ

*តារាង (២) សំរាប់ប្រទេសអាស៊ានថ្មី*

| ប្រទេស | មិនហួស ថ្ងៃ១ មករា ២០០៤ | មិនហួស ថ្ងៃ១ មករា ២០០៥ | មិនហួស ថ្ងៃ១ មករា ២០០៦ | មិនហួស ថ្ងៃ១ មករា ២០០៧ | មិនហួស ថ្ងៃ១ មករា ២០០៨ | មិនហួស ថ្ងៃ១ មករា ២០០៩ | មិនហួស ថ្ងៃ១ មករា ២០១០ |
|---|---|---|---|---|---|---|---|
| *ផលិតផលប្រភេទទី១* | | | | | | | |
| កម្ពុជា | | | 20% | 15% | 10% | 5% | 0% |
| ឡាវ | | | 20% | 14% | 8% | 0% | 0% |
| ភូមា | | | 20% | 14% | 8% | 0% | 0% |
| វៀតណាម | 20% | 15% | 10% | 5% | 0% | 0% | 0% |
| *ផលិតផលប្រភេទទី២* | | | | | | | |
| កម្ពុជា | | | 10% | 10% | 5% | 5% | 0% |
| ឡាវ | | | 10% | 10% | 5% | 0% | 0% |
| ភូមា | | | 10% | 10% | 5% | 0% | 0% |
| វៀតណាម | 10% | 10% | 5% | 5% | 0% | 0% | 0% |
| *ផលិតផលប្រភេទទី៣* | | | | | | | |
| កម្ពុជា | | | 5% | 5% | 0-5% | 0-5% | 0% |
| ឡាវ | | | 5% | 5% | 0-5% | 0% | 0% |
| ភូមា | | | 5% | 5% | 0-5% | 0% | 0% |
| វៀតណាម | 5% | 5% | 0-5% | 0-5% | 0% | 0% | 0% |

នៅឆ្នាំ២០០៤ ។ ការនាំចេញចំបងៗផ្សេងទៀតទៅចិន មានដូចជា កប្បាស កៅស៊ូ និងត្រី ។ វិស័យវាយនភណ្ឌ និងសំលៀកបំពាក់ មានប្រមាណ ៦៣% នៃការនាំចូលសរុបរបស់កម្ពុជាពីចិន រឺ ២៨៦លានដុល្លារនៅឆ្នាំ២០០៤ ។ ទំនិញនាំចូលធំបំផុតលំដាប់ទី២របស់កម្ពុជាពីចិន គឺម៉ាស៊ីន និងគ្រឿងអគ្គិសនីដែលមានតំលៃដល់ ៣៧,៩៩លានដុល្លារ រឺ ៨% នៃការនាំចូលសរុប ។ ទំនិញនាំចូលចំបងៗផ្សេងទៀង រួមមាន សាច់ ត្រីនិងគ្រឿងសមុទ្រ ដែក និងដែកថែប របស់របរធ្វើពីដែក-ដែកថែប ផលិតផលកុលាលភាជន៍ (សេរ៉ាមិច) និងគ្រឿងយន្ត ។

ក្នុងកម្មវិធីប្រមូលផលឆាប់ កម្ពុជានាំចេញទៅចិននូវសត្វរស់ ត្រីរស់ បង្គា បង្កង និងក្ដាមខ្យង ។ ទំនិញនាំចេញទាំងនេះ មានតំលៃដល់ ១,៣២លានដុល្លារ រឺប្រហែល ៤% នៃការនាំចេញសរុបរបស់កម្ពុជាទៅចិន ។ បង្គា និងបង្កង គឺជាមុខទំនិញធំបំផុតក្នុងប្រភេទនេះដែលមានតំលៃ ៧២៥.០០០ដុល្លារ នៅឆ្នាំ២០០៤ បន្ទាប់មក គឺត្រីរស់ សត្វរស់ និងក្ដាមខ្យង ។ កម្ពុជានាំចូលពីចិននូវ ផលិតផលក្នុងជំពូកទី៧ (បន្លែ) និងជំពូកទី៨ (ផ្លែឈើនិង គ្រាប់ឈើហូបបាន) ដែលមានតំលៃដល់ ១,៤៧៨លានដុល្លារ រឺ ០,៣% នៃការនាំចូលសរុបពីចិន ។ ខ្ទឹមស គឺជាមុខទំនិញធំបំផុតក្នុងប្រភេទនេះ និងមានតំលៃដល់ ៧២០.០០០ដុល្លារ នៅឆ្នាំ២០០៤ ។ ផលិតផលផ្សេងទៀត មានផ្លែប៉ោម ផ្សិតក្រៀម ផ្លែព័រ សណ្ដែកក្រហម និងបន្លែ ។

### *ការវិនិយោគ*

នៅឆ្នាំ១៩៩៥-២០០៤ ចិនជាប្រភពវិនិយោគផ្ទាល់ពីបរទេសធំបំផុតលំដាប់ទី៤ របស់កម្ពុជា ដោយបណ្ដាក់ទុនក្នុងជាង ១៥០គំរោងដែលមានតំលៃក្នុងកិច្ចសន្យា ៣៩៥លានដុល្លារ រឺ ៩% នៃវិនិយោគផ្ទាល់ពីបរទេស (FDI) សរុប ។ វិស័យវិនិយោគចំបងៗ គឺមានសំណង់ហេដ្ឋារចនាសម្ព័ន្ធកាត់ដេរ វាយនភណ្ឌ និងអភិវឌ្ឍន៍កសិកម្ម ។ កាត់ដេរ គឺជាវិស័យតែមួយគត់ដែលមានលំហូរចូលទុនវិនិយោគយ៉ាងទៀងទាត់ពីចិនតាំងពីឆ្នាំ១៩៩៥ ដោយមានតំលៃសរុប ១០០លានដុល្លារនៅឆ្នាំ១៩៩៥-២០០៤ រឺប្រហែល ២៥% នៃវិនិយោគសរុបពីចិន ។

### ផលប៉ះពាល់ចំពោះកម្ពុជា

តាមទ្រឹស្ដីសេដ្ឋកិច្ច កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ផ្ដល់អត្ថប្រយោជន៍

*ក្រាហ្វិក១ : ពាណិជ្ជកម្មក្រៅប្រទេសរបស់កម្ពុជា ជាមួយចិន*




ប្រភព : ទីចាត់ការគយ និងរដ្ឋាករ (TradeMap: ITC)

ជាច្រើនដល់គ្រប់ប្រទេសសមាជិកមានតាំងពីកំណើនប្រសិទ្ធភាពសេដ្ឋកិច្ច រហូតដល់ការរីតចំណងសហប្រតិបត្តិការ និងភាពជាដៃគូ ក្នុងវិស័យមិនមែនសេដ្ឋកិច្ច ដូចជា លើកកំពស់សន្តិភាព និងស្ថិរភាពជាដើម ។ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ដែលតំរូវឱ្យកាត់បន្ថយពន្ធគយ និងលុបបំបាត់របាំងមិនមែនពន្ធជាបណ្ដើរៗ រំពឹងថានឹងជួយបន្ទាបថ្លៃដើមទំនិញ បង្កើនពាណិជ្ជកម្មក្នុងតំបន់ និងជួយបង្កើនលក្ខណៈប្រកួតប្រជែង ផលិតភាព និងប្រសិទ្ធភាព ។

### ឱកាសសេដ្ឋកិច្ច

សំរាប់កម្ពុជា ឱកាសសំខាន់បំផុតទាក់ទងនឹងតំបន់ពាណិជ្ជកម្មសេរី គឺលទ្ធភាពកាន់តែធូរទូលាយដើម្បីចូលទៅទីផ្សារចិនដែលធំសំបើម និងកំពុងរីកលូតលាស់ ។ ដូចបានបញ្ជាក់ពីខាងដើម ប្រទេសកម្ពុជានាបច្ចុប្បន្ននាំចេញទៅចិននូវកៅស៊ូ ត្រី សត្វចិញ្ចឹម និងបង្គា ។ តាមការអនុវត្តន៍កម្មវិធីប្រមូលផលឆាប់ ផលិតផលកសិកម្មភាគច្រើន នឹងមានលទ្ធភាពធំទូលាយចូលទៅទីផ្សារចិន ដូច្នេះគឺមានសក្ដានុពលខ្ពស់ដើម្បីរីកលូតលាស់ ។

ទី២ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី អាចជួយទាក់ទាញវិនិយោគផ្ទាល់ពីបរទេសកាន់តែច្រើនមកកម្ពុជា ទាំងពីប្រទេសសមាជិក និងប្រទេសផ្សេងទៀតលើពិភពលោក ។ អាស៊ាន៦ និងចិន កំពុងអភិវឌ្ឍ និងកែលំអសេដ្ឋកិច្ចរបស់ខ្លួន ដោយងាកចេញពីឧស្សាហកម្មផលិតទំនិញជាមូលដ្ឋាននិងប្រើពលកម្មច្រើន ទៅធ្វើឧស្សាហកម្មប្រើបច្ចេកវិទ្យាខ្ពស់ និងពលកម្មមានជំនាញ ។ ដូច្នេះ គេរំពឹងថា ឧស្សាហកម្មផលិតទំនិញជាមូលដ្ឋាន និងប្រើពលកម្មច្រើន នឹងផ្លាស់កន្លែងចូលមកប្រទេសមានកំរិតអភិវឌ្ឍន៍ទាបជាង ដូចជាកម្ពុជាជាដើម ។ ដោយសារទំហំធនធាន និងកំរិតអភិវឌ្ឍន៍របស់ខ្លួន កម្ពុជាអាចជាគោលដៅល្អមួយសំរាប់វិនិយោគខាងឧស្សាហកម្មប្រើបច្ចេកវិទ្យាទាប និងពលកម្មច្រើន ។ វិស័យកាត់ដេរ និងកសិ-ឧស្សាហកម្ម មានសក្ដានុពលខ្ពស់ដើម្បីទាក់ទាញទុនវិនិយោគផ្ទាល់ពីបរទេសចូលមកពីចិន និងប្រទេសអាស៊ាននានា ។

ទី៣ ការលុបបំបាត់ពន្ធគយ និងរបាំងមិនមែនពន្ធគយរំពឹងថា អាចជួយសំរួលសកម្មភាពពាណិជ្ជកម្ម និងជំរុញឯកទេសនីយកម្ម ។ ចំពោះរចនាសម្ព័ន្ធពាណិជ្ជកម្ម និងលំនាំផលិតផលនៃកម្មវិធីប្រមូលផលឆាប់រវាងកម្ពុជា និងចិន កម្ពុជាមានសក្ដានុពលខ្ពស់ ដើម្បីធ្វើការនាំចេញទៅចិននូវផលិតផលកាន់តែច្រើនដែលខ្លួនអាចផលិត ដោយមានប្រសិទ្ធភាពខ្ពស់ជាង ដូចជា ត្រី បង្គា និងសត្វរស់ជាដើម ។ កម្ពុជា ក៏អាចធ្វើចំរុះកម្មកសិផលនាំចេញឱ្យមាន ដូចជា សណ្ដែកសៀង សណ្ដែកបាយ និងដំឡូងឈើថែមទៀត ។

ទី៤ កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី នឹងផ្ដល់ឱ្យអ្នកប្រើប្រាស់កម្ពុជានូវជំរើសផលិតផលកាន់តែច្រើន និងមានថ្លៃប្រកួតប្រជែង ដូច្នេះវាជួយបង្កើនសុខមាលភាពអ្នកប្រើប្រាស់ ។ ក្រៅពីឱកាសសេដ្ឋកិច្ច កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន អាចបង្កើតឱកាសមិនមែនសេដ្ឋកិច្ចមួយចំនួនទៀត ដូចជា ការពង្រឹងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការក្នុងវិស័យឯទៀត, ការរីតចំណងសហប្រតិបត្តិការជាមួយចិន ក្នុងមហាអនុតំបន់ទន្លេមេគង្គ និងការទទួលបានកាន់តែច្រើននូវលក្ខខណ្ឌពិសេស និងជំនួយបច្ចេកទេសពីចិន ។

### *បញ្ហាប្រឈម*

សំរាប់កម្ពុជា កិច្ចព្រមព្រៀងក្របខ័ណ្ឌបានបង្កើតផងដែរនូវបញ្ហាប្រឈមធំៗមួយចំនួនក្នុងការរិះរកវិធីល្អបំផុត ដើម្បីប្រើប្រាស់កិច្ចព្រមព្រៀង និងកាត់បន្ថយផលប៉ះពាល់អវិជ្ជមានជាយថាហេតុ ។ បញ្ហាប្រឈមទី១ គឺការកសាងសមត្ថភាពខាងផ្នែកផ្គត់ផ្គង់ ដើម្បីប្រកួតប្រជែងបានល្អនៅទីផ្សារក្នុងតំបន់ ។ រឿងនេះ ត្រូវមានការបង្កើតក្របខ័ណ្ឌគោលនយោបាយក្នុងស្រុកមួយជួយទ្រទ្រង់ដល់វិស័យឯកជន ជាពិសេសសហគ្រាសធុនតូច និងមធ្យម តាមរយៈការកាត់បន្ថយបន្ទុកចំនាយធ្វើអាជីវកម្ម ។ ការងារនេះ ទាមទារគុណភាព និងសមត្ថភាពនៃស្ថាប័នរដ្ឋសំខាន់ៗក្នុងការសំរបសំរួល និងអនុវត្តគោលនយោបាយ ដើម្បីបង្កើនសមត្ថភាពផលិតរបស់សហគ្រាសឯកជន ។

ចំនុចបារម្ភមួយទៀតសំរាប់កម្ពុជា គឺផលប៉ះពាល់អវិជ្ជមានជាយថាហេតុនៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម ចំពោះផលិតករ និងទីផ្សារពលកម្មក្នុងស្រុក ។ នៅពេលរបាំងពាណិជ្ជកម្មបានដកចេញអស់ ឧស្សាហកម្មមួយចំនួន នឹងរីកលូតលាស់ ហើយមួយចំនួនទៀតនឹងធ្លាក់ចុះវិញ ដោយសារការប្រកួតប្រជែង ។រឿងនេះអាចនាំឱ្យមានការបែងចែកចំណាយ និងអត្ថប្រយោជន៍មិនបានស្មើគ្នា ក្នុងចំណោមវិស័យ និងផ្នែកឧស្សាហកម្មផ្សេងៗ ។ម្យ៉ាងទៀត នៅពេលមានការកាត់បន្ថយ រឺលុបបំបាត់ពន្ធគយលើទំនិញពាណិជ្ជកម្ម ប្រហែលជាមានការប្រកួតប្រជែងកាន់តែខ្លាំងជាមួយទំនិញនាំចូលពីចិន ។ ផលិតករក្នុងស្រុកដែលពុំមានកំលាំងប្រកួតប្រជែងគ្រប់គ្រាន់ ជាពិសេសខាងចំណាយផលិតកម្ម និងគុណភាពផលិតផលអាចនឹងដួលរលំដោយសារការនាំចូលនេះ ។ ការដួលរលំផលិតករក្នុងស្រុកខ្សោយៗ អាចបង្កការខាតបង់ក្នុងរយៈពេលខ្លីដោយសារការបាត់បង់ការងារ ការបាត់បង់ចំណូល និងធ្លាក់ចូលក្នុងភាពក្រីក្រ ។

បញ្ហាប្រឈមផ្សេងទៀតពាក់ព័ន្ធនឹងកិច្ចព្រមព្រៀងក្របខ័ណ្ឌ គឺមានការបាត់បង់ចំនូលរដ្ឋាភិបាល និងឱនភាពពាណិជ្ជកម្មកាន់តែធំជាមួយចិន ដោយសារការកាត់បន្ថយពន្ធគយ ដែលអាចធ្វើឱ្យគោលនយោបាយសារពើពន្ធរបស់រដ្ឋាភិបាលកាន់តែគ្មានស្ថិរភាព និងសុវត្ថិភាព ។

### *ផលប៉ះពាល់មួយចំនួនលើភាពក្រីក្រ*

ក្នុងលក្ខណៈជាប្រទេសក្រីក្រជាងគេមួយនៅក្នុងអាស៊ាន កម្ពុជា ចាត់ទុកកិច្ចព្រមព្រៀងនេះជាឱកាសល្អ ដើម្បីជំរុញកំនើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្រ ។ ដូចបានបញ្ជាក់ហើយ សេរីភាវូបនីយកម្មពាណិជ្ជកម្មនៅក្នុងកិច្ចព្រមព្រៀងនេះ នឹងបង្កើតទាំងឱកាសសេដ្ឋកិច្ច និងបញ្ហាប្រឈម ហើយរំពឹងថាមានផលប៉ះពាល់ទាំងវិជ្ជមាន និងអវិជ្ជមានចំពោះជនក្រីក្រ ។ អត្ថប្រយោជន៍សុទ្ធចំពោះអ្នកក្រ មិនទាន់ដឹងច្បាស់ទេ ព្រោះវាអាស្រ័យថា តើក្របខ័ណ្ឌនយោបាយក្នុងតំបន់ និងក្នុងស្រុកវាអំណោយផលដល់អ្នកក្រីយ៉ាងណា ។ សេរីភាវូបនីយកម្មពាណិជ្ជកម្មនឹងផ្ដល់អត្ថប្រយោជន៍ដល់អ្នកក្រ បើសិនគេតាក់តែងគោលនយោបាយនោះឱ្យមានលក្ខណៈជួយអភិវឌ្ឍទីផ្សារក្នុងស្រុក ដើម្បីឱ្យមានសមត្ថភាពប្រកួតប្រជែងក្នុងតំបន់ និងនៅអន្តរជាតិ ។ ទំហំអត្ថប្រយោជន៍សំរាប់អ្នកក្រជាប់ទាក់ទងផងដែរនឹងកំរិតដែលអ្នកក្រ ជាពិសេសនៅជនបទបាន

*តារាង ៣ : ពាណិជ្ជកម្មកម្ពុជា-ចិន លើផលិតផលក្នុងកម្មវិធីប្រមូលផលឆាប់, ២០០២-០៤ ( គិតជាដុល្លារUS)*

| លេខកូតផលិតផល | | 2002 | 2003 | 2004 |
|---|---|---|---|---|
| ទំនិញនាំចេញ | | | | |
| 030623 | បង្គានិងបង្កង មិនបង្កក មានសំបក រឺបកសំបក ក្នុងនេះគឺមានរបស់ស្ងោរទាំងសំបកផង | 176, 000 | 373,000 | 725,000 |
| 030199 | ត្រីរស់ | 1,063,000 | 683,000 | 520,000 |
| 010600 | សត្វរស់ | 317,000 | 64,000 | 40,000 |
| 030629 | ក្ដាមខ្យង មិនបង្កក មានសំបក រឺបកសំបក ក្នុងនេះគឺមានរបស់ស្ងោរទាំងសំបកផង | 1,000 | 18,000 | 37,000 |
| ទំនិញនាំចូល | | | | |
| 070320 | ខ្ទឹមស ស្រស់ រឺដាក់ទឹកកក | 79,000 | 526,000 | 720,000 |
| 080810 | | | | |
| ផ្លែប៉ោមស្រស់ | 32,000 | 48,000 | 287,000 | |
| 071230 | ផ្សិតក្រៀមប៉ុន្តែគ្មានកែច្នៃបន្ថែម | 0 | 42,000 | 279,000 |
| 080820 | ផ្លែព័រស្រស់ | 29,000 | 5,000 | 130,000 |
| 071332 | សណ្ដែកក្រហមគ្រាប់តូច (Adzuki) ស្ងួត បកសំបកចេញ កិនបំបែក រឺអត់កិន | 0 | 16,000 | 33,000 |
| 071290 | បន្លែ និងបន្លែចំរុះហាលក្រៀម ប៉ុន្តែគ្មានកែច្នៃបន្ថែម | 222,000 | 81,000 | 3,000 |

ប្រភព : TradeMap (ITC)

ចូលរួមក្នុងសកម្មភាពពាណិជ្ជកម្មសំខាន់ៗ ដូចជា ការផ្គត់ផ្គង់ទំនិញនាំចេញ រឺការចូលបំរើការក្នុងវិស័យនានាដែលប្រកួតប្រជែងគ្នា និងការងារជាប់ទាក់ទិនផ្សេងៗ ។

កម្មវិធីប្រមូលផលឆាប់ ពិតជាមានសារៈសំខាន់ចំពោះកសិកម្មកម្ពុជាជាទូទៅ និងចំពោះកសិករជាពិសេស ។ កសិករកម្ពុជាភាគច្រើនក្រីក្រ ធ្វើផលិតកម្មខ្នាតតូចមានផលិតភាពទាប និងរកចិញ្ចឹមជីវិតដោយលក់ផលិតផលកសិកម្មនៅទីផ្សារក្នុងស្រុក ។ ដោយផ្អែកលើចរិតលក្ខណៈទាំងនេះ អ្នកចរចាកម្ពុជា បានដាក់មុខទំនិញ (ក្នុងតារាងគយ) ២៥០មុខ សំរាប់ធ្វើសេរីភាវូបនីយកម្ម ដោយដកចេញផលិតផលកសិកម្មសំខាន់ៗ ៣០មុខ ដូចជា ប៉េងប៉ោះ ខ្ទឹមបារាំង ខ្ទឹមស ផ្កាស្ពៃ ស្ពៃក្ដោប សាឡាត់ ការ៉ុត ឆៃថាវ សណ្ដែកដូង ម្នាស់ ត្រប់បែកស្វាយ មង្ឃុត ក្រូចពោធិសាត់ ត្រសក់ស្រូវ ឪឡឹក និងម្ទេស ។ តាមការដកចេញនេះ កសិករកម្ពុជាអាចចៀសផុតពីការខាតបង់ ដោយសារទំនិញនាំចូល ។ ក្រៅពីការគំរាមកំហែងតិចតួចបំផុតនេះ កម្មវិធីប្រមូលផលឆាប់ហាក់ដូចអំណោយផលដល់កសិករ ដោយផ្ដល់នូវឱកាសនាំចេញ ។ កម្ពុជានឹងបានចំណេញពីកំណើនការនាំចេញផលិតផល ដូចជា ត្រីរស់ សត្វរស់ បង្គា បង្កង សណ្ដែកសៀងនិងពោត ។ គោលនយោបាយ រឺអន្តរាគមន៍រដ្ឋាភិបាល ដែលសំដៅជំរុញផលិតកម្មសំរាប់បំរើការនាំចេញ នឹងជួយយ៉ាងច្រើនដល់ជនក្រីក្រឱ្យបង្កើនចំណូលរបស់ខ្លួន ។

## សេចក្ដីសន្និដ្ឋាន

ទោះបីកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន ផ្ដល់ឱកាសល្អសំរាប់កំនើនសេដ្ឋកិច្ច និងការអភិវឌ្ឍន៍កម្ពុជាក្ដី ប៉ុន្តែអត្ថប្រយោជន៍នានាមិនអាចទទួលបានពេញលេញទេ បើសិនគ្មានក្របខ័ណ្ឌគោលនយោបាយក្នុងស្រុកល្អ បរិយាកាសពាណិជ្ជកម្មអំណោយផល និងស្ថាប័នរដ្ឋមានប្រសិទ្ធភាពខ្ពស់នោះទេ[៥] ។ គឺបានន័យថា សហគ្រិនមិន អាចទទួលបានអត្ថប្រយោជន៍ពីឱកាសថ្មីៗដែលកើតមានតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីទេ បើសិនគ្មានស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច បរិយាកាសពាណិជ្ជកម្មអំណោយផល ក្របខ័ណ្ឌច្បាប់សមស្រប ហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់ និងស្ថាប័នរដ្ឋមានប្រសិទ្ធភាព ។ កន្លងមកកម្ពុជាអាចរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចបានល្អ ប៉ុន្តែនៅខ្វះយន្តការសំខាន់ៗមួយចំនួនសំរាប់កសាងច្បាប់និងជំរុញការអនុវត្តន៍ច្បាប់ ខ្វះហេដ្ឋារចនាសម្ព័ន្ធខាងសេដ្ឋកិច្ច-សង្គមកិច្ច ហើយសេវាកម្មរដ្ឋ និងស្ថាប័នរដ្ឋនៅមានប្រសិទ្ធភាពទាបនៅឡើយ ។ ជាលទ្ធផល វិនិយោគិនយល់ឃើញថា បរិយាកាសពាណិជ្ជកម្ម និងវិនិយោគ មិនអំណោយផលដល់ការបង្កើនសមត្ថភាពប្រកួតប្រជែងទេ ។

យោងតាមទិសដៅ និងឱកាសល្អនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន-ចិន, ប្រទេសកម្ពុជាគួរចាត់ទុកកិច្ចព្រមព្រៀងជាយានមួយមានសក្ដានុពលសំរាប់កំនើនសេដ្ឋកិច្ចការអភិវឌ្ឍន៍ និងការកាត់បន្ថយភាពក្រីក្រ ។ គេគួរកសាងសមត្ថភាពផ្គត់ផ្គង់ និងកែលំអបរិយាកាសប្រកួតប្រជែងរបស់សហគ្រាស ដើម្បីឱ្យកម្ពុជាអាចប្រើប្រាស់ប្រព័ន្ធសេរីភាវូបនីយកម្មមាននៅក្នុងកិច្ចព្រមព្រៀងអាស៊ាន-ចិននេះ ។ សំរាប់ការកាត់បន្ថយភាពក្រីក្រ គួរមានគោលនយោបាយដែលជួយទ្រទ្រង់ដល់អ្នកក្រឱ្យចូលរួមក្នុងដំណើរការសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងការរីកចំរើន ។ ត្រូវដាក់អនុវត្តវិធានការកែតំរូវមួយចំនួន ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមានជាសក្ដានុពលលើអ្នកក្រ ។ ជោគជ័យនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីពឹងផ្អែកយ៉ាងខ្លាំងលើការប្ដេជ្ញាចិត្ត និងសមត្ថភាពរបស់រដ្ឋាភិបាល ដើម្បីបំពេញលក្ខខណ្ឌពីដំបូងទាំងនេះ ។

## កំណត់សំគាល់

១. អាស៊ាន៦ រួមមាន ប្រ៊ុយណេ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ ។

២. ប្រទេសអាស៊ានថ្មី ទទួលបានពេលវេលាច្រើនជាងសំរាប់ធ្វើសេរីភាវូបនីយកម្មដោយសារសេដ្ឋកិច្ចពួកគេមានកំរិតអភិវឌ្ឍន៍ទាប ។ ការផ្ដល់លក្ខខណ្ឌពិសេសលើសគេបែបនេះ សំដៅផ្ដល់ឱ្យប្រទេសអាស៊ានថ្មីអាចបត់បែនបាន និងមានពេលវេលាគ្រប់គ្រាន់សំរាប់ធ្វើកំណែទំរង់ក្នុងស្រុក ។

៣. កម្ពុជា ឡាវ ភូមា និងវៀតណាម

៤. ផ្លូវស្មុគស្មាញមានគោលដៅផ្ដល់ឱ្យសាមីប្រទេសនូវពេលវេលាបន្ថែម ដើម្បីធ្វើឱ្យផលិតផល រឺ វិស័យសំខាន់ៗ មានលក្ខណៈប្រកួតប្រកួតប្រជែងគ្រប់គ្រាន់សំរាប់សេរីភាវូបនីយកម្ម និងដើម្បីចាត់វិធានការកែតំរូវសំដៅកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន ។

៥. World Bank, 2005, Trade Note: Regional Trade Agreement and Development: Upside Potential and Downside Risks, October 2005.

## ឯកសារយោង


_____ (2002), *Framework Agreement on Comprehensive Economic Cooperation Between The Association of South East Asian Nations and The People's Republic of China*

ASEAN-China Expert Group on Economic Cooperation (2001), *Forging Closer ASEAN-China Economic Relations in the Twenty-First Century*

Bernardino, Natividad Y. (2004), *The ASEAN-China Free Trade Area: Issues and Prospects* (Manila: International Gender & Trade Network)

Cordenillo, Raul L. (2005), *The Economic Benefits of the ASEAN-China Free Trade Area (ACFTA)* (Jakarta: ASEAN Secretariat)

HING Vutha & Nou Keosothea, (forthcoming), *The Early Harvest Programme: Implications for Cambodian Agriculture*

Wong, John & Sarah Chan (2002), "China-ASEAN Free Trade Arrangement: Opportunities and Challenges", paper presented at the International Seminar on China-ASEAN Trade, Investment and Development Cooperation held in Kunming, China, in September 2002

# រចនាសម្ព័ន្ធសមាគមកសិករនៅកម្ពុជា

*លោក នូ កែវសុធា ជាអ្នកស្រាវជ្រាវនៅ វបសអ បានរកឃើញបញ្ហាចំបងៗមួយចំនួនដែលអង្គការកសិករនៅកម្ពុជា ត្រូវប្រឈមមុខ បានពិនិត្យពីទ្រង់ទ្រាយអង្គការកសិករនានា និងបានបង្ហាញពីយុទ្ធសាស្ត្រជាក់ស្តែងផ្សេងៗសំរាប់បង្កើតឥណទានមានការប្រាក់ទាប និងការលើកទឹកចិត្តរបស់រដ្ឋាភិបាលជួយដល់អង្គការកសិករ ។**

នៅកម្ពុជា គោលគំនិត និងការប្រើប្រាស់សហករណ៍កសិករជាឧបករណ៍សំរាប់អភិវឌ្ឍន៍កសិកម្ម និងកាត់បន្ថយភាពក្រីក្រ មានប្រវត្តិដ៏វែង និងប្រែប្រួលចុះឡើង ។ សព្វថ្ងៃប្រជាជនជៀសវាងប្រើពាក្យ *សហករណ៍* ពីព្រោះនៅសម័យប៉ុលពត វាសំដៅដល់ការធ្វើពលកម្មជាសមូហភាពដោយបង្ខំ ។ តាមពិត គោលការណ៍សហករណ៍ រួមមាន ការស្ម័គ្រចិត្ត និងភាពជាសមាជិកតាមបែបប្រជាធិបតេយ្យ ។ការបង្កើតសហករណ៍កសិករ ដើម្បីបង្កើនអំណាចតថ្លៃរបស់ម្ចាស់ដីតូចៗ និងបង្កើតទុនខាងសង្គមកិច្ចចាំបាច់សំរាប់ការអភិវឌ្ឍន៍ជនបទ បានទទួលការគ្រាំទ្រពីអង្គការអភិវឌ្ឍន៍អន្តរជាតិជាច្រើន(Marlo et al., 2004) ។បច្ចុប្បន្ន រដ្ឋាភិបាលកម្ពុជាប្រើពាក្យ *សមាគម*ជំនួសពាក្យ *សហករណ៍*វិញ ។ ក្នុងយុទ្ធសាស្ត្រចតុកោណ រដ្ឋាភិបាលកម្ពុជាបានទទួលស្គាល់កសិកម្មជាវិស័យនាំមុខគេដើម្បីរុញកំនើនសេដ្ឋកិច្ចនិងកាត់បន្ថយភាពក្រីក្រនៅជនបទ ។ គោលការណ៍៤សំខាន់ៗនៃយុទ្ធសាស្ត្រនេះគឺៈ ១) ធ្វើផលិតកម្មស្របតាមស្ថានភាពបរិស្ថាន ដើម្បីបំពេញតំរូវការទីផ្សារ, ២) សំរបសំរួល និងផ្តល់ការលើកទឹកចិត្តដល់ផលិតករ ដូចជា ម៉ាឃីតទីង ឥណទាន បច្ចេកវិទ្យា និងពូជធារ ៣) ជួយពង្រឹងការគ្រប់គ្រង និងសមត្ថភាពធនធានមនុស្ស និង ៤) ជួយសំរួលការបង្កើតសហករណ៍កសិករ ដើម្បីធានាថ្លៃផលិតផល[១] ។

សព្វថ្ងៃនៅកម្ពុជា ការអភិវឌ្ឍន៍សហករណ៍កសិករកំពុងស្ថិតក្នុងដំណាក់កាលដំបូងនៅឡើយ ។ ដល់ត្រឹមចុងឆ្នាំ២០០៥ មានតែ ៥៤សហករណ៍កសិករប៉ុណ្ណោះដែលបានចុះបញ្ជីនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់និងនេសាទ ។ ប៉ុន្តែរបៀបរបបកសិករធ្វើការរួមគ្នាជាសហមូហភាព មិនមែនជារឿងថ្មីទេនៅកម្ពុជា ។ សមូហភាពបែបនេះហៅថា អង្គការកសិករ (FOs) ។

ការអភិវឌ្ឍន៍កសិកម្មកម្ពុជានៅមានបញ្ហាប្រឈមធំៗជាច្រើន ដូចជា ហេដ្ឋារចនាសម្ព័ន្ធអន់ខ្សោយ ប្រព័ន្ធម៉ាឃីតទីងគ្មានប្រសិទ្ធភាព កង្វះបច្ចេកវិទ្យាអាចថ្ងៃប្រើប្រាស់បាន កង្វះសេវាផ្សព្វផ្សាយបច្ចេកទេស កង្វះកន្លែងកែច្នៃកសិផល និងកង្វះរចនាសម្ព័ន្ធហិរញ្ញវត្ថុនៅជនបទ ។ កសិករម្នាក់ៗមិនអាចដោះស្រាយបញ្ហាទាំងនេះដោយខ្លួនឯងទេ ប៉ុន្តែការសិក្សាលើ ២-៣ ករណីមានជោគជ័យ បានបង្ហាញថា កសិករអាចធ្វើការរួមគ្នាដោះស្រាយបញ្ហាបានខ្លះដែរ ។ អត្ថបទនេះបំផុសឱ្យឃើញបញ្ហាចំបងខ្លះៗដែលអង្គការកសិករនៅកម្ពុជាត្រូវប្រឈមមុខ, ពិនិត្យពីចំនួនអង្គការកសិករ, និងបង្ហាញពីបទពិសោធន៍អនុវត្តយុទ្ធសាស្ត្រដ៏ជាក់លាក់ ដើម្បីទទួលបានឥណទានមានការប្រាក់ទាប និងការលើកទឹកចិត្តដែលរដ្ឋាភិបាលផ្តល់ឱ្យអង្គការកសិករ ។

## ហេតុអ្វីបានជាបង្កើតសមាគមកសិកម្ម?

គុណតំលៃស្នូលនៃសហករណ៍កសិករ គឺជួយខ្លួនឯង ទទួលខុសត្រូវចំពោះខ្លួនឯង ប្រជាធិបតេយ្យ សមភាព សមធម៌និងសាមគ្គីភាព សំរាប់ឱ្យប្រជាជនជនបទរួបរួមគ្នាដោះស្រាយបញ្ហាតាមរយៈសកម្មភាពជាសមូហភាព ។ មានការឯកភាពជាទូទៅថា ដើម្បីមានចីរភាព សមាគម រឺសហករណ៍ត្រូវមានជោគជ័យខាងសេដ្ឋកិច្ច ដោយអាចប្រកួតប្រជែងជាមួយសហករណ៍ឯទៀត និងវិស័យឯកជន ។ សហករណ៍ត្រូវផ្តល់ឱ្យអតិថិជន និងសមាជិកខ្លួននូវសេវាកម្ម និងផលិតផលមានថ្លៃប្រកួតប្រជែង ។ ទំនាក់ទំនងរវាងសមាជិក និងសហករណ៍ខុសគេទាំងអស់ ពីព្រោះសមាជិកគឺជាអ្នកកាន់ភាគហ៊ុន រឺសហកម្មសិទ្ធិករនៃសហករណ៍ និងជាអតិថិជនចំបងទិញសេវាកម្មដែលមាន ផ្តល់ ។ ដូច្នេះ ការចូលរួមរបស់សមាជិក មានលក្ខណៈចាំបាច់សំរាប់គ្រប់ការងារសហករណ៍ (អាជីវកម្ម, ហិរញ្ញវត្ថុ, គ្រប់គ្រង និងសង្គមកិច្ច) (Couture et al., 2002) ។

កម្ពុជា ដែលបច្ចុប្បន្នជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) មានសេដ្ឋកិច្ចបែបទីផ្សារសេរី ។ កម្ពុជាស្ថិតនៅចន្លោះប្រទេសកសិកម្មធំៗ២ គឺ ថៃ និងវៀតណាម ដែលធ្វើការប្រកួតប្រជែងនៅគ្រប់កំរិតទីផ្សារ ។កសិករកម្ពុជាប្រឈមមុខនឹងកំហិតខាងផលិតកម្ម និងម៉ាឃីទីងជាច្រើន ។ ដូច្នេះ សហករណ៍កសិករសំខាន់ណាស់ ដើម្បីជួយគ្រប់គ្រងការផ្លាស់ប្តូរក្នុងបរិស្ថាន និងដោះស្រាយតំរូវការរបស់កសិករ នៅពេលកសិករម្នាក់ៗមិនអាចប្រកួតប្រជែងបាន ។ សហករណ៍ក៏ជាច្រកឱ្យអង្គការអភិវឌ្ឍន៍នានា អាចចូលដល់ និងធ្វើការជាមួយកសិករដែរ ។ សកម្មភាពសហមូហភាពតាមរយៈអង្គការកសិករ ជួយកាត់បន្ថយចំនាយប្រតិបត្តិការ និងបង្កើតវិធានគ្រប់គ្រងទីផ្សារ ។ ម្យ៉ាងទៀតកសិករចង់ឱ្យសហករណ៍កសិករ ជួយផ្តល់សន្តិសុខក្នុងការលក់ផលិតផលទទួលបានថ្លៃល្អសំរាប់ធាតុចូល/ផលិតផល ទទួលបានជំនួយបច្ចេកទេស និងកាត់បន្ថយចំនាយតាមរយៈការចែករំលែកគ្នាប្រើម៉ាស៊ីនឧបករណ៍កែច្នៃ និងកន្លែងស្តុក ។

តួនាទីចំបងនៃអង្គការកសិករ គឺផ្តល់សេវាបច្ចេកទេស/ហិរញ្ញវត្ថុ ទៅឱ្យសមាជិក, តំណាងផលប្រយោជន៍របស់សមាជិក, និងធ្វើវិនិយោគខាងសង្គមកិច្ច ។ សេវាបច្ចេកទេស/ហិរញ្ញវត្ថុ មានប្រជាប្រិយភាពណាស់ ជាពិសេសក្នុងចំណោមកសិករក្រីក្រ ។

## ស្ថានភាពបច្ចុប្បន្ននៃអង្គការកសិករ

អង្គការកសិករកម្ពុជា កំពុងស្ថិតក្នុងដំណាក់កាលដំបូងនៃការអភិវឌ្ឍន៍ ដោយទទួលបានការគ្រាំទ្រពីរដ្ឋាភិបាល និង NGOs ។ អង្គការកសិករមានច្រើនបែបយ៉ាងខុសៗគ្នាទាំងដើមកំណើត សមាជិក មុខងារ ទំហំ ទំនាក់ទំនងជាមួយស្ថាប័នគាំទ្រ ហើយភាគច្រើនតូចៗណាស់ មានមុខងារតែមួយ កកើតក្នុងមូលដ្ឋាន មិនបានចុះបញ្ជីតាមច្បាប់ មានថ្នាក់គ្រប់គ្រង/ដឹកនាំគ្មានការបណ្តុះបណ្តាលត្រឹមត្រូវ និងមានបញ្ហាចោទក្នុងការទទួលបានសេវាកម្មពីរដ្ឋ រឺស្ថាប័នមីក្រូហិរញ្ញវត្ថុ ។ ថ្វីបើអង្គការកសិករស្ទើរទាំងអស់ត្រូវបានទ្រទ្រង់ដោយNGOs រឺរដ្ឋាភិបាល តែមានមួយចំនួនបង្កើតឡើងដោយក្រុមហ៊ុនឯកជនដូចជាក្រុមហ៊ុនថ្នាំជក់ BAT (ចុះកិច្ចសន្យាជាមួយកសិករ ៣.០០០នាក់[២] នៅកំពង់ចាម) និង ស៊ីភីគ្រុប ជាដើម ។

សារៈតា និងគោលដៅរបស់អង្គការកសិករប្រែប្រួលខុសគ្នាទៅតាមទីតាំង និងផលប្រយោជន៍របស់កសិករជាសមាជិក ។ តាមការស្រង់ចំនួននៅ

* អត្ថបទនេះ ផ្អែកលើគំរោងស្រាវជ្រាវសកម្មមួយឈ្មោះថា "ការកែលំអប្រព័ន្ធម៉ាឃីទីងសំរាប់ពោត និងសណ្តែកសៀងនៅកម្ពុជា" ផ្តល់ទុនដោយមជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការសិក្សាពីកសិកម្មអន្តរជាតិ (ACIAR) ។

ឆ្នាំ១៩៩៩ (Julie et al., 2005) គឺមាន ១.០៦៥ អង្គការកសិករនៅកម្ពុជា ដែលកើនដល់ ១៣.០១៧ នៅឆ្នាំ២០០៥ ។ ខេត្តមានអង្គការកសិករច្រើនជាងគេ គឺកំពង់ចាម កំពង់ធំ បន្ទាយមានជ័យ ស្វាយរៀង និងកំពង់ស្ពឺ ។ អង្គការកសិករ ៦៩%មានសមាជិកតិចជាង ៣០នាក់, ១៩% មាន ៣០-១០០នាក់ និង ១២% មានច្រើនជាង ១០០នាក់ ( ក្រាហ្វិក១) ។ការសិក្សាបង្ហាញទៀតថា អង្គការកសិករ ៦៣% បានកើតឡើងនៅក្រោយឆ្នាំ២០០០ ។

Julie et al., 2005 បានចាត់ថ្នាក់អង្គការកសិករជា ៥ប្រភេទ: ក្រុមកសិករ សមាគម សហគមន៍ សហករណ៍ និងសហព័ន្ធ ។ តារាង១ បង្ហាញច្បាស់ថា អង្គការកសិករភាគច្រើនជាក្រុមកសិករ ។

ក្រាហ្វិក ១. ទំហំសមាជិក FOs




ប្រភព: Julie et al., (2005)

## ក្របខ័ណ្ឌច្បាប់សំរាប់ទ្រទ្រង់អង្គការកសិករ

រដ្ឋាភិបាលកម្ពុជាមានក្របខ័ណ្ឌច្បាប់មួយចំនួនហើយ សំរាប់ជួយជំរុញសហករណ៍កសិករ ។បច្ចុប្បន្នមានក្របខ័ណ្ឌច្បាប់គ្រប់គ្រាន់សំរាប់ទ្រទ្រង់ អង្គការកសិករ ប៉ុន្តែសំរាប់សហគមន៍នេសាទ និងសមាគមអ្នកថែទាំសុខភាពសត្វក្នុងភូមិ ច្បាប់សំខាន់ៗមួយចំនួនមិនទាន់អនុម័តទេ ។សព្វថ្ងៃអង្គការកសិករនិងស្ថាប័នជួយទ្រទ្រង់ភាគច្រើន មានការយល់ដឹងតិចតួចនៅឡើយពីក្របខ័ណ្ឌច្បាប់ដែលគ្រប់គ្រងសកម្មភាពរបស់ពួកគេ ។

ក្របខ័ណ្ឌច្បាប់ដែលរដ្ឋាភិបាល បានបង្កើតដើម្បីជួយទ្រទ្រង់អង្គការកសិករមានដូចតទៅ:

### សហករណ៍កសិករ

ក្របខ័ណ្ឌច្បាប់នេះ ស្ថិតក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានផ្សព្វផ្សាយកសិកម្មនៃក្រសួងកសិកម្ម និងមានជាអាទិ៍ ព្រះរាជក្រឹត្យ នស/រកត/០៧០១/២៣៤ ស្តីពីការបង្កើត និងការប្រព្រឹត្តទៅនៃសហគមន៍អភិវឌ្ឍន៍កសិកម្ម សហភាពសហគមន៍អភិវឌ្ឍន៍កសិកម្ម និងបុរេសហគមន៍អភិវឌ្ឍន៍កសិកម្ម, និងប្រកាសផ្សព្វផ្សាយគំរូលក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់សហករណ៍កសិករឆ្នាំ២០០៣ ។ មន្ទីរកសិកម្មខេត្ត អាចចុះបញ្ជីសហករណ៍ជាផ្លូវការបាន ។ ក្នុងច្បាប់ទាំងនេះ សហករណ៍កសិករ គឺជា "សហគ្រាសសេដ្ឋកិច្ច ដែលគ្រប់គ្រងតាមបែបប្រជាធិតេយ្យដោយសមាជិករបស់ខ្លួន ដែលបានរួមចំនែកក្នុងដើមទុននិងសង្ឃឹមលើផលព្រមទាំងសុខចិត្តទទួលគ្រោះខាតបង់ស្របតាមសមាមាត្ររបស់ភាគហ៊ុនដែលបានចូលរួម" ។

### សមាគមកសិករ

ក្របខ័ណ្ឌច្បាប់ និងដំណើរការចុះបញ្ជីសមាគមកសិករ ស្ថិតក្រោមការគ្រប់គ្រងរបស់អគ្គនាយកដ្ឋានរដ្ឋបាល នៃក្រសួងមហាផ្ទៃ ។ទំរង់ចុះបញ្ជី និងច្បាប់រួមមាន: ទំរង់ចុះបញ្ជីសំរាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុកនៅក្រោមឱវាទក្រសួងមហាផ្ទៃ, សេចក្តីព្រៀងច្បាប់ស្តីពីសមាគមក្នុងស្រុកនិងអង្គការមិនមែនរដ្ឋាភិបាលឆ្នាំ១៩៩៦ ។ ឯកសារទាំងនេះផ្តល់ក្របខ័ណ្ឌច្បាប់ទូទៅមួយសំរាប់អង្គការគ្រប់វិស័យ មិនមែនតែអង្គការកសិករមួយមុខទេ ។ ក្នុងឯកសារទាំងនេះ សមាគមសំដៅដល់ក្រុមបុគ្គលរូបវន្តរៀបចំឡើងដោយប្រជាពលរដ្ឋខ្មែរ ដើម្បីស្វែងរកគោលដៅរួមគ្នាមួយក្នុងការបំរើផលប្រយោជន៍ខាងស្មារតី និងសំភារៈរបស់សមាជិកសមាគមដោយមិនស្វែងរកផលចំណេញជាឯកជន ។

តារាង ១: ចំនួនអង្គការកសិករគិតតាមប្រភេទ

| អង្គការកសិករ | ចំនួន | ភាគរយ |
|---|---|---|
| ក្រុមកសិករ | 10,487 | 80.5 |
| សហគមន៍កសិករ | 1,769 | 13.6 |
| សមាគមកសិករ | 662 | 5.0 |
| សហករណ៍កសិករ | 93 | 0.7 |
| សហព័ន្ធកសិករ | 6 | 0.05 |
| សរុប | 13,017 | |

ប្រភព: Julie et al., (2005)

### សមាគមអ្នកថែទាំសុខភាពសត្វក្នុងភូមិ

ក្របខ័ណ្ឌច្បាប់ ស្ថិតក្រោមការគ្រប់គ្រងពីនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មនៃក្រសួងកសិកម្ម ។ ក្នុងឯកសារព្រាងស្តីពីសមាគមអ្នកថែទាំសុខភាពសត្វក្នុងភូមិ សមាគមបសុពេទ្យ និងអ្នកថែទាំសុខភាពសត្វកម្ពុជា គឺជាក្រុមហ៊ុនមួយស្ថិតក្រោមច្បាប់ក្រុមហ៊ុនឯកជនដែលកំនត់ថា សមាជិកម្នាក់ៗរបស់សមាគម ត្រូវតែជាបុគ្គលបានចុះបញ្ជីស្របតាម ប្រកាសស្តីពីការបង្កើតក្រុមអ្នកថែទាំសុខភាពសត្វក្នុងភូមិ (២០០៣) និង អនុក្រឹត្យស្តីពីការបង្កើតក្រុមអ្នកថែទាំសុខភាពសត្វក្នុងភូមិ (២០០០) ។

### សហគមន៍នេសាទ

ក្របខ័ណ្ឌច្បាប់ស្ថិតក្រោមការគ្រប់គ្រងពីនាយកដ្ឋានជលផលនៃក្រសួងកសិកម្ម យោងតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងសហគមន៍នេសាទឆ្នាំ២០០៥ (សេចក្តីព្រាង) ។នៅក្នុងច្បាប់នេះ សហគមន៍នេសាទ គឺជាក្រុមបង្កើតឡើងដោយស្ម័គ្រចិត្តនូវបុគ្គលមានសញ្ជាតិខ្មែរជាអ្នករស់នៅក្នុង រឺនៅជិតតំបន់នេសាទ ដែលបានផ្តួចផ្តើមគំនិតលើកកំពស់ជីវភាពរបស់ខ្លួន តាមរយៈការប្រើប្រាស់ និងកែច្នៃ ធនធានជលផលដើម្បីរួមចំនែកជំរុញសេដ្ឋកិច្ច សង្គម និងកាត់បន្ថយភាពក្រីក្រ ។

### សហគមន៍ព្រៃឈើ

ក្របខ័ណ្ឌច្បាប់ស្ថិតក្រោមការគ្រប់គ្រងពី រដ្ឋបាលព្រៃឈើនៃក្រសួងកសិកម្ម យោងតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងព្រៃសហគមន៍ ខែកញ្ញា ឆ្នាំ២០០៣ ។ ក្នុងអនុក្រឹត្យនេះ សហគមន៍ព្រៃឈើ គឺជាសហគមន៍ដែលផ្តួចផ្តើមគំនិតបង្កើតក្រុមដោយស្ម័គ្រចិត្តស្របតាមកិច្ចព្រមព្រៀងព្រៃសហគមន៍ ដើម្បីធ្វើសកម្មភាពអភិវឌ្ឍន៍ផ្សេងៗ ។

## សហគមន៍កសិករអ្នកប្រើប្រាស់ទឹក

ក្របខ័ណ្ឌច្បាប់ និងការទទួលស្គាល់សហគមន៍កសិករអ្នកប្រើប្រាស់ទឹក ស្ថិតក្រោមការគ្រប់គ្រងពីនាយកដ្ឋាន កសិកម្មស្រោចស្រព នៃក្រសួងធនធានទឹក និងឧតុនិយម យោងតាមសារាចរលេខ១ របស់នាយករដ្ឋមន្ត្រីស្តីពីការអនុវត្តន៍គោលនយោបាយធារាសាស្ត្រមានចីរភាពឆ្នាំ១៩៩៩, ប្រកាសលេខ ៣០៦ ឧបសម្ព័ន្ធ ២ និងសេចក្តីព្រាងអនុក្រឹត្យស្តីពីសហគមន៍កសិករអ្នកប្រើប្រាស់ទឹក ។ ក្នុងឯកសារទាំងនេះ សហគមន៍កសិករ អ្នកប្រើប្រាស់ទឹក គឺជាសមាគមផ្លូវការ និងស្របច្បាប់នៃអ្នកដែលប្រើប្រាស់ទឹកបានពីប្រព័ន្ធធារាសាស្ត្រ និងគ្រប់គ្រងលើប្រព័ន្ធធារាសាស្ត្រ ។

## ករណីសិក្សាលើសមាគមសណ្តែកសៀង តាអុង

នៅកម្ពុជា ខេត្តកំពង់ចាមគឺជាតំបន់សំខាន់សំរាប់ការដាំសណ្តែកសៀង ។ នៅឆ្នាំ២០០៥ ខេត្តនេះផលិតបាន ប្រហែល៤៨% នៃផលសណ្តែកសៀងសរុបនៅកម្ពុជា ។ ប្រហែល ៩០% នៃផលិតផលនេះ ត្រូវបាននាំចេញ ហើយភាគច្រើនទៅវៀតណាមភាគខាងត្បូង ។ នៅខេត្តកំពង់ចាម ចំការលើជាស្រុកដែលផលិតសណ្តែកសៀង បានច្រើនជាងគេដល់ ២៣.០០០តោន នៅឆ្នាំ២០០៥ ធៀបនឹង ៥៧.៦០០តោនក្នុងខេត្តទាំងមូល ។

សមាគមអភិវឌ្ឍន៍សណ្តែកសៀង តាអុង (TSA) បង្កើតឡើងនៅឆ្នាំ ២០០១ ដោយសារមានគោលនយោបាយរដ្ឋាភិបាលគាំទ្រដល់សហករណ៍ រឺសមាគមកសិករ ។ គ្រឿងលើកទឹកចិត្តសំខាន់ទាក់ទាញកសិករឱ្យចូលរួមក្នុងសមាគមតាអុង គឺលទ្ធភាពទទួលបានឥណទានមានការប្រាក់ទាបតាមរយៈសមាគម ។ ចំណាយខ្ពស់លើឥណទាន អាចជាឧបសគ្គធំបំផុតចំពោះកសិករដែលចង់អភិវឌ្ឍន៍ផលិតកម្មសណ្តែកសៀង ។មានកសិករតិចនាក់ណាស់ដែលអាចទិញពូជ ជី និងធាតុចូលផ្សេងទៀតដោយគ្មានឥណទាន ។ កសិករជាង ៨០% អាចទទួលបានឥណទានបែបនេះពីអ្នកប្រមូលទិញតាមភូមិក្នុងអត្រាការប្រាក់ពី ៣-៥%/ខែដោយមានលក្ខខណ្ឌឱ្យកសិករលក់ផលិតផលទៅឱ្យម្ចាស់បំណុលនៅពេលប្រមូលផលដែលតាមធម្មតាគឺជាពេលផលដំណាំចុះថ្លៃទាបបំផុត ។

ដើមឡើយ កសិករផុសផុលជាខ្លាំងចង់ចូលសមាគមតាអុង ហើយសមាជិកដំបូងមានដល់ប្រហែល ៥០នាក់ ។ ប៉ុន្តែលក្ខន្តិកៈសមាគមតាអុងតាក់តែងមិនបានល្អ ជាពិសេសតួនាទីជួយទ្រទ្រង់របស់សមាគមមិនបានកំនត់ច្បាស់ទេ ។ សមាជិកសមាគមតាអុង ចាប់ផ្តើមថយចុះនៅពេលសមាគមមិនអាចទទួលបានឥណទានមានការប្រាក់ទាប ហើយចុះរហូតដល់ ២០នាក់ នៅដើមឆ្នាំ២០០៥ ។ នៅពេលនោះ សមាគមមានមុខងារមិនច្បាស់លាស់សោះចំពោះពួកសមាជិកដែលនៅសល់ ។

ដូចគ្នានឹងអង្គការកសិករឯទៀតដែរ សមាគមតាអុងជួបកំហិតចំបងៗដូចជាកង្វះឥណទានមានការប្រាក់ទាប ផលិតភាពទាប កង្វះបច្ចេកវិទ្យាសមស្រប ផលិតផលគុណភាពអន់ ការមិនអាចរកទីផ្សារបានល្អ កង្វះសមាហរណកម្មតាមខ្សែបណ្តោយនិងខ្សែទទឹង កំរិតអប់រំទាប កង្វះទឹកចិត្តធ្វើការងារជាសមូហភាព និងការយល់ដឹងតិចតួចពីក្របខ័ណ្ឌច្បាប់ ហើយក្នុងនេះ លទ្ធភាពទទួលបានឥណទានមានការប្រាក់ទាបហាក់ដូចសំខាន់ជាងគេ ។

នៅកម្ពុជាគ្មានធនាគារឯកទេសសំរាប់កសិកម្មទេ ។ អត្រាការប្រាក់របស់ស្ថាប័នមីក្រូហិរញ្ញវត្ថុ (MFI) រឺធនាគារពាណិជ្ជ នៅខ្ពស់ជាខ្លាំង (យ៉ាងតិច ២%/ខែ) និងត្រូវដាក់ទ្រព្យធានាទៀតផង ។ ធានាគារអភិវឌ្ឍន៍ជនបទ (RDB) ដែលជា "អ្នកលក់ដុំ" យកការប្រាក់ ១០%/ឆ្នាំ ប៉ុន្តែតំរូវឱ្យបំពេញលក្ខខណ្ឌច្រើន ជាពិសេសដំណើរការពីរជំហានដំបូងគឺ ទី១ ការចុះឈ្មោះនៅធនាគារជាតិនៃកម្ពុជា (NBC) និង ទី២ ការមានឈ្មោះក្នុងបញ្ជីប្រតិបត្តិករមានសក្តានុពល[៤] ។

ដើម្បីអាចចុះក្នុងបញ្ជីនៅធនាគារជាតិ អង្គការមីក្រូហិរញ្ញវត្ថុត្រូវបំពេញលក្ខខណ្ឌមួយចំនួនៈ ១) កំចីសុទ្ធដែលអង្គការបានផ្តល់ឱ្យអតិថិជន ត្រូវស្មើរឺលើសពី ១.០០០លានរៀល រឺអង្គការត្រូវមានអ្នកខ្ចី ១.០០០នាក់ រឺច្រើនជាងនេះ, ២) សំរាប់អង្គការធ្វើប្រតិបត្តិការទទួលប្រាក់បញ្ញើសន្សំ គឺត្រូវមានប្រាក់បញ្ញើនេះស្មើនឹងរឺលើសពី ១០០លានរៀល រឺមានសមាជិក ១.០០០នាក់ រឺច្រើនជាង ។ នៅឆ្នាំ២០០៥ សមាគមតាអុង អាចប្រមូលប្រាក់សន្សំពីសមាជិកដល់ទៅ ១៦៧លានរៀល ហើយធនាគារជាតិក៏បានចុះឈ្មោះឱ្យក្នុងបញ្ជីអ្នកមានសក្តានុពល នៅខែកក្កដា ២០០៥ ។

ក្រោយបានទទួលបានការអនុមតិពីធនាគារជាតិ សមាគមតាអុងបានដាក់លិខិតស្នើសុំកំចីមានការប្រាក់ទាប ទៅធនាគារអភិវឌ្ឍន៍ជនបទ ដែលបានផ្តល់ឱ្យនូវកំចីសំរាប់ចាប់ផ្តើម ១២០លានរៀល (៣០.០០០ដុល្លារ) ក្នុងអត្រាការប្រាក់ ១០%/ឆ្នាំ សំរាប់រយៈពេល១ឆ្នាំ ។ បន្ទាប់ពីរឿងនេះ សមាជិកសមាគមតាអុង បានកើនដល់ ២០០នាក់ ក្នុងរយៈមិនដល់ ៦ខែផង ហើយសមាគមក៏បានសំរេចចិត្តឈប់ទទួលសមាជិកទៀត ដើម្បីអាចធ្វើការគ្រប់គ្រងមានប្រសិទ្ធភាពល្អ ។

## មេរៀនទទួលបានពីសហករណ៍កសិករ

គេអាចរៀនសូត្របានច្រើនពី "បទពិសោធន៍" កសាងសហករណ៍ដែលកំពុងប្រព្រឹត្តទៅនៅកម្ពុជា ។ ក្នុងករណីសមាគមតាអុង មានជំនួយបច្ចេកទេសយ៉ាងច្រើនពីទីភ្នាក់ងារទ្រទ្រង់ផ្សេងៗ ដើម្បីអាចទទួលបានឥណទានពីធនាគារអភិវឌ្ឍន៍ជនបទ ។ជំនួយបច្ចេកទេសរួមមានកិច្ចប្រជុំជាច្រើនជាមួយសមាជិកសមាគមតាអុងសំខាន់ៗ ការជួយរៀបចំលក្ខន្តិកៈ ការជួយកសាងសមត្ថភាពគណនេយ្យករ និងអ្នកដឹកនាំសំខាន់ៗ, ការផ្តល់ព័ត៌មានឱ្យ និងការជួយរៀបចំសំនុំបែបបទសំរាប់ធនាគារជាតិ និងធនាគារអភិវឌ្ឍន៍ ។ ប៉ុន្តែអង្គការជួយទ្រទ្រង់គ្មានធ្វើការសន្យា រឺធានាពីជោគជ័យឱ្យសមាគមទេ ។ រាល់សេចក្តីសំរេចចិត្តខាងគ្រប់គ្រង និងប្រតិបត្តិការ គឺសមាគមតាអុងត្រូវធ្វើដោយខ្លួនឯង ។

ការពង្រឹងសមត្ថភាពសហករណ៍កសិករ បានជួបឧបសគ្គប្រហាក់ប្រហែលគ្នានឹងក្នុងប្រទេសកំពុងអភិវឌ្ឍន៍ ឯទៀតដែរ (FAO, 1996)ៈ

- រដ្ឋដើរតួជាឪម៉ែគេនៅក្នុងការគ្រប់គ្រងសហករណ៍កសិករ
- សព្វថ្ងៃអ្នកគ្រប់គ្រងសហករណ៍ និងមន្ត្រីរដ្ឋាភិបាលជាច្រើន នៅមានជំហរ បញ្ជាពីលើចុះក្រោម
- សមាជិកខ្វះខាតទុន និងមិនសូវមានអារម្មណ៍ជាម្ចាស់ ។

គេរកឃើញថា កត្តាដែលជំរុញសហករណ៍ឱ្យរីកលូតលាស់ វាពាក់ព័ន្ធទាំងសង្គមនិងបុគ្គល ទិដ្ឋភាពខាងហិរញ្ញវត្ថុនិងសេដ្ឋកិច្ច គោលការណ៍ខាងសហករណ៍និងអភិបាលកិច្ច ព្រមទាំងច្បាប់ គោលនយោបាយ និងក្របខ័ណ្ឌស្ថាប័ន (Couture et al., 2002 and Casaki et al., 1993) ហើយថាមពលលើសបានពីការផ្គុំគ្នារវាងកត្តាទាំងអស់ ត្រូវមានជាចាំបាច់ដើម្បីបង្កើតបរិយាកាសអំណោយផល ។ ដោយអាជ្ញាធរថ្នាក់ជាតិ និងថ្នាក់មូលដ្ឋាន លើកទឹកចិត្តខ្លាំងដល់កសិករឱ្យបង្កើតក្រុមកសិករ និងចុះបញ្ជី ជាសហករណ៍ផ្លូវការ ដូច្នេះបទប្បញ្ញត្តិអំពីការផ្តល់ការលើកទឹកចិត្ត ប្រហែលនឹងដាក់សំពាធទៅលើការ

តទៅទំព័រទី ១៩

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

## កំណើនសេដ្ឋកិច្ចពិភពលោក

នៅត្រីមាសទី៣ ២០០៥ ប្រទេសខ្លាំងៗដូចជា អាមេរិក សហភាពអឺរ៉ុប ជប៉ុន និងប្រទេសអាស៊ីខាងកើត មានកំនើនសេដ្ឋកិច្ចខ្លាំងជាងត្រីមាសមុន ។

ក្នុងរយៈ ១ឆ្នាំដល់ចុងត្រីមាសទី៣ ផសស ពិត របស់ US កើន បាន ៤,១% ។ នៅត្រីមាសទី២ កត្តាសំខាន់ដែលបង្កកំណើនគឺ ចំណាយប្រើប្រាស់ផ្ទាល់ខ្លួន ផលិតកម្មគ្រឿងបរិក្ខារនិងសូហ្វវែរ វិនិយោគលើសំណង់ផ្ទះសំបែង និងចំណាយរបស់រដ្ឋាភិបាលសហព័ន្ធ ។ កំណើននៅត្រីមាសទី៣ បណ្ដាលជាសំខាន់ពីកំនើនចំនាយប្រើប្រាស់ផ្ទាល់ខ្លួន និងចំនាយរដ្ឋាភិបាលសហព័ន្ធ ប៉ុន្ដែវាត្រូវកាត់កង ថយចុះអស់មួយភាគវិញ ដោយសារកំណើនការនាំចូល និងការថយចុះការនាំចេញ ចំណាយរបស់រដ្ឋាភិបាលតាមរដ្ឋ/មូលដ្ឋាន និងវិនិយោគលើសំណង់ផ្ទះសំបែង ។

ផសស ពិត នៅតំបន់អឺរ៉ូ កើន ១,៥%ក្នុងរយៈពេល ១ឆ្នាំ ដល់ចុងត្រីមាសទី៣ និង ០,៦% បើធៀបនឹងត្រីមាសមុន ។ នៅត្រីមាសទី៣ ចំនាយប្រើប្រាស់ចុងក្រោយតាមគ្រួសារកើន ០,៣% វិនិយោគកើន ១,៦% ការនាំចេញកើន ៣,៤ % និងការនាំចូលកើន ២,៨% ។ ផសស ពិត នៅជប៉ុន កើន ២,៩% ក្នុងរយៈ១២ខែ អត្រាខ្ពស់បំផុត (ក្នុង៥ឆ្នាំកន្លងមក) និងកើន០,៨% បើធៀបនឹងត្រីមាសមុន ។ ក្នុងរយៈ ១ឆ្នាំដល់ចុងត្រីមាសទី៣ ផសស ពិត នៅកូរ៉េខាងត្បូង កើន ៤,៤% ធៀប នឹង ៣,៣%នៅត្រីមាសទី២ ។ វិស័យឧស្សាកម្មផលិត កើន ៧% នាំមុខ គេដោយផលិតផល អគ្គិសនីនិងអេឡិចត្រូនិក (មានទាំងផលិតផលពាក់កណ្ដាលចំលងផង) រីឯវិស័យសេវាកម្មកើន ៣,៣% ។

ក្នុងរយៈ១ឆ្នាំដល់ចុងត្រីមាសទី៣ ចិនបន្ដមានកំណើន ផសស ពិតកំរិតខ្ពស់ដល់ ៩,៤% ប៉ុន្ដែចុះទាបជាងត្រីមាសមុនអស់ ០,១% ។ ក្នុងនេះវិស័យឧស្សាហកម្មកើន ១១% ហើយវិស័យ កសិកម្ម-យករ៉ែ និងវិស័យសេវាកម្មកើន ៥% និង ៨% រៀងគ្នា ។ ផសស ពិត នៅហុងកុងមានកំនើន ៨,២% ធៀបនឹងកំនើន ៧,៣% នៅត្រីមាសទី២ ។

ក្នុងរយៈ១ឆ្នាំដល់ចុងត្រីមាស៣ ផសស ពិត នៅម៉ាឡេស៊ី កើន ៥,៣% ធៀបនឹង ៤,៤%នៅត្រីមាសទី២ ។ ឧស្សាហកម្មផលិត និងសេវាកម្មកើន ៣,៤ % និង ៧,៣% រៀងគ្នា រីឯកសិកម្មមាន កំនើនតិចតួចត្រឹម ០,៩% ។ ផសស ពិត នៅសិង្ហបុរី និងថៃ កើន ៧% និង ៥,៣% រៀងគ្នា ធៀបនឹង ៥,៤% និង ៤,៦% ក្នុងរយៈ ១ឆ្នាំដល់ចុងត្រីមាសទី២ ។ កំណើនខ្ពស់នៅថៃបណ្ដាលជាសំខាន់ពី ការស្ទុះកើនការនាំចេញ និងការលូតលាស់វិស័យទេសចរណ៍ ។ វិស័យកសិកម្ម កើន ៤,៤% (ក្រោយពីបានរួមចុះអស់ ៦ត្រីមាសជាប់ៗគ្នា) ដោយសារកំណើនផលិតកម្ម ស្រូវ ពោត សណ្ដែកសៀង ផ្លែឈើ បន្លែ និងប្រេងឆា ។

## អតិផរណាក្នុងពិភពលោក និងអត្រាប្ដូរប្រាក់នៅទីផ្សារអន្ដរជាតិ

នៅត្រីមាសទី៣ ថ្លៃទំនិញប្រើប្រាស់ក្នុងប្រទេសមានចំណូលខ្ពស់មានកំនើនលឿនជាងនៅត្រីមាសមុន ។ កំនើននេះឆ្លុះបញ្ចាំងពីការស្ទុះឡើងថ្លៃប្រេងឥន្ទនៈដែលបានធ្វើឱ្យកើនខ្លាំងនូវចំណាយថាមពល ។ ក្នុងរយៈ ១២ខែថ្លៃទំនិញប្រើប្រាស់កើន ៣,៨% នៅ US និង ២,៣%នៅសហភាពអឺរ៉ុប ។ ពីត្រីមាសទី២ ដល់ត្រីមាសទី៣ អតិផរណានៅសិង្ហបុរីកើនពីកំរិត ០,១% ដល់ ០,៥%, នៅម៉ាឡេស៊ីវាកើនពី ៣,០% ដល់ ៣,៤% និងនៅថៃ កើនពី ៥,៣% ដល់ ៥,៦% ។

នៅត្រីមាសទី៣ ដុល្លារ US ឡើងថ្លៃទល់នឹងរូបិយវត្ថុសំខាន់ៗ ដោយប្ដូរបាន ០,៨១អឺរ៉ូ/ដុល្លារ រឺ ១១១,២យ៉េន/ដុល្លារធៀបនឹង ០,៧៩អឺរ៉ូ/ដុល្លារ និង ១០៧,៤យ៉េន/ដុល្លារនៅត្រីមាសមុន ។ រូបិយវត្ថុរបស់ប្រទេសអាស៊ីមួយចំនួន ក៏ធ្លាក់ថ្លៃទល់នឹងដុល្លារ US ដែរ ។ ប្រាក់ដុល្លារឡើងថ្លៃដោយសារឱនភាពពាណិជ្ជកម្មរបស់ US ទាបជាងការរំពឹងទុកអត្រាការប្រាក់នៅ US ឡើងខ្ពស់ និងប្រទេសនានាក្រៅពីអាមេរិកបានថយចុះកំនើនសេដ្ឋកិច្ច ។

## ថ្លៃផលិតផលនៅលើទីផ្សារពិភពលោក

នៅត្រីមាសទី៣ ថ្លៃផលិតផលជ្រើសរើសមួយចំនួនក្នុងទីផ្សារអន្ដរជាតិមានការឡើងចុះចំរុះគ្នា ។ ថ្លៃអង្ករ សណ្ដែកសៀង និងប្រេងឆាធ្លាក់ចុះ ប៉ុន្ដែថ្លៃពោត ប្រេងឆៅ និងប្រេងសាំងកើនឡើង ។ នៅត្រីមាសទី៣ អង្ករស Thai 100%B លេខ២ នៅទីផ្សារបាងកក លក់បាន ២៨២ដុល្លារ/តោន គឺធ្លាក់ចុះពី ២៩៥,៧ដុល្លារ/តោននៅត្រីមាសមុន ។ សណ្ដែកសៀងលក់បាន២៣៦,៣៥ដុល្លារ/តោនរឺចុះថ្លៃ១៩% បើធៀបនឹងត្រីមាសមុន ។ប្រេងឆាក៏ធ្លាក់ថ្លៃដែរ ពី ៤២១,៧ដុល្លារ/តោន នៅត្រីមាសទី២ មកត្រឹម ១៥ដុល្លារ/តោននៅត្រីមាសទី៣ ប៉ុន្ដែ ពោតបានឡើងថ្លៃបន្ដិចពី ៩៦,៥ដុល្លារ/តោន ដល់ ៩៩,៩ដុល្លារ/តោន ។ ប្រេងឆៅ និងប្រេងសាំង ក៏ឡើងថ្លៃខ្លាំងដែរ ដល់ ២០% និង ៣២% រៀងគ្នា ធៀបនឹងត្រីមាស ទី២ ។ នៅត្រីមាសទី៣ ប្រេងឆៅលក់បាន ៥៧,២៧ដុល្លារ/ធុង រីឯប្រេងសាំងលក់បាន ៥២,៣៧សេន/លីត្រ ។ *រៀបរៀងដោយ ហ៊ីង វុត្ថា និង ភឹម រុនស៊ីណារិទ្ធិ*

---

*តពីទំព័រទី៤* **សកម្មភាពអាទិភាពក្នុងបឋមសិក្សា**

អប់រំ, ២) ប្រសិទ្ធភាព និងគុណភាពបឋមសិក្សា, ៣) ប្រសិទ្ធភាព និងគុណភាពមធ្យមសិក្សា, ៤) ប្រសិទ្ធភាព និងគុណភាពការបណ្ដុះបណ្ដាល/អប់រំខាងបច្ចេកទេស និងវិជ្ជាជីវៈ, ៥) ប្រសិទ្ធភាព និងគុណភាពការសិក្សាជាន់ខ្ពស់, ៦) ការអភិវឌ្ឍន៍គ្រូបង្រៀនជាបន្ដបន្ទាប់, ៧) ការអភិវឌ្ឍន៍សៀវភៅ និងសំភារៈបង្រៀន ៨) ការពង្រីកការអប់រំក្រៅប្រព័ន្ធ, ៩) ការយល់ដឹងនៅសាលារៀនពីជំងឺអេដស៍ ១០) ការយល់ដឹងនៅក្រៅសាលាពីជំងឺអេដស៍, ១១) សំភារៈផ្គត់ផ្គង់ការពង្រឹងសមត្ថភាព និងការពិនិត្យតាមដាននៅថ្នាក់ខេត្ត, ១២) ការចុះឈ្មោះ និងការផ្ដល់អាហារូបករណ៍មានសមធម៌ ។

៤. នៅខាងសុខាភិបាល PAP បានអនុវត្តសាកល្បងក្នុង ៧ខេត្តប៉ុណ្ណោះ ។ យោងតាមការឆ្លើយសំភាសន៍ថ្មីៗ គួរប្រើប្រាស់ PAP ឱ្យបានទូលាយជាងនេះនៅក្នុងវិស័យសិកម្ម និងអភិវឌ្ឍន៍ជនបទផង ។

**ឯកសារយោងសូមអាននៅក្នុងអត្ថបទជាភាសាអង់គ្លេស**

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្រៅប្រទេស

តារាង១. កំនើន ផសស ពិត នៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៥ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន)

| | 2000 | 2001 | 2002 | 2003 | 2004 | | 2005 | | | 2004 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | 7.3 | 6.7 | 4.8 | 7 | - | - | - | - | - | 7.7 |
| ឥណ្ឌូនេស៊ី | 4.4 | 3.8 | 3.8 | 4.9 | 5.0 | 6.6 | 6.4 | 5.5 | 5.3 | 5.1 |
| ម៉ាឡេស៊ី | 8.7 | 0.5 | 5.6 | 5.4 | 6.8 | 5.6 | 5.7 | 4.4 | 5.3 | 7 |
| សិង្ហបុរី | 9.5 | -2.3 | 2.6 | 1.4 | 7.5 | 6.5 | 2.5 | 5.4 | 7 | 8.5 |
| ថៃ | 4.4 | 1.9 | 6.1 | 6.9 | 6.0 | 5.0 | 3.3 | 4.6 | 5.3 | 6 |
| វៀតណាម | | 6.0 | 6.7 | 7 | - | - | - | - | - | 7.5 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 8.0 | 7.5 | 8.1 | 9.9 | 9.1 | 9.5 | 9.5 | 9.5 | 9.4 | 9.5 |
| ហុងកុង | 10.2 | 0.5 | 5.0 | 3.2 | 7.2 | 7.1 | 2.7 | 7.3 | 8.2 | 8.3 |
| កូរ៉េខាងត្បូង | 9.1 | 3.0 | 6.1 | 3 | 4.6 | 3.3 | 6 | 3.3 | 4.4 | 4.7 |
| តៃវ៉ាន់ | 5.8 | -2.2 | 4.2 | 3.1 | 5.3 | 3.3 | 2.7 | - | - | 5.7 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ | 3.5 | 1.4 | 0.7 | 0.5 | 1.9 | 1.6 | 1.3 | 1.2 | 1.5 | 1.8 |
| ជប៉ុន | 2.8 | 0.4 | 0.4 | 2.6 | 2.6 | 0.8 | 1.3 | 1.4 | 2.9 | 3.4 |
| សហរដ្ឋអាមេរិក | 5.0 | 1.2 | 2.4 | 3.1 | 3.9 | 3.8 | 3.5 | 3.3 | 4.1 | 4.4 |

Source: The Economist, Country's National Statistics offices and Central Banks, and ADB's Asia Regional Information Center

តារាង២. អត្រាអតិផរណានៃដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៥ (កំណើនជាភាគរយធៀបនឹងឆ្នាំមុន-មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | 2003 | 2004 | | 2005 | | | 2004 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា | -0.8 | -0.6 | 3.2 | 1.2 | 6.5 | 6.1 | 5.9 | 6.9 | 6.0 | 4.0 |
| ឥណ្ឌូនេស៊ី | 3.6 | 11.5 | 13.2 | 8.3 | 9.2 | 8.6 | 10.7 | - | - | 8.3 |
| ម៉ាឡេស៊ី | 1.5 | 1.4 | 1.8 | 1.1 | 1.5 | 2.4 | 2.5 | 3.0 | 3.4 | 1.6 |
| សិង្ហបុរី | 1.4 | 1.0 | -0.4 | 0.5 | 1.7 | 1.7 | 0.4 | 0.1 | 0.5 | 1.7 |
| ថៃ | 1.5 | 1.7 | 0.6 | 1.8 | 3.3 | 3.1 | 2.8 | 5.3 | 5.6 | 2.7 |
| វៀតណាម | -1.7 | -0.4 | 3.8 | 3.2 | 10.3 | 10.7 | - | - | - | 8.3 |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន | 0.3 | 0.9 | -0.7 | 1.2 | 5.2 | 3.2 | 2.8 | 1.7 | 1.3 | 3.9 |
| ហុងកុង | -3.6 | -1.3 | -3.0 | -2.6 | 0.8 | 0.2 | 0.4 | 0.8 | 1.4 | -0.4 |
| កូរ៉េខាងត្បូង | 2.3 | 4.4 | 2.7 | 3.5 | 4.4 | 3.4 | 3.2 | 3.2 | 2.4 | 3.5 |
| តៃវ៉ាន់ | 1.3 | -0.01 | -0.2 | -0.3 | 2.9 | 1.9 | 1.6 | 2.1 | - | 1.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ | 2.3 | 2.6 | 2.2 | 2.1 | 2.3 | 2.3 | 2.1 | 2.1 | 2.3 | 2.2 |
| ជប៉ុន | -0.7 | -0.6 | -0.9 | -0.3 | -0.1 | 0.5 | -0.2 | -0.1 | -0.3 | Nil |
| សហរដ្ឋអាមេរិក | 3.3 | 2.8 | 1.6 | 2.3 | 2.9 | 2.7 | 3.3 | 3.0 | 2.9 | 2.7 |

Source: The International Monetary Fund, the Economist and the National Institute of Statistics

តារាង៣. អត្រាប្តូរប្រាក់ធៀបនឹងដុល្លារនៃរូបិយវត្ថុរបស់ដៃគូពាណិជ្ជកម្មជ្រើសរើស ពីឆ្នាំ២០០០-២០០៥ មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | 2003 | 2004 | | 2005 | | | 2004 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q3 | Q4 | Q1 | Q2 | Q3 | |
| ប្រទេសអាស៊ានជ្រើសរើស | | | | | | | | | | |
| កម្ពុជា (រៀល) | 3,840.8 | 3,916.3 | 3,912.1 | 3,973 | 4,034.7 | 4,034.7 | 4,027.0 | 4,054.3 | - | 4,016.3 |
| ឥណ្ឌូនេស៊ី (រូពីយ៉ា) | 8,421 | 10,261 | 9,311 | 8,577 | 9,156 | 9,128 | 9,274 | - | - | 8,938 |
| ម៉ាឡេស៊ី (រីងហ្គីត) | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.80 | 3.77 | 3.80 |
| សិង្ហបុរី (ដុល្លារសិង្ហបុរី) | 1.72 | 1.79 | 1.79 | 1.74 | 1.70 | 1.65 | 1.63 | 1.66 | 1.67 | 1.69 |
| ថៃ (បាត) | 40.1 | 44.4 | 42.9 | 41.5 | 41.3 | 40.3 | 38.6 | 40.1 | 41.3 | 40.2 |
| វៀតណាម (ដុង) | 14,168 | 14,725 | 15,280 | 15,510 | 16,262 | - | - | - | - | - |
| ប្រទេសអាស៊ីជ្រើសរើស | | | | | | | | | | |
| ចិន (យ៉ុន) | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.28 | 8.14 | 8.28 |
| ហុងកុង (ដុល្លារហុងកុង) | 7.80 | 7.80 | 7.80 | 7.78 | 7.80 | 7.78 | 7.80 | 7.79 | 7.75 | 7.79 |
| កូរ៉េខាងត្បូង (វ៉ុន) | 1,131 | 1,291 | 1,251 | 1,192 | 1,155 | 1,093 | 1,022 | 1008 | 1037 | 1,145 |
| តៃវ៉ាន់ ដុល្លារតៃវ៉ាន់-(NT$) | 31.2 | 33.8 | 34.5 | 34.4 | 33.9 | 32.9 | 31.5 | 31.4 | 32.3 | 33.6 |
| ប្រទេសឧស្សាហកម្មជ្រើសរើស | | | | | | | | | | |
| អឺរ៉ុប-១២ (អឺរ៉ូ) | 1.09 | 1.12 | 1.06 | 0.89 | 0.82 | 0.77 | 0.76 | 0.79 | 0.81 | 0.80 |
| ជប៉ុន (យ៉េន) | 107.8 | 121.5 | 125.4 | 115.9 | 109.9 | 105.9 | 104.7 | 107.4 | 111.2 | 108.2 |

Sources: International Monetary Fund, Economist and National Bank of Cambodia

តារាង៤. ថ្លៃផលិតផលជ្រើសរើសនៅលើទីផ្សារពិភពលោក ពីឆ្នាំ២០០០-២០០៥ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 2000 | 2001 | 2002 | 2003 | 2004 | | | 2005 | 2005 | 2004 |
|---|---|---|---|---|---|---|---|---|---|---|
| | | | | | Q2 | Q3 | Q4 | Q1 | Q2 | |
| ប្រេងឆា- អឺរ៉ុបពាយព្យ ($/តោន) | 88.4 | 89.5 | 99.21 | 105.2 | 128.8 | 102.3 | 94.4 | 97 | 96.5 | 122 |
| ពោត (US No. 2) - US ($/តោន) | 310.2 | 285.7 | 390.2 | 443.25 | 497 | 432.3 | 429 | 413.3 | 421.7 | 471.3 |
| កៅស៊ូ - ម៉ាឡេស៊ី ($/តោន) | 720.8 | 602.0 | 768.3 | 1050 | 1,333.4 | 1,190.6 | 1238.2 | - | - | 1252.2 |
| អង្ករ (Thai 100%B) - បាងកក ($/តោន) | 206.7 | 177.3 | 196.9 | 200.9 | 240.7 | 240.5 | 264.9 | 295.6 | 295.7 | 244.4 |
| សណ្តែកសៀង (US No. 1) - US ($/តោន) | 193 | 180.7 | 201.3 | 241.3 | 356.4 | 251.1 | 216.5 | 229.9 | 290.7 | 288.9 |
| ប្រេងឆៅ-ឌូបៃ ($/ធុង) | 26.1 | 22.8 | 23.9 | 26.8 | 33.3 | 36.09 | 35.5 | 42.6 | 47.7 | 33.5 |
| សាំង - US Gulfcoast (សេន/លីត្រ) | 21.1 | 19.5 | 19.1 | 23 | 32.1 | 32.1 | 31.8 | 34.4 | 39.7 | 30.9 |

Sources: Food and Agriculture Organisation and US Energy Information Administration

# តាមដានសេដ្ឋកិច្ច ~ ស្ថានភាពក្នុងប្រទេស

## សកម្មភាពសេដ្ឋកិច្ចសំខាន់ៗ

កំណើនតួលេខនៅក្នុងពាណិជ្ជកម្មក្រៅប្រទេស វិនិយោគឯកជន និងទេសចរណ៍នៅត្រីមាសទី៣, ២០០៥ ធៀបនឹងត្រីមាសមុន បង្ហាញពីកំលាំងសេដ្ឋកិច្ចរបស់កម្ពុជាជាទូទៅក្នុងអំឡុងពេលនេះ ។

ពាណិជ្ជកម្មក្រៅប្រទេសមានអតិរេក ដោយសារកំណើនតាមរដូវកាលនៃបរិមាណនាំចេញជាសំខាន់ ។ នៅត្រីមាសទី៣ ពាណិជ្ជកម្មមានអតិរេក ៩៧,៧លានដុល្លារ ធៀបនឹងឱនភាព ១៥១,៤លានដុល្លារនៅត្រីមាសមុន ប៉ុន្តែនៅតិចជាងអតិរេកកាលពីត្រីមាសដូចគ្នានឹងឆ្នាំមុន ដែលមានដល់ ១៤៤,១លានដុល្លារ ។ តាមរបាយការណ៍ពីទីចាត់ការគយនិងរដ្ឋាករ តំលៃនាំចេញសរុបកើន ៤១,៧% ពីកំរិត ៥១៥លានដុល្លារនៅត្រីមាសទី២ ដល់ ៧៣០លានដុល្លារនៅត្រីមាសទី៣ ។ តួលេខនេះបង្ហាញជាសំខាន់ពីកំណើនផលិតផលសំលៀកបំពាក់ បារីនិងកៅស៊ូ ប៉ុន្តែការនាំចេញផលិតផលកសិកម្មចំបងៗ ដូចជា អង្ករស្រូវ ត្រី និងឈើ បានថយចុះ ។ ការនាំចេញសំលៀកបំពាក់ដែលនៅតែធំជាងគេ ក្នុងចំណោមទំនិញនាំចេញទាំងអស់ កើនយ៉ាងខ្លាំងបាន ៤២,៦% ដល់ ៧០៩,៨លានដុល្លារ ។ នៅត្រីមាសទី៣ ការនាំចេញសំលៀកបំពាក់កើន១០,៣% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ ក្នុងអំឡុងពេលនេះដែរ ការនាំចេញសរុបកើន ៩,២% ។

នៅត្រីមាសទី៣ ការនាំចូលសរុបរបស់កម្ពុជាដែលមានការនាំចូលរបស់វិស័យឯកជន និងសាធារណៈ (រដ្ឋ) មានតំលៃ ៦៣២,៣លានដុល្លារ គឺថយចុះ ៥,១% ពីកំរិត ៦៦៦,៤លានដុល្លារនៅត្រីមាសមុន ។ ការនាំចូលផ្នែកឯកជនថយចុះ៩,៥% (ពី២៦១,៣លានដុល្លារដល់២៣៦,៣លានដុល្លារ) និងផ្នែករដ្ឋ ថយចុះ ២,២% (ពី ៤០៥,១លានដុល្លារ ដល់ ៣៩៦លានដុល្លារ) ដែលបណ្តាលជាសំខាន់ពីការថយចុះការនាំចូលយានយន្តនិងគ្រឿងបន្លាស់របស់វា និងបន្ទាប់ពីនេះគឺ ម្ហូបអាហារ ភេសជ្ជៈ និងផលិតផលថ្នាំជក់ ។ ធៀបនឹងត្រីមាសទី៣ ២០០៤ ការនាំចូលសរុប កើន២០,៥% ដែលបណ្តាលជាសំខាន់ពីកំណើនថ្លៃទំនិញនាំចូល ភាគច្រើន និងកំណើនបរិមាណទំនិញនាំចូលមួយចំនួន ជាពិសេស សំភារៈសំណង់ និងប្រេងសាំង ។

នៅត្រីមាសទី៣នេះដែរ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា(CDC) បានអនុម័តគំរោងវិនិយោគឯកជនចំនួន ៣៣គំរោង គឺច្រើនជាងត្រីមាសទី២ ដែលមានតែ ២៥គំរោង ។ វិនិយោគឯកជននេះដែលគិត ជាតំលៃទ្រព្យសកម្មជាប់លាប់បានចុះបញ្ជី បានកើនយ៉ាងខ្លាំងពី ៩៦,១លានដុល្លារ ដល់ ៤០៤,២លានដុល្លារ និងឆ្លុះបញ្ចាំងពីកំណើនក្នុងវិស័យសំខាន់ៗទាំង៣ គឺឧស្សាហកម្ម កសិកម្ម និងសេវាកម្ម ។ គំរោងបានអនុម័តភាគច្រើន ស្ថិតក្នុងវិស័យឧស្សាហកម្ម និងមានតំលៃ ៣៤៩,៧លានដុល្លារ រឺ ៨៦,៥% នៃគំរោងអនុម័តសរុប (ធៀបនឹង៦២,១លានដុល្លារនៅត្រីមាសទី២) ក្នុងនេះរោងចក្រស៊ីម៉ង់ត៍នៅកំពត មានតំលៃ ១៨០,៨លានដុល្លារ ។វិនិយោគខាងកសិកម្មដែលមាននិន្នាការ កើនឡើងតាំងពីត្រីមាសទី១ ឡើងដល់ ១០,៤លានដុល្លារនៅត្រីមាសទី៣ ធៀបនឹង ៤លានដុល្លារនៅត្រីមាសទី២ ។ វិនិយោគខាងសេវាកម្មកើនដល់ ៤៤,១លានដុល្លារនៅត្រីមាសទី ៣ រឺកើន ៤៧% ពី ៣០លានដុល្លារនៅត្រីមាសទី២ ។ វិនិយោគឯកជនសរុប នៅត្រីមាសទី៣ ២០០៥ មានទំហំជិត ៥ដង នៃវិនិយោគក្នុងអំឡុងពេលដូចគ្នាឆ្នាំមុនដែលមានតែ ២០គំរោង ស្មើនឹង ៨២លានដុល្លារ ។

ក្រោយពីការធ្លាក់ចុះតាមរដូវកាលនៅត្រីមាសទី ២ ភ្ញៀវបរទេសចូលមកកម្ពុជាសរុបបានកើន ១០% ដល់ ៣២៣.២១៧នាក់ នៅត្រីមាសទី៣ ។ ក្នុងនេះ ទេសចរបរទេសមាន ២៨៨.៨៧៨នាក់ រឺកំណើន ១០% ធៀបនឹងត្រីមាសមុន រីឯភ្ញៀវចូលមកក្នុងការងារជំនួញ និងភ្ញៀវមានទិដ្ឋាការរដ្ឋការ បានកើន ៩,៦% ដល់ ២២.១៩២នាក់ និង ១២.១៤៧នាក់ រៀងគ្នា ។នៅត្រីមាសទី៣ចំនួនភ្ញៀវបរទេសសរុបកើនយ៉ាងខ្លាំងដល់៤១,៨% បើធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន ។ ភ្ញៀវមានទិដ្ឋាការផ្លូវការរដ្ឋ កើនខ្ពស់ជាងគេ (៥៩,៦%) បន្ទាប់មកគឺទេសចរ (៤២,២%) និងអ្នកជំនួញ (២៩,៣%) ។

ថ្វីបើពាណិជ្ជកម្មក្រៅប្រទេស ការវិនិយោគទុន និងទេសចរណ៍ បានរីកចំរើននៅត្រីមាសទី៣ ក្តី ប៉ុន្តែគំរោងសាងសង់នៅភ្នំពេញដែលទទួលការអនុមតិ បានបន្តធ្លាក់ចុះអស់ ២៦,៧% ដល់ ៧៦,៥លានដុល្លារពីកំរិត ១០៤,៤លានដុល្លារនៅត្រីមាសទី២ ។រឿងនេះបង្ហាញពីការធ្លាក់ចុះគំរោងសាងសង់ផ្ទះល្វែង (ពី ៦៩,១លានដុល្លារ ដល់ ៤១,៣លានដុល្លារ) និងសំណង់ដទៃទៀត (ពី ២៨,៦លានដុល្លារ ដល់ ១៦,០លានដុល្លារ) ប៉ុន្តែគំរោងសាងសង់ភូមិគ្រឹះ/ផ្ទះ កើនឡើងជិតមួយជាបី ពី ៦,៦លានដុល្លារ ដល់ ១៩,២លានដុល្លារ ។ បើធៀបនឹងត្រីមាសទី ៣ ២០០៤ តំលៃគំរោងសាងសង់សរុបបានអនុម័តនៅភ្នំពេញ ថយចុះ ១,៨% ។

## ហិរញ្ញវត្ថុសាធារណៈ

យោងតាមទិន្នន័យបានកែតំរូវហើយ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ប្រតិបត្តិការថវិការដ្ឋ មានដំណើរកាន់តែមិនសូវល្អនៅត្រីមាសទី៣ ដោយមានឱនភាពសរុបឡើងដល់ ២១៣,១ពាន់លានរៀល ធៀបនឹង ៤២,៣ពាន់លានរៀលនៅត្រីមាសទី២ ។

នៅត្រីមាសទី៣ ចំណូលថវិការដ្ឋកើនដល់ ៦២៤,៣ពាន់លានរៀល រឺកើន ០,៤% ធៀបនឹងត្រីមាសទី២ ។ ចំនូលជាមូលធនកើន ៤០,៤% ដល់ ១៤,៦ពាន់លានរៀន ប៉ុន្តែចំណូលចរន្ត ថយចុះ ០,៣% ដល់ត្រឹម ៦០៩,៨ពាន់លានរៀល ។ ចំណូលពន្ធដែលជាប្រភពចំបងនៃចំណូលចរន្ត ថយចុះ ៦,៤% ដល់ ៤៣៦,២ពាន់លានរៀល ប៉ុន្តែចំណូលមិនមែនពន្ធបន្តកើនឡើង ១៩,២% ដល់ ១៧៣,៥ពាន់លានរៀល ។ នៅត្រីមាសទី៣ នេះ ចំណូលថវិកាសរុបមានកំរិតប្រហែល ៣៨% ច្រើនជាងត្រីមាសដូចគ្នាឆ្នាំមុន ដោយសារទាំងចំនូលជាមូលធន និងចំនូលចរន្ត បានកើនយ៉ាងខ្លាំងក្នុងអំឡុងពេលនេះ ។

ចំណាយថវិការដ្ឋសរុប ដែលមានទាំងការកែតំរូវចំណាយផង បានបន្តកើនឡើងដល់ ៨៣៧,៥ពាន់លានរៀលនៅត្រីមាសទី៣ រឺ ២៦% ខ្ពស់ជាងត្រីមាសមុន ។ កំណើនយ៉ាងខ្លាំងនៃចំណាយថវិកាចរន្ត (កើន ៤៥% ដល់ ៥៧៧,៣ពាន់លានរៀល) ជាកត្តានាំមុខគេនៅក្នុងកំណើនចំណាយសរុប ប៉ុន្តែក៏មានការថយចុះ កំណើនចំណាយជាមូលធនអស់ ២,៣% មកត្រឹម ២៦០,២ពាន់លានរៀលដែរ ។ ចំណាយលើរដ្ឋបាលសង្គមកិច្ច និងការពារជាតិ/សន្តិសុខ បានកើនយ៉ាងខ្លាំង បើធៀបនឹងចំណាយលើរដ្ឋបាលទូទៅ រដ្ឋបាលសេដ្ឋកិច្ច និងរដ្ឋបាលដទៃទៀត ។ ធៀបនឹងត្រីមាសទី៣ ២០០៤ ចំណាយថវិកាសរុបកើន ១៩% ដែលមានចំណាយចរន្តនាំមុខគេ ។

## អតិផរណា និងអត្រាប្តូរប្រាក់

បន្ទាប់ពីកើនខ្ពស់អស់ជាច្រើនត្រីមាស អតិផរណាបានធ្លាក់ចុះមកវិញ ។ នៅត្រីមាសទី៣ ២០០៥ សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់នៅភ្នំពេញ កើន ៤,៦% ធៀបនឹងត្រីមាសដូចគ្នាឆ្នាំមុន គឺទាបជាងកំនើន ៦,៤% នៅត្រី

មាសមុន ។ ក្នុងនេះថ្លៃម្ហូបអាហារ (ប្រហែល ៨០% នៃទំនិញបានធ្វើអង្កេតទាំងអស់) កើន ៦% ធៀបនឹងកំណើន ៩,៨% នៅត្រីមាសទី២ ប៉ុន្តែថ្លៃទំនិញប្រើប្រាស់សំខាន់ៗឯទៀត (សំលៀកបំពាក់ ស្បែកជើង សំភារៈប្រើប្រាស់ក្នុងផ្ទះ ថ្នាំពេទ្យ ដឹកជញ្ជូននិងទូរគមនាគមន៍, ការអប់រំ និងការលំហែកំសាន្ត, និង ផលិតផលថែទាំកាយ) កើនឡើងបន្តិចប៉ុណ្ណោះ ។

នៅត្រីមាសទី៣ ប្រាក់រៀលបន្តធ្លាក់ថ្លៃទល់នឹងដុល្លារអាមេរិក និងប្រាក់ដុងវៀតណាម ប៉ុន្តែឡើងថ្លៃទល់នឹងប្រាក់បាតថៃ ។១ដុល្លារអាមេរិកជាមធ្យមប្តូរបាន៤.១៣៤,៣រៀល ធៀបនឹង៤.០៥៤,៣រៀលនៅត្រីមាសទី២ គឺប្រាក់រៀល បានចុះថ្លៃ ២% ។ ម្យ៉ាងទៀត ប្រាក់រៀលប្តូរបាន ២៥,៩រៀល/១០០ដុងដោយចុះថ្លៃ ២,៤% ទាបជាងត្រីមាសទី២ ។ ប្រាក់រៀលបន្តឡើងថ្លៃទល់នឹងប្រាក់បាត បានជិត ១,១% ពីកំរិត ១០១,៣ រៀល/បាតនៅត្រីមាសទី២ ដល់ ១០០,២រៀល/បាតនៅត្រីមាសទី៣ ។

## ការវិវត្តន៍រូបិយវត្ថុ

នៅត្រីមាសទី៣ រូបិយវត្ថុផ្គត់ផ្គង់ (M3) (ប្រាក់រៀលកំពុងធ្វើចរាចរ និងផ្ញើនៅធនាគារ និងប្រាក់បញ្ញើជារូបិយវត្ថុបរទេស) កើន ៧,៩% ដល់ ៤.៩៩៣,៨ពាន់លានរៀល (ធៀបនឹងកំណើន ៣,០% នៅត្រីមាសទី២) ដោយសារជាសំខាន់ កំណើនយ៉ាងរហ័សនៃប្រាក់បញ្ញើជារូបិយវត្ថុបរទេស និងបន្ទាប់មកគឺកំណើនប្រាក់រៀល កំពុងចរាចរនៅក្រៅធនាគារ ។ ប្រាក់បញ្ញើជារូបិយវត្ថុបរទេសកើន ៧,៣% (ពី ៣.២៩៤,៩ពាន់លានរៀល រឺ ៨០២,៥លានដុល្លារដល់៣.៥៩៦,៣ពាន់លានរៀលរឺ៨៦១,៤លានដុល្លារ) ធៀបនឹង កំណើនតែ១,៤% នៅត្រីមាសទី២ ។ប្រាក់រៀលនៅក្រៅធនាគារកើន ៥,៨% (ពី ១.១៦៧,៣ពាន់លានរៀលដល់ ១.២៣៥,១ពាន់លានរៀល) ធៀបនឹងកំណើនត្រឹម ០,៣% នៅត្រីមាសទី២ ។ ការបញ្ចេញប្រើក្រដាសប្រាក់ថ្មីយ៉ាងលឿននាំឱ្យមានកំណើននេះ ។

ប្រាក់រៀលនៅធនាគារ (ប្រាក់បញ្ញើចរន្ត ប្រាក់បញ្ញើមានកាលកំណត់ និងប្រាក់បញ្ញើសន្សំ) ធ្លាក់ចុះ ២,៣% (ពី ១៦៦,៣ពាន់លានរៀលដល់ ១៦២,៥ពាន់លានរៀល) គឺផ្ទុយពីកំនើន ១៥,៧%នៅត្រីមាសទី២ ។ ប្រាក់បញ្ញើចរន្តធ្លាក់ចុះ ៧,០% ដល់ ៤៤,២ពាន់លានរៀល ហើយប្រាក់បញ្ញើមានកាលកំនត់ និងប្រាក់បញ្ញើសន្សំធ្លាក់ចុះ ០,៤% ដល់ ១១៨,៣ពាន់លានរៀល ។

## ស្ថានភាពក្រីក្រ និងប្រាក់ចំណូលប្រចាំថ្ងៃពិតរបស់ពលករងាយរងគ្រោះ

អង្កេតថ្មីៗរបស់ វបសអ លើពលករងាយរងគ្រោះបង្ហាញថា ចំនូលប្រចាំថ្ងៃក្នុងមនុស្សសំរាប់ ១០ក្រុមពលករងាយរងគ្រោះ បានធ្លាក់ចុះអស់២ឆ្នាំជាប់ៗគ្នា ។ចំណូលប្រចាំថ្ងៃជាមធ្យមក្នុង មនុស្សម្នាក់គឺ ៧.៤៨៩រៀលនៅឆ្នាំ២០០៥ រឺធ្លាក់ចុះ ១% ក្រោយពីបានធ្លាក់ចុះអស់ ៣% នៅឆ្នាំ២០០៤ ។ អង្កេតបង្ហាញទៀតថា អ្នករត់ម៉ូតូឌុប មានកំណើនប្រាក់ចំនូលខ្ពស់ជាងក្រុមឯទៀតៗ ឯកម្មករកាត់ដេរមានប្រាក់ចំណូលធ្លាក់ចុះច្រើនជាងគេ ។

ចំណូលពិតជាមធ្យមនៃកម្មករកាត់ដេរ ធ្លាក់ចុះ ៨,៧% ពីកំរិត ៩.២៧៧រៀលនៅឆ្នាំ២០០៤ ដល់ ៨.៤៦៦រៀល នៅឆ្នាំ២០០៥ ដែលជាការធ្លាក់ចុះខ្លាំងបំផុត តាំងពីពេលធ្វើអង្កេតដំបូងនៅឆ្នាំ២០០០ ។ រឿងនេះបង្ហាញពីចំនួនកាន់តែច្រើននៃអ្នកស្វែងរកការងារនៅក្នុងវិស័យនេះ ដែលធ្វើឱ្យម្ចាស់រោងចក្រអាចជួលកម្មករថ្មីៗក្នុងតំលៃថោកជាងមុន ។ការបញ្ចប់កិច្ចព្រមព្រៀងវិស័យកាត់ដេរ និងវាយនភណ្ឌ បានបង្ខំឱ្យវិនិយោគិនមួយចំនួនបិទរោងចក្រដែលផ្តល់ឱកាសឱ្យរោងចក្រដទៃ អាចជួលកម្មករបណ្តោះអាសន្នបន្ថែមក្នុងតំលៃថោកជាងមុន ។ ចំនួនកម្មករបណ្តោះអាសន្នមានច្រើនជាងឆ្នាំមុន ហើយពួកគេភាគច្រើនបានឆ្លើយសំភាសន៍ប្រាប់ថា ទទួលបានកំរៃតិចជាងកម្មករអចិន្ត្រៃយ៍ ។ សព្វថ្ងៃកម្មករ កាត់ដេរ កំពុងព្រួយបារម្ភពីរឿងស្ថិរភាពការងារ ដោយសារនិន្នាការធ្លាក់ចុះប្រាក់ចំណូលរបស់ពួកខ្លួន និងការបិទរោងចក្រ ។ ភាគច្រើននៃកម្មករអចិន្ត្រៃយ៍ និងកម្មករបណ្តោះអាសន្ន ជាអ្នកមកពីតំបន់ជនបទដែលត្រូវផ្ញើប្រាក់ចំណូលរបស់ខ្លួនមួយភាគធំទៅផ្គត់ផ្គង់ក្រុមគ្រួសារ ។

ចំណូលមធ្យមរបស់អ្នកលីសែងនៅឆ្នាំ២០០៥ គឺ ៦.៦០០រៀល/ថ្ងៃ រឺថយចុះ ៤% ពីកំរិត ៦.៩០០រៀលនៅឆ្នាំ ២០០៤ ហើយរឿងនេះបណ្តាលពីកម្មករលីសែងមានច្រើនជាងឆ្នាំមុន ។ អ្នកចំនូលថ្មីភាគច្រើនជាអ្នកទើបឈប់រៀន និងមានចំនេះដឹងតិចតួច ។ អង្កេតរកឃើញថា អ្នកលីសែង ៥៧,៥% បានឈប់រៀននៅកំរិតបឋមសិក្សា ។ស្ថិតិបង្ហាញថាសិស្សបោះបង់ការសិក្សាអាចនៅមានចំនួនច្រើនហើយគេមិនគួរធ្វេសប្រហែសទេនៅក្នុងការងារកាត់បន្ថយភាពក្រីក្រ ។

ចំនូលប្រចាំថ្ងៃជាមធ្យមរបស់កម្មករសំណង់មានជំនាញធ្លាក់ចុះ ៥% ពី ១២.៧០០រៀលនៅឆ្នាំ២០០៤ ដល់ ១២.០៥០រៀល នៅឆ្នាំ២០០៥ ថ្វីបើនាយកដ្ឋានសុរិយោដី និងភូមិសាស្ត្រក្រុង ភ្នំពេញបានរាយការណ៍ថា មានគំរោងសាងសង់ដ៏ច្រើនក្នុងអំឡុងពេលនេះក្តី ។ មូលហេតុគឺអាចមកពីកំនើនចំនួនកម្មករដែលស្វែងរកការងារធ្វើ ។ ពួកកម្មករសំណង់មានអារម្មណ៍ថា ទាំងកម្មករសំណង់មានជំនាញ និងគ្មានជំនាញ បានកើនចំនួនយ៉ាងខ្លាំង បើធៀបនឹងឆ្នាំមុន ។ ពួកគេសឹងតែគ្រប់គ្នាមកពីតំបន់ជនបទ និងចំនាយយ៉ាងសំចៃអស់តែ ៣.៥០០រៀលប៉ុណ្ណោះសំរាប់អាហារប្រចាំថ្ងៃ ។ ចំនុចនេះបង្ហាញថា នៅតាមខេត្តរបស់ពួកគេមានការងារមិនមែនកសិកម្មតិចតួចណាស់ ។

នៅឆ្នាំ២០០៥ ចំនូលប្រចាំថ្ងៃរបស់អ្នកលក់បន្លែតូចតាចកើន ៥,៤% ។ ជាមធ្យម ពួកអ្នកលក់តូចៗអាចរកចំនូលបាន ៦.៩៥០រៀល/ថ្ងៃ ធៀបនឹង ៦.៦០០រៀលនៅឆ្នាំមុន ។ ប៉ុន្តែក្នុងរយៈពេលធ្វើអង្កេត មានអ្នកលក់តែ ៣០% ប៉ុណ្ណោះដែលយល់ថា ចំណូលរបស់ពួកខ្លួនបានកើនឡើង រីឯ ៣០% ទៀត រាយការណ៍ថានៅដដែល និង ៤០%ទៀត និយាយថា បានធ្លាក់ចុះ ។ អង្កេតរកឃើញដែរថា អ្នកនិយាយប្រាប់ពីកំនើនចំណូល គឺអ្នករស់នៅជាប់លាប់ក្នុងក្រុងភ្នំពេញ ឯក្រៅពីនេះសុទ្ធតែមកពីខេត្ត ។

ចំណូលប្រចាំថ្ងៃរបស់អ្នករើសអេតចាយ កើន ៤ឆ្នាំជាប់ៗគ្នា ដល់ ៤.៩៥០រៀល រឺ ១១% ខ្ពស់ជាងឆ្នាំមុន ដែលហាក់ដូចមកពីការឡើងថ្លៃរបស់អេតចាយនៅឆ្នាំ២០០៥ ។ ប្រហែល ១/៣ នៃអ្នករើសអេតចាយពឹងផ្អែកទាំងស្រុងលើការរើសអេតចាយ ទោះបីប្រាក់ដែលពួកគេរកបានវាមិនគ្រប់គ្រាន់សំរាប់ទិញម្ហូបអាហារចាំបាច់សំរាប់ក្រុមគ្រួសារក្តី ។ អង្កេតរកឃើញថា ភាគច្រើននៃពលករប្រភេទនេះមកពីតំបន់ជនបទ និងរស់នៅតាមកន្លែងដែលពួកគេរើសំរាម ប្រមូលរបស់អេតចាយតែម្តង ។

ចំណូលប្រចាំថ្ងៃពិតរបស់អ្នករត់ម៉ូតូឌុបកើនឡើងយ៉ាងខ្លាំងដល់ ៥%ពី ៩.២០០រៀលនៅឆ្នាំ ២០០៤ ដល់ ១០.៦០០រៀលនៅឆ្នាំ២០០៥ ។ ប៉ុន្តែពួកគេអះអាងថា កំនើននេះមិនគ្រប់គ្រាន់សំរាប់ប៉ះប៉ូវការឡើងថ្លៃប្រេងសាំងទេ ។ ពលករក្រុមនេះ ប្រហែលបានទទួលផលពីកំណើនទេសចរណ៍ ។ ទិន្នន័យពីក្រសួងទេសចរណ៍បង្ហាញថា ចំនួនភ្ញៀវទេសចរចូលមកកម្ពុជានៅឆ្នាំ២០០៥ កើន ៣៦% ។

*រៀបរៀងដោយ អ៊ូច ច័ន្ទតារានី និង ប៉ុន ដូរីណា*

## តារាង១. គំរោងវិនិយោគឯកជនដែលបានអនុម័ត ឆ្នាំ១៩៩៧-២០០៥

| | 1997* | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | | 2005 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q3 | Q4 | Q1 | Q2 | Q3 |
| | ទ្រព្យសកម្មជាប់លាប់ (លានដុល្លារ) | | | | | | | | | | | |
| កសិកម្ម | 65.6 | 51.6 | 63.9 | 9.8 | 5.6 | 38.9 | 3.7 | 2.9 | 0.0 | 3.2 | 4.0 | 10.4 |
| ឧស្សាហកម្ម | 512.4 | 650.5 | 162.6 | 109.4 | 99.8 | 57.4 | 142.6 | 72.7 | 16.4 | 418.8 | 62.1 | 349.7 |
| កាត់ដេរ | 97.0 | 126.5 | 67.7 | 35.2 | 23.0 | 18.0 | 74.8 | 44.0 | 12.7 | 44.9 | 23.2 | 56.5 |
| សេវាកម្ម | 166.5 | 154.7 | 222.6 | 150.0 | 111.4 | 143.3 | 167.7 | 6.4 | 0.0 | 53.3 | 30.0 | 44.1 |
| សណ្ឋាគារ និងទេសចរណ៍ | 41.5 | 112.0 | 171.8 | 79.8 | 71.9 | 45.1 | 118.6 | 6.4 | 0.0 | 46.4 | 0.0 | 33.6 |
| សរុប | 744.5 | 856.8 | 449.1 | 269.2 | 216.8 | 239.6 | 314.1 | 82.0 | 16.4 | 475.3 | 96.1 | 404.2 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | -27.6 | -80.0 | 2,798.2 | -79.8 | 320.6 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | - | 15.0 | -47.6 | -40.0 | -19.5 | 10.5 | 31.1 | -13.8 | -73.6 | 650.8 | -15.2 | 392.9 |

Source: Cambodian Investment Board. *Excluding expansion project approvals.

## តារាង២. តំលៃគំរោងសំណង់នៅភ្នំពេញដែលបានអនុម័ត ឆ្នាំ១៩៩៧-២០០៥

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | | 2005 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q3 | Q4 | Q1 | Q2 | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ភូមិគ្រឹះ, ផ្ទះ | 17.2 | 21.2 | 20.0 | 16.4 | 15.9 | 23.4 | 20.0 | 7.5 | 5.5 | 14.3 | 6.6 | 19.2 |
| ផ្ទះល្វែង | 19.3 | 227.3 | 290.5 | 174.8 | 167.8 | 179.9 | 91.6 | 44.3 | 46.3 | 48.6 | 69.1 | 41.3 |
| ផ្សេងៗ | 221.2 | 27.0 | 16.4 | 14.2 | 12.6 | 16.6 | 87.3 | 26.1 | 12.4 | 43.1 | 28.6 | 16.0 |
| សរុប | 257.7 | 275.4 | 326.8 | 205.4 | 196.2 | 219.8 | 198.9 | 77.9 | 64.1 | 106.1 | 104.4 | 76.5 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | - | - | - | - | - | - | - | 60.3 | -17.7 | 65.5 | -1.6 | -26.7 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | - | 6.9 | 18.7 | -37.2 | -4.5 | 12.0 | -9.5 | 56.4 | 28.6 | 45.5 | 114.8 | -1.8 |

Source: Department of Cadastre and Geography of the Municipality of Phnom Penh

## តារាង៣. ការនាំចេញ និងនាំចូល ឆ្នាំ១៩៩៧-២០០៥

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | | 2005 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q3* | Q4* | Q1* | Q2* | Q3 |
| | លានដុល្លារ | | | | | | | | | | | |
| ការនាំចេញសរុប | 493.4 | 784.4 | 941.1 | 1,056.2 | 1,268.2 | | 1,708.1 | 668.8 | 545.1 | 463.0 | 515.0 | 730.0 |
| រួមមាន: - សំល្បៀកបំពាក់ | 227.2 | 378.0 | 554.0 | 962.1 | 1,202.2 | | 1,628.4 | 643.7 | 520.3 | 444.9 | 497.6 | 709.8 |
| - ទៅសហរដ្ឋអាមេរិក | 107.2 | 74.1 | 486.0 | 714.1 | 840.9 | 943.4 | 1,099.8 | 387.6 | 321.2 | 312.5 | 335.9 | 489.5 |
| - ទៅសហគមន៍អ៊ឺរ៉ុប | - | - | - | 228.1 | 323.3 | 356.3 | 414.7 | 200.9 | 159.1 | 89.2 | 106.0 | 162.5 |
| - ប្រទេសផ្សេងទៀត | 120.0 | 82.0 | 68.0 | 19.9 | 38.0 | 56.1 | 113.8 | 55.2 | 40.0 | 43.1 | 55.7 | 57.8 |
| - កសិកម្ម | - | - | - | 94.2 | 66.0 | 97.3 | 79.7 | 25.1 | 24.8 | 18.1 | 17.3 | 20.2 |
| - កៅស៊ូ | - | - | - | 29.6 | 25.9 | 29.7 | 35.1 | 11.6 | 12.0 | 7.3 | 6.2 | 9.8 |
| - ឈើ | - | - | - | 32.9 | 22.3 | 16.0 | 10.2 | 4.2 | 2.4 | 3.3 | 2.9 | 2.1 |
| - ត្រី | - | - | - | 5.4 | 6.0 | 4.3 | 2.8 | 4.3 | 4.4 | 1.5 | 1.1 | 0.8 |
| - ផ្សេងៗ | - | - | - | 26.2 | 11.8 | 47.4 | 31.6 | 5.0 | 6.0 | 6.0 | 7.1 | 7.5 |
| ការនាំចូលសរុប | 1,094.5 | 1,112.2 | 1,237.4 | 1,417.7 | 1,501.4 | | 1,824.9 | 524.7 | 548.1 | 520.7 | 666.4 | 632.3 |
| រួមមាន: - សាំង | - | - | - | - | - | 26.0 | 33.2 | 6.6 | 7.8 | 10.3 | 9.3 | 9.9 |
| - ម៉ាស៊ូត | - | - | - | - | - | 102.0 | 109.6 | 27.4 | 23.5 | 21.6 | 25.8 | 24.6 |
| - សំភារៈសំណង់ | - | - | - | - | - | 97.4 | 80.8 | 21.3 | 26.5 | 32.3 | 37.1 | 38.7 |
| - ផ្សេងៗ | - | - | - | - | - | | 1,601.3 | 469.4 | 490.3 | 456.5 | 594.2 | 559.1 |
| ជញ្ជីងពាណិជ្ជកម្ម | -601.2 | -327.8 | -296.3 | -361.5 | -233.2 | -220.9 | -116.8 | 144.1 | -3.0 | -57.7 | -151.4 | 97.7 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំល្បៀកបំពាក់សរុប | - | - | - | - | - | - | - | 34.3 | -19.2 | -14.5 | 11.8 | 42.6 |
| ការនាំចេញសរុប | - | - | - | - | - | - | - | 35.2 | -18.5 | -15.1 | 11.2 | 41.7 |
| ការនាំចូលសរុប | - | - | - | - | - | - | - | -13.5 | 4.5 | -5.0 | 28.0 | -5.1 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីឆ្នាំមុន | | | | | | | | | | | |
| ការនាំចេញសំល្បៀកបំពាក់សរុប | 188.0 | 66.4 | 47.0 | 74.0 | 24.9 | 12.8 | 20.1 | 35.4 | 16.0 | 16.0 | 3.8 | 10.3 |
| ការនាំចេញសរុប | 27.5 | 59.0 | 20.0 | 12.2 | 20.1 | 14.6 | 17.5 | 35.9 | 14.6 | 15.9 | 4.1 | 9.2 |
| ការនាំចូលសរុប | -1.8 | 1.6 | 11.3 | 14.6 | 5.9 | 11.5 | 9.0 | 20.3 | 12.5 | 13.7 | 9.9 | 20.5 |

Sources: Department of Trade Preferences Systems, MOC and Customs and Excise Department, MEF. Import data include tax exemption imports.

តារាង៤. ចំនួនអ្នកដំណើរមកដល់ក្នុងប្រទេសកម្ពុជា ឆ្នាំ១៩៩៧-២០០៥

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | | 2005 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q3 | Q4 | Q1 | Q2 | Q3 |
| | អ្នកដំណើរពាន់នាក់ | | | | | | | | | | | |
| តាមផ្លូវអាកាស | – | 186.3 | 262.9 | 351.7 | 408.4 | 523.0 | 456.0 | 143.9 | 201.5 | 231.7 | 169.8 | 202.8 |
| | – | 100.2 | 104.8 | 114.7 | 196.5 | 263.5 | 245.0 | 84.2 | 177.3 | 148.9 | 124.0 | 120.4 |
| សរុប | 218.8 | 286.5 | 367.7 | 466.4 | 604.9 | 786.5 | 701.0 | 228.1 | 378.8 | 380.6 | 293.8 | 323.2 |
| | បំរែបំរួលជាភាគរយធៀបនឹងត្រីមាសមុន | | | | | | | | | | | |
| សរុប | – | – | – | – | – | – | – | 17.7 | 66.1 | 0.5 | -22.8 | 10.0 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| សរុប | -16.0 | 30.9 | 28.3 | 26.8 | 29.7 | 30.0 | -10.9 | 44.0 | 70.1 | 49.6 | 51.6 | 41.8 |

ប្រភព: ក្រសួងទេសចរណ៍ ។

តារាង៥. ប្រតិបត្តិការថវិកាជាតិលើមូលដ្ឋានជាសាច់ប្រាក់ ឆ្នាំ១៩៩៧-២០០៥ (ពាន់លានរៀល)

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | | 2005 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q3 | Q4 | Q1 | Q2 | Q3 |
| ចំណូលសរុប | 880 | 920 | 1326 | 1,528 | 1,529 | 1,744 | 1,765 | 452.1 | 662.2 | 551.6 | 621.9 | 624.3 |
| ចំណូលចរន្ត | - | - | - | - | 1,521 | 1,728 | 1,733 | 450.8 | 657.7 | 551.3 | 611.5 | 609.8 |
| ចំណូលពន្ធ | 596 | 676 | 956 | 1,096 | 1,096 | 1,227 | 1,220 | 334.1 | 485.7 | 455.1 | 466.0 | 436.2 |
| ពន្ធគយ | 348 | 376 | 432 | 376 | 376 | 424 | 395 | 99.9 | 168.0 | 129.4 | 129.7 | 123.7 |
| ចំណូលមិនមែនពន្ធ | 272 | 204 | 348 | 424 | 424 | 501 | 513 | 116.7 | 172.1 | 96.2 | 145.5 | 173.5 |
| អាជីវកម្មព្រៃឈើ | 36 | 20 | 36 | 28 | 29 | 15 | 7.0 | 0.2 | 0.5 | 1.3 | 1.5 | 0.3 |
| ប្រៃសណីយ៍ និងទូរគមនាគមន៍ | 84 | 88 | 108 | 124 | 122 | 123 | 120 | 28.8 | 26.3 | 21.9 | 32.0 | 30.9 |
| ចំណូលជាមូលធន | 12 | 36 | 12 | 8 | 9 | 16 | 31 | 1.3 | 4.5 | 0.3 | 10.4 | 14.6 |
| ចំណាយសរុប | 1,260 | 1,296 | 1,792 | 2,332 | 2,332 | 2,948 | 2,757 | 703.4 | 909.3 | 630.7 | 664.2 | 837.5 |
| ចំណាយជាមូលធន | 452 | 368 | 624 | 976 | 977 | 1,388 | 1,171 | 277.3 | 293.5 | 250.7 | 266.4 | 260.2 |
| ចំណាយចរន្ត | 808 | 980 | 1,164 | 1,356 | 1,355 | 1,560 | 1,586 | 426.0 | 615.8 | 380.0 | 397.8 | 577.3 |
| អប់រំ និងសុខាភិបាល | 128 | 132 | 280 | 344 | 343 | 454 | 473 | 116.0 | 290.0 | 52.5 | 92.3 | 202.1 |
| ការពារជាតិ និងសន្តិសុខ | 420 | 448 | 464 | 404 | 405 | 438 | 411 | 91.5 | 197.8 | 74.9 | 73.9 | 116.7 |
| ក្រសួងផ្សេងៗទៀត | 260 | 332 | 412 | 636 | 637 | 668 | 702 | 218.6 | 130.6 | 252.6 | 231.7 | 258.5 |
| ឱនភាពជាទូទៅ | -380 | -380 | -476 | -804 | -803 | -1,204 | -992 | -251.2 | -247.1 | -79.1 | -42.3 | -213.1 |
| ហិរញ្ញប្បទានពីក្រៅប្រទេស | 444 | 268 | 416 | 768 | 766 | 1,249 | 886 | 216.6 | 238.7 | 190.68 | 203.8 | 255.8 |
| ហិរញ្ញប្បទានក្នុងស្រុក | -64 | 112 | 60 | 36 | 37 | -45 | 106 | 34.6 | 8.4 | -111.5 | -161.5 | -42.7 |

Source: Ministry of Economy and Finance. Q1–Q4 2004 revised. Provisional for Q1–Q4 2004 and Q1–Q3 2005.

តារាង៦. សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ (CPI) អត្រាប្តូរប្រាក់ និងថ្លៃមាស ឆ្នាំ១៩៩៧-២០០៥ (មធ្យមភាគតាមការិយបរិច្ឆេទ)

| | 1997 | 1998 | 1999 | 2000 | 2001* | 2002 | 2003 | 2004 | | 2005 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q3 | Q4 | Q1 | Q2 | Q3 |
| | សន្ទស្សន៍ថ្លៃទំនិញប្រើប្រាស់ បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន) | | | | | | | | | | | |
| ខេត្ត* | – | – | 5.8 | 5.4 | -0.1 | 0.9 | 4.4 | 22.1 | 23.0 | 14.3* | 7.9* | 3.6 |
| ភ្នំពេញ – ទំនិញគ្រប់ប្រភេទ | 8.0 | 14.8 | 4.0 | -0.8 | 0.2 | 3.3 | 1.1 | 6.7 | 5.8 | 5.6 | 6.4 | 4.6 |
| ភ្នំពេញ – ម្ហូបអាហារ | 6.7 | 14.1 | 7.6 | -3.4 | -2.5 | 1.8 | 1.5 | 12.2 | 9.1 | 7.9 | 9.8 | 6.0 |
| ភ្នំពេញ – ដឹកជញ្ជូន | 19.5 | 15.1 | 3.5 | 6.6 | -4.2 | 0.3 | 4.9 | 11.5 | 14.5 | 12.3 | 11.1 | 11.9 |
| | អត្រាប្តូរប្រាក់ ថ្លៃមាស ថ្លៃប្រេងឥន្ធនៈ (តាមអត្រាទីផ្សារនៅភ្នំពេញ) | | | | | | | | | | | |
| ៛/១ ដុល្លារ* | – | – | – | 3,840.8 | 3,916.3 | 3,912.1 | 3,973.3 | 4,034.7 | 4,034.7 | 4,027.0 | 4,054.3 | 4,134.3 |
| ៛/១ បាតថៃ* | – | – | – | 95.8 | 88.2 | 91.1 | 95.8 | 97.7 | 100.1 | 104.4 | 101.3 | 100.2 |
| ៛/១០០ដុងវៀតណាម* | – | – | – | 27.1 | 26.6 | 25.6 | 25.6 | 24.8 | 25.3 | 25.1 | 25.3 | 25.9 |
| ថ្លៃមាស (ដុល្លារក្នុង១ជី) | 46.3 | 40.4 | 36.0 | 33.3 | 32.8 | 36.8 | 41.4 | 46.3 | 47.0 | 52.6 | 52.5 | 55.4 |
| ថ្លៃម៉ាស៊ូត (រៀល/លីត្រ) | 779 | 883 | 1,065 | 1,105 | 1,329 | 1,521 | 1,508 | 1,983 | 2,150 | 2,350 | 2,500 | 2,767 |
| ថ្លៃសាំង (រៀល/លីត្រ) | 1,118 | 1,378 | 1,613 | 1,760 | 2,113 | 2,084 | 2,150 | 2,767 | 2,950 | 3,050 | 3,300 | 3,633 |

Sources: CDRI, IMF, NIS, Ministry of Planning, Ministry of Economy and Finance. *Revised.

តារាង៧. ស្ថានភាពរូបិយវត្ថុ ឆ្នាំ១៩៩៧-២០០៥ (តួលេខនៅចុងការិយបរិច្ឆេទ)

| | 1997 | 1998 | 1999 | 2000 | 2001 | 2002 | 2003 | 2004 | | 2005 | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | | | | Q3 | Q4 | Q1 | Q2 | Q3 |
| | ពាន់លានរៀល | | | | | | | | | | | |
| ទ្រព្យសកម្មបរទេសសុទ្ធ | 1,177 | 1,726 | 2,019 | 2,589 | 3,080 | 3,737 | 4,027 | 4,524 | 4,797 | 4,883 | 5,084 | 5,391 |
| ទ្រព្យសកម្មក្នុងស្រុកសុទ្ធ | -114 | -496 | -576 | -759 | -876 | -849 | -698 | -354 | -467 | -385 | -455 | -397 |
| ឥណទេយ្យសុទ្ធលើរដ្ឋាភិបាល | 54 | 178 | 103 | 3 | -75 | -119 | -128 | -96 | -209 | -252 | -343 | -404 |
| ឥណទានចំពោះផ្នែកឯកជន | 637 | 655 | 763 | 898 | 936 | 1,059 | 1,337 | 1,673 | 1,817 | 1,983 | 2,166 | 2,386 |
| រូបិយវត្ថុទូទៅ M2 | 1,063 | 1,230 | 1,443 | 1,831 | 2,204 | 2,888 | 3,328 | 4,169 | 4,329 | 4,498 | 4,629 | 4,994 |
| រូបិយវត្ថុ M1 | 385 | 543 | 531 | 540 | 609 | 813 | 937 | 1,078 | 1,153 | 1,198 | 1,215 | 1,279 |
| រូបិយវត្ថុផ្សេងៗ | 678 | 687 | 911 | 1,291 | 1,594 | 2,075 | 2,391 | 3,091 | 3,176 | 3,300 | 3,414 | 3,715 |
| | បំរែបំរួលជាភាគរយធៀបនឹងឆ្នាំមុន | | | | | | | | | | | |
| រូបិយវត្ថុទូទៅ M2 | 16.6 | 15.7 | 17.3 | 26.9 | 20.4 | 31.0 | 15.2 | 38.7 | 30.0 | 22.9 | 20.4 | 19.8 |
| រូបិយវត្ថុ M1 | 17 | 41 | -2.2 | 1.7 | 12.8 | 33.5 | 15.3 | 21.7 | 23.0 | 19.0 | 16.8 | 18.6 |
| រូបិយវត្ថុផ្សេងៗ | 16.3 | 1.3 | 32.6 | 41.7 | 23.5 | 30.2 | 15.2 | 45.8 | 32.8 | 20.3 | 21.7 | 20.2 |

Source: National Bank of Cambodia.

*តពីទំព័រទី ២០* **ព័ត៌មានថ្មីៗ ពី វបសអ**

ការចុះអង្កេតដល់ភូមិចំនួន ៨ នៅស្វាយរៀង និងបន្ទាយមានជ័យ ។ ការសិក្សាPPA និងRETA បានអនុវត្តក្នុងកិច្ចសហការជាមួយធនាគារអភិវឌ្ឍន៍អាស៊ី និងវិទ្យាស្ថានជាតិស្ថិតិ ។

អ្នកស្រាវជ្រាវ វបសអ ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ បានបញ្ចប់នាពេលថ្មីៗនូវការចុះអង្កេតកន្លែងសំរាប់ដំណាក់កាលទីក្រុងនៃគំរោងអង្កេតមូលដ្ឋាន(BSP) លើការចុះបញ្ជីដីធ្លី ។ សរុប ២.៧១២អង្កេត បានធ្វើឡើងលើគ្រួសារ និងអាជីវកម្មធុនតូចក្នុងនេះនៅភ្នំពេញមាន៨៦១,សៀមរាប៥៣៨និងបន្ទាយមានជ័យ៥០៧ ។ គោលបំណងគំរោង BSP គឺសំដៅបង្កើតទិន្នន័យមូលដ្ឋានសំរាប់វាយតំលៃផលប៉ះពាល់សេដ្ឋកិច្ចនៃការចុះបញ្ជីដីធ្លីលើគ្រួសារជនបទ/ទីក្រុង និងអាជីវកម្មធុនតូចក្រោយកន្លងពេល ៣ឆ្នាំ ។ ឥឡូវនេះ វបសអ កំពុងបញ្ចប់សំណើមួយសំរាប់ដាក់ជូនទីភ្នាក់ងារ AusAID ស្ដីពីកម្មវិធីរយៈ ៥ឆ្នាំនៃការកសាងសមត្ថភាពស្រាវជ្រាវ និងគ្រប់គ្រងធនធានទឹក ។ គំរោងនេះនឹងអនុវត្តដោយរួមសហការជាមួយសាកលវិទ្យាល័យភូមិន្ទភ្នំពេញ និងសាកលវិទ្យាល័យស៊ីដនី ដោយសង្កត់ធ្ងន់លើការពង្រឹងសមត្ថភាពស្រាវជ្រាវខាងគោលនយោបាយនៅថ្នាក់ជាតិនិងតំបន់ និងការគ្រប់គ្រងក្នុងវិស័យធារាសាស្ត្រ ហើយក្រសួងធនធានទឹក និងឧត្តុនិយម និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សុទ្ធតែចាប់អារម្មណ៍នឹងគំរោងនេះ ។ ក្រុមវិមជ្ឈការ និងអភិបាលកិច្ចរបស់ វបសអ កំពុងបន្តធ្វើការសិក្សា ២ អំពីគណនេយ្យភាពរបស់វិស័យសាធារណៈថ្នាក់ខេត្ត និងការឆ្លើយតបរបស់អាជ្ញាធរមូលដ្ឋាន ។ ក្រុមនេះ បានបង្ហាញលទ្ធផលរកឃើញក្នុងការសិក្សាពីការផ្ដល់សេវាសាធារណៈ ក្នុងកិច្ចប្រជុំថ្នាក់ជាតិនៅដើមខែកុម្ភៈ ដោយរួមសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមូលនិធិអភិវឌ្ឍន៍មូលធននៃអង្គការសហប្រជាជាតិ ។

*តពីទំព័រទី ១២* **សមាគមកសិករ**

រីកលូតលាស់ និងកំលាំងប្រកួតប្រជែងរបស់សហករណ៍តូចៗ ដែលទើបបង្កើតថ្មី ។ អង្គភាពណាដែលមិនអាចបំពេញលក្ខខណ្ឌបាន ប្រហែលមិនអាចទទួលបានកម្មវិធីនិងសេវាសំខាន់ៗរបស់រដ្ឋ ដូចជាឥណទានពីធនាគារអភិវឌ្ឍន៍ជនបទនោះទេ ។ប៉ុន្តែ Otto 1998 រកឃើញថាតាមការយល់ឃើញរបស់ប្រជាជនក្រីក្រនៅជនបទ ចំនុចខ្សោយធំបំផុតរបស់ស្ថាប័នហិរញ្ញវត្ថុផ្លូវការគឺ ពិបាកទាក់ទង ការងារវែងកំព្រឹស និងបែបបទស្មុគស្មាញ ។

ក្នុងករណីសមាគមតាអុង គេឃើញច្បាស់ថា វិធីសាស្ត្របញ្ជាពីលើចុះក្រោមដើម្បីបង្កើតសមាគម ដោយគ្មានជំនួយបច្ចេកទេស ការកសាងសមត្ថភាព និងដំណោះស្រាយតំរូវការរបស់កសិករ វាមិនបានជោគជ័យទេ ។

## សេចក្ដីសន្និដ្ឋាន

នៅកម្ពុជា សហករណ៍កសិករនៅក្មេងខ្ចី ខ្វះហិរញ្ញប្បទាន ខ្វះថ្នាក់ដឹកនាំ/គ្រប់គ្រងដែលមានការបណ្ដុះបណ្ដាលសមស្រប ។ នាបច្ចុប្បន្ន បទប្បញ្ញត្តិអំពីការលើកទឹកចិត្តផ្សេងៗសំរាប់ឱ្យបង្កើតសមាគម ត្រូវតែប្រទាញប្រទង់ទៅគ្រប់ទិសទៅតាមផលប្រយោជន៍របស់អ្នកពាក់ព័ន្ធនានា ដូចជា កសិករ មន្ត្រីថ្នាក់មូលដ្ឋាន អាជីវករ និងស្ថាប័នផ្សេងៗ ។ កត្តាដែលជួយឱ្យសមាគមតាអុង អាចរីកលូតលាស់បានដោយជោគជ័យ គឺជាប្រព័ន្ធពាក់ព័ន្ធគ្នាចុះឡើងនៃការកសាងសមត្ថភាព ទិដ្ឋភាពខាងហិរញ្ញវត្ថុនិងសេដ្ឋកិច្ច គោលការណ៍សហករណ៍ និងអភិបាលកិច្ច ក្របខ័ណ្ឌស្ថាប័ន និងការបំពេញតំរូវការរបស់សមាជិក ។ រដ្ឋាភិបាលគួរពិនិត្យតាមដានដោយប្រយ័ត្នប្រយែងពីផលប៉ះពាល់នៃច្បាប់/បទប្បញ្ញត្តិបែបបទដែលអ្នកពាក់ព័ន្ធនានាមានប្រតិកម្មតបនឹងគោលនយោបាយ/ព័ត៌មានពីទីផ្សារ ព្រមទាំងលទ្ធផលនៃគោលនយោបាយរដ្ឋ ។

### កំណត់សំគាល់

១. ប្រសាសន៍របស់ ឯ.ឧ ច័ន្ទ សារុន នៅសិក្ខាសិលាជាតិស្ដីពីការពង្រឹងសហករណ៍កសិករ កាលពីថ្ងៃ ១៦ កញ្ញា ២០០៤ ។

២. កសិករធ្វើការជាបុគ្គលជាមួយក្រុមហ៊ុនឯកជន

៣. ករណីសិក្សានេះ ចងក្រងដោយលោក អ៊ុន ប៊ុនថា ប្រធានស្ដីទីនៃនាយកដ្ឋានពាណិជ្ជកម្មក្រៅប្រទេស ក្រសួងពាណិជ្ជកម្ម ក្នុងក្របខ័ណ្ឌគំរោងផ្ដល់ទុនដោយមជ្ឈមណ្ឌលអូស្ត្រាលីសំរាប់ការសិក្សាពីកសិកម្មអន្តរជាតិ (ACIAR) ឈ្មោះថា "ការកែលំអប្រព័ន្ធម៉ាឃីទីងសំរាប់ពោត និងសណ្ដែកសៀងនៅកម្ពុជា" និងដឹកនាំដោយសាស្ត្រាចារ្យ John Spriggs, University of Canberra, Australia ។

៤. បញ្ជីនេះ NBC និង RDB ជាអ្នកកាន់កាប់ ដើម្បីផ្ដល់អាទិភាពឱ្យអ្នកមានឈ្មោះក្នុងបញ្ជី ពីព្រោះឥណទានសំរាប់ផ្ដល់ឱ្យមានតិច ។

**ឯកសារយោងសូមអានអត្ថបទជាភាសាអង់គ្លេស**

តារាង៨. ចំណូលប្រចាំថ្ងៃជាមធ្យមពិតរបស់ពលករងាយរងគ្រោះ ( ថ្លៃថេរ ខែវិច្ឆិកា ២០០៥)

| | ចំណូលប្រចាំថ្ងៃ (ជារៀល) | | | | | | | | | បំរែបំរួលធៀបនឹងឆ្នាំមុន (%) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | 2000 | 2001 | 2002 | 2003 | 2004 | 2005 | 2005 | | | 2003 | 2004 | 2005 |
| | | | | | | | ឧសភា | សីហា | វិច្ឆិកា | | | |
| អ្នកធាក់ស៊ីក្លូ | 9,489 | 8,408 | 8,975 | 8,572 | 7,614 | 7,970 | 7,726 | 7,857 | 7,768 | -4.5 | -11.2 | 4.7 |
| អ្នកលីសែង | 7,951 | 6,746 | 7,044 | 6,676 | 6,895 | 6,616 | 7,056 | 6,000 | 6,473 | -5.2 | 3.3 | -4.0 |
| អ្នកលក់បន្លែតូចតាច | 7,016 | 6,493 | 6,566 | 6,532 | 6,947 | 7,321 | 8,574 | 5,938 | 8,385 | -0.5 | 6.4 | 5.4 |
| អ្នករើសអេតចាយ | 4,310 | 3,211 | 3,685 | 3,944 | 4,446 | 4,947 | 5,270 | 4,335 | 4,801 | 7.0 | 12.7 | 11.3 |
| អ្នកបំរើតាមភោជនីយដ្ឋាន* | 2,306 | 2,800 | 4,365 | 4,932 | 4,448 | 4,324 | 4,287 | 4,648 | 3,893 | 13.0 | -9.8 | -2.8 |
| អ្នកស៊ីឈ្នួលធ្វើស្រែ | 4,175 | 4,064 | 4,304 | 4,177 | 4,139 | 4,013 | 3,822 | 4,009 | 4,224 | -2.9 | -0.9 | -3.0 |
| កម្មកររោងចក្រកាត់ដេរ | 8,006 | 8,608 | 8,904 | 9,577 | 9,277 | 8,466 | 7,235 | 8,756 | 8,659 | 7.6 | -3.1 | -8.7 |
| អ្នករត់ម៉ូតូឌុប | 8,597 | 10,768 | 12,184 | 10,092 | 9,204 | 10,563 | 11,130 | 9,406 | 9,645 | -17.2 | -8.8 | 14.8 |
| កម្មករសំណង់គ្មានជំនាញ | 9,769 | 6,672 | 6,453 | 6,558 | 6,382 | 6,659 | 8,130 | 6,069 | 6,691 | 1.6 | -2.7 | 4.3 |
| កម្មករសំណង់មានជំនាញ | 15,491 | 11,105 | 12,605 | 13,111 | 12,679 | 12,055 | 12,320 | 10,273 | 11,253 | 4.0 | -3.3 | -4.9 |

សំគាល់: ចំនួលអ្នកបំរើតាមភោជនីយដ្ឋាន អ្នកស៊ីឈ្នួលធ្វើស្រែ កម្មករកាត់ដេរ អ្នករត់ម៉ូតូឌុប និងកម្មករសំនង់មាននិងគ្មានជំនាញ ចាប់ធ្វើអង្កេតពីខែកុម្ភៈ២០០០ ។*ចំនួលអ្នកបំរើតាមហាងមិនរាប់បញ្ចូលអាហារ និងការស្នាក់នៅដែលម្ចាស់ភោជនីយដ្ឋានផ្ដល់ឱ្យទេ ។

## ព័ត៌មានថ្មីៗ ពី វបសអ

### ផ្នែកគ្រប់គ្រង

នៅត្រីមាសទី១ ២០០៦ វបសអ បានឈានទៅអនុវត្តគំរោងយុទ្ធសាស្ត្រថ្មី ឆ្នាំ២០០៦-១០ របស់ខ្លួន ដែលក្រុមប្រឹក្សាភិបាលបានអនុម័តកាលពីនៅខែធ្នូ ២០០៥ ។ ដោយផ្អែកលើចំនុចខ្លាំង និងសមត្ថភាពបច្ចុប្បន្នរបស់ខ្លួនយុទ្ធសាស្ត្រ វបសអ សំរាប់ ៥ឆ្នាំខាងមុខ នឹងឆ្លុះបង្ហាញ គាំទ្រ និងបំពេញបន្ថែមលើយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធរបស់ខ្លួន ព្រមទាំងគោលដៅក្នុងគំរោងអភិវឌ្ឍន៍យុទ្ធសាស្ត្រជាតិថ្មីរបស់រាជរដ្ឋាភិបាល ។គំរោងរបស់ វបសអ មានចុះសេចក្តីប្រកាសបេសកកម្មធ្វើបច្ចុប្បន្នភាពថ្មីៗដូចខាងក្រោម :

*ក្នុងលក្ខណៈជាវិទ្យាស្ថានឯករាជ្យមួយរបស់កម្ពុជាខាងការស្រាវជ្រាវពីគោលនយោបាយអភិវឌ្ឍន៍ វបសអ មានបេសកកម្មចូលរួមចំនែកដល់ការអភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយចីរភាព និងលើកកំពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋកម្ពុជា តាមរយៈការស្រាវជ្រាវមានគុណភាពខ្ពស់ពីគោលនយោបាយអភិវឌ្ឍន៍ ការផ្សព្វផ្សាយចំណេះដឹង និងការកសាងសមត្ថភាព ។*

*វបសអ ប្រឹងប្រែងបំពេញបេសកកម្មនេះ ដោយធ្វើការងារជាដៃគូជាមួយស្ថាប័នសាធារណៈ និងសង្គមស៊ីវិលកម្ពុជា ស្ថាប័នអភិវឌ្ឍន៍ក្នុងតំបន់ និងពិភពលោក និងដោយគោរពដល់សមត្ថភាពរបស់ប្រជាពលរដ្ឋ និងស្ថាប័នកម្ពុជា ចំណេះដឹង និងបទពិសោធន៍ក្នុងស្រុក ព្រមទាំងប្រវត្តិសាស្ត្រ និងវប្បធម៌របស់ប្រទេសកម្ពុជា ។*

នៅឆ្នាំ២០០៦-១០ វបសអ នឹងខិតខំសំរេចឱ្យបាននូវគោលដៅយុទ្ធសាស្ត្រធំៗ ៣ :

១) ធ្វើការស្រាវជ្រាវគុណភាពខ្ពស់ ប្រាកដនិយម និងឯករាជ្យខាងគោលនយោបាយអភិវឌ្ឍន៍ ជួយឱ្យអ្នកធ្វើគោលនយោបាយអ្នកមានឥទ្ធិពល និងអ្នកពាក់ព័ន្ធផ្សេងទៀត អាចប្រើប្រាស់បានជាអតិបរមានូវចំណេះដឹងខាងអភិវឌ្ឍន៍នេះ និងផលប៉ះពាល់របស់វាទៅលើគោលនយោបាយក្នុង ៥វិស័យ ជាប់ទាក់ទិនគ្នា សំរាប់ការអភិវឌ្ឍន៍ប្រទេសកម្ពុជាប្រកបដោយចីរភាពៈ
- សេដ្ឋកិច្ច ពាណិជ្ជកម្ម និងកិច្ចសហប្រតិបត្តិការក្នុងតំបន់
- ការកាត់បន្ថយភាពក្រីក្រ ការអភិវឌ្ឍន៍កសិកម្ម និងជីវភាពនៅជនបទ
- អភិបាលកិច្ចប្រជាធិបតេយ្យនិងកំណែទំរង់វិស័យសាធារណៈ
- ធនធានធម្មជាតិ និងបរិស្ថាន
- សន្តិសុខមនុស្ស, ការកសាងសន្តិភាព និងការបំប្លែងទំនាស់

២) កសាងអនាគតប្រកបដោយចីរភាពសំរាប់ វបសអ ក្នុងលក្ខណៈជាវិទ្យាស្ថានស្រាវជ្រាវគោលនយោបាយអភិវឌ្ឍន៍នាំមុខគេនៅកម្ពុជា តាមរយៈការពង្រឹងគំរូអភិវឌ្ឍស្ថាប័នរបស់ខ្លួន កម្ពុជាភាវូបនីយកម្ម ការអភិវឌ្ឍន៍សមត្ថភាពបុគ្គលិកនិងថ្នាក់គ្រប់គ្រង និងការកេណ្ឌប្រមូលធនធានដ៏សក្តិសិទ្ធិ ។

៣) ឈានដល់ស្តង់ដារខ្ពស់បំផុតនៃអភិបាលកិច្ចស្ថាប័នល្អ ការគ្រប់គ្រងមានគុណភាព និងប្រព័ន្ធផ្តល់សេវាកម្ម ។

### ផ្នែកស្រាវជ្រាវ

នាបច្ចុប្បន្នវបសអកំពុងអនុវត្ត៣គំរោងស្រាវជ្រាវពាក់ព័ន្ធនឹងភាពក្រីក្រ ។ សមាជិក ២នាក់នៃក្រុមសិក្សាខាងការចេញឱ្យផុតពីភាពក្រីក្រ (MOPS) បានចូលរួម និងធ្វើបទបង្ហាញពីករណីសិក្សានៅកម្ពុជានៅក្នុងសិក្ខាសាលាបូកសរុបជាសាកលGlobal Synthesis Workshop) ក្នុងក្រុងSt. Petersburg នៅខែមករា ។ ការសិក្សានេះ មានកិច្ចសហការយ៉ាងជិតស្និទ្ធអំពីធនាគារពិភពលោកដោយ វបសអ អាចសំរេចបានគោលដៅធ្វើការស្រាវជ្រាវខាងគោលនយោបាយមានគុណភាពខ្ពស់ និងពង្រឹងសមត្ថភាពបុគ្គលិក ។

ការសិក្សា MOPS និងការតំលៃភាពក្រីក្រដោយមានការចូលរួម (PPA) នៅតំបន់ទន្លេសាប ក៏បានផ្តល់ព័ត៌មានផងដែរ ដល់គំរោងវាយតំលៃភាពក្រីក្រនៅកម្ពុជារបស់ធនាគារពិភពលោក ។

វបសអ ក៏កំពុងចូលរួមធ្វើការសិក្សាករិតតំបន់មួយស្តីពីការពិនិត្យឡើងវិញពីផលប៉ះពាល់លើភាពក្រីក្រនសមាហរណកម្មសេដ្ឋកិច្ចក្នុងមហាអនុតំបន់មេគង្គ (RETA) ។ បច្ចុប្បន្ន ក្រុមស្រាវជ្រាវ RETA បានបញ្ចប់

*តទៅទំព័រទី ១៩*


ទស្សនាវដ្តី អភិវឌ្ឍន៍កម្ពុជា

*ឯកសារបោះពុម្ពផ្សាយរបស់ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា*

ឆ្នាំទី១០ លេខ១ ខែមករា-មីនា ឆ្នាំ២០០៦



**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ)**

ផ្ទះលេខ៥៦ ផ្លូវ៣១៥ ទួលគោក ភ្នំពេញ កម្ពុជា

អាសយដ្ឋានប្រៃសណីយ: ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា

ទូរស័ព្ទ: (៨៥៥-២៣) ៨៨១-៧០១, ៨៨១-៩១៦, ៨៨៣-៦០៣ ទូរសារ: (៨៥៥-២៣) ៨៨០-៧៣៤

e-mail: cdri@camnet.com.kh / pubs@cdri.forum.org.kh

website: http://www.cdri.org.kh



*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* បោះពុម្ពផ្សាយដោយ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា នៅភ្នំពេញចំនួន ៤ដងមួយឆ្នាំជាភាសាខ្មែរ និងអង់គ្លេសនៅក្នុងពេលដំណាលគ្នា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ផ្តល់ជាវេទិកាមួយ ដើម្បីពិភាក្សាពីបញ្ហានៃការអភិវឌ្ឍន៍ដែលកំពុងតែជះឥទ្ធិពលដល់ប្រទេសកម្ពុជា ។ *អត្ថបទតាមដានសេដ្ឋកិច្ច* ផ្តល់ជូននូវមូលវិចារឯករាជ្យស្តីពីដំណើរប្រព្រឹត្តទៅនៃសេដ្ឋកិច្ចប្រទេសកម្ពុជា ។

*ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា* ស្វាគមន៍អត្ថបទទាំងឡាយពីប្រិយមិត្តអ្នកអាន ។ លិខិតត្រូវចុះហត្ថលេខាប្រត្យក្សភាព ទូរស័ព្ទ និងមានអាសយដ្ឋានផង ។ អ្នកនិពន្ធទាំងអស់ត្រូវទាក់ទង វបសអ មុននឹងជូនអត្ថបទរបស់ខ្លួន ទោះបីជាឯកសារនោះមិនទាន់រៀបរយក៏ដោយ ។ ឯកសារទាំងអស់នឹងត្រូវកែសម្រួលសំរាប់ការបោះពុម្ព ។ វបសអ សូមរក្សាសិទ្ធិបដិសេធការបោះពុម្ព ដោយមិនចាំបាច់បញ្ជាក់ពីហេតុផល ។

ISBN 99950-52-06-7

គ្រឹះស្ថានផ្សាយ: វបសអ

គ្រប់គ្រងកែសំរួល: យូ សិទ្ធីរិទ្ធ

កែសំរួលផលិតកម្ម: អ៊ុំ ចាន់ថា

រោងពុម្ពជប៉ុន ភ្នំពេញ រូបភាពទំព័រមុខ: រូបភាព CDRI



រក្សាសិទ្ធិ ២០០៦ វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា

រក្សាសិទ្ធិគ្រប់យ៉ាង-គ្មានផ្នែកណាមួយនៃការបោះពុម្ពផ្សាយនេះត្រូវបានចំលងទុក ឬផ្សព្វផ្សាយតាមទម្រង់ និងតាមមធ្យោបាយផ្សេងៗដូចជា: អេឡិចត្រូនិក យន្តកម្មថតចម្លង... ដោយគ្មានការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពី វបសអ ឡើយ ។


ISSN 1560-7615 / ISBN 978-99950-52-06-5


ទំនួលខុសត្រូវលើគំនិត សត្យានុម័ត និងការបញ្ចេញយោបល់ទាំងឡាយនៅក្នុង ទស្សនាវដ្តីអភិវឌ្ឍន៍កម្ពុជា គឺជាបន្ទុកផ្ទាល់របស់អ្នកនិពន្ធ ។

ការបញ្ចេញយោបល់ និងការបកស្រាយទាំងនោះ មិនមែនជាទស្សនៈរបស់ វបសអ ទេ ។